សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច


## សារណាបញ្ចប់ការសិក្សា

# កំណើនប្រជាជនផ្តល់ផលប៉ះពាល់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា

ស្រាវជ្រាវ ពីថ្ងៃទី១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី១៦ ខែ ឧសភា ឆ្នាំ២០១៩


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **គង់ ខេមរាត្ន**
**ហ៊ាង សុខលីម**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ឌុយ ចាន់ឌីណា**


ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍
ជំនាន់ទី៣

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# អារម្ភកថា

ដោយសង្កេតឃើញថា កំណើនប្រជាជនជាកត្តាដែលសំខាន់ ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងជាកត្តាជះឥទ្ធិពលខ្លាំងបំផុតមកលើសេដ្ឋកិច្ចកម្ពុជា។ កាលណាកំណើនប្រជាជនកើនឡើងខ្ពស់ នោះវាជាការព្រួយបារម្ភ និង ជាបញ្ហាប្រឈមដល់សេដ្ឋកិច្ច ព្រោះប្រសិនបើកំណើនប្រជាជនកើនឡើងខ្ពស់ជាងផលិតផលក្នុងស្រុកសរុប នោះវានឹងធ្វើអោយការអភិវឌ្ឍន៍សេដ្ឋកិច្ចយឺត ដោយសារមនុស្សកាន់តែច្រើនធ្វើអោយមានបញ្ហាជាច្រើនសំរាប់ធ្វើការដោះស្រាយ ម្យ៉ាងវិញទៀត កាលណាកំណើនប្រជាជនកើនឡើងលឿនរហ័ស វាអាចជះឥទ្ធិពលដល់កំណើនសេដ្ឋកិច្ចជាតិនិងស្តង់ដានៃការរស់នៅរបស់ប្រជាជនក្នុងប្រទេសកម្ពុជា ដោយសារនៅពេលចំនួនប្រជាជនស្ទុះឡើងខ្លាំង ធ្វើអោយកំលាំងពលកម្មច្រើន តំរូវការក៏ច្រើន ដែលជាហេតុបណ្តាលអោយប៉ះពាល់ដល់ការបែងចែកប្រាក់ចំណូល។ ផ្ទុយទៅវិញប្រសិនបើកំណើនប្រជាជនកើនឡើងទាបជាងផលិតផលក្នុងស្រុកសរុប ការអភិវឌ្ឍន៍សេដ្ឋកិច្ចនឹងល្អប្រសើរ និង មានប្រសិទ្ធភាព។ ជារួមដោយកំណើនប្រជាជនផ្តល់ផលប៉ះពាល់ដល់ការអភិវឌ្ឍន៍ សេដ្ឋកិច្ចកម្ពុជា ក្រោមរូបភាពវិជ្ជមាននិងអវិជ្ជមាន ដូច្នេះគឺត្រូវទាមទារអោយមានការសិក្សាស្រាវជ្រាវ ព្យាករណ៍ ប៉ាន់ស្មាន និងប្រមើលមើលទៅមុខ ដើម្បីរៀបចំផែនការ ក៏ដូចជាការដាក់ចេញនូវគោលនយោបាយជាតិ អោយប្រព្រឹត្តទៅបានល្អ។ ទើបយើងខ្ញុំបានធ្វើការសិក្សា ស្រាវជ្រាវអំពីទំនាក់ទំនងនៃធាតុផ្សំនៃកំណើនប្រជាជននិងការអភិវឌ្ឍន៍សេដ្ឋកិច្ច ដើម្បីជាជំនួយក្នុងការសិក្សាស្វែងយល់អោយបានស៊ីជម្រៅពីសេដ្ឋកិច្ចនិងប្រជាជនក្នុងប្រទេសកម្ពុជា សម្រាប់ធ្វើការសម្រេចចិត្ត គួរបង្កើនចំនួនប្រជាជន ឬធ្វើអោយមានកំណើនសេដ្ឋកិច្ច ដើម្បីរៀបចំផែនការ គោលនយោបាយសម្រាប់កម្ពុជា ដើម្បីលើកកម្ពស់ជីវភាពរស់នៅសុខុមាលភាពសង្គម និងស្តង់ដានៃការរស់នៅរបស់ប្រជាជនកម្ពុជាយើង។

យើងខ្ញុំសង្ឃឹមថាឯកសារមួយច្បាប់នេះ នឹងអាចជាទុនក៏ដូចជាគំរូដល់ការសិក្សា ស្រាវជ្រាវ ឬអនុវត្តរបស់បងប្អូនមិត្តនិស្សិតទាំងឡាយ និងអ្នកសិក្សាទាំងអស់។ ដោយហេតុតែនេះជាស្នាដៃដំបូងបំផុតរបស់យើងខ្ញុំ ហើយណាមួយយើងខ្ញុំក៏នៅក្មេងខ្ចីនៅឡើយ ហេតុដូចនេះហើយ តែងតែកើតមាននូវរាល់កំហុសទាំងឡាយដោយអចេតនា យើងខ្ញុំរីករាយនឹងទទួល ការរិះគន់បែបស្ថាបនាទាំងឡាយ ហើយប្រែក្លាយការរិះគន់នេះមកស្ថាបនានិងអភិវឌ្ឍន៍ខ្លួនជានិច្ច ពីសំណាក់ សាស្ត្រាចារ្យ សិស្ស និស្សិត និង អ្នកសិក្សាទាំងឡាយ។

# សេចក្តីថ្លែងអំណរគុណ

ស្នាដៃនៃ ការសិក្សាស្រាវជ្រាវនេះអាចប្រព្រឹត្តទៅមកបានដោយសារតែមានការចូលរួមជួយជ្រោមជ្រែង ពីសំណាក់សាស្ត្រាចារ្យ មិត្តនិស្សិតជាច្រើន។ ដែលក្នុងនោះដែរ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់៖

ជាដំបូង យើងខ្ញុំទាំងពីរសូមឱនកាយគោរពប្រណិបត្តិ និងសូមសម្តែងនូវកតញ្ញូតាធម៌ យ៉ាងជ្រាលជ្រៅចំពោះ៖

- លោកអ្នកមានគុណទាំងពីរ ដែលលោកទាំងពីរជាអ្នកមានគុណដ៏ធំធេងដែលពុំអាចគណនាបាន។ លោកទាំងពីរបាន ចិញ្ចឹមបីបាច់ ថែរក្សា យើងខ្ញុំជាកូន រហូតមក ដែលលោកទាំងពីរ បានជួយទំនុកបម្រុង គាំពារ យើងខ្ញុំជានិច្ច មិនថា ក្នុងផ្នែកស្មារតី សម្ភារ តម្រូវការផ្សេងៗ មិនថាក្នុងកាលៈទេសៈណាក៏ដោយ។
- លោកសាស្ត្រាចារ្យ **បណ្ឌិត ឌុយ ចាន់ឌីណា** ដែលបានដឹកនាំក្នុងការសរសេរសារណាជួយណែនាំ បង្ហាត់បង្ហាញ ចង្អុលបង្ហាញ ការជួយទំនុកបំរុង ទាំងផ្នែកស្មារតី ឯកសារគំនិត ចំណាយពេលវេលាដ៏មមាញឹក និងមានតម្លៃរបស់លោកផ្តល់ជាគំនិតយោបល់ល្អៗ និងផ្តួចផ្តើមក្នុងការសរសេរសារណារហូតដល់ស្នាដៃនេះកើតមានឡើងប្រកបដោយជោគជ័យ។
- **ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង ព្រឹទ្ធបុរស** លោក លោកស្រីសាស្ត្រាចារ្យ និង បុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានផ្ទេរនូវចំណេះដឹង ជំនាញ យើងខ្ញុំទាំងពីររូបពីឆ្នាំសិក្សាមូលដ្ឋានរហូតដល់ឆ្នាំទី៤ជាឆ្នាំបញ្ចប់ការសិក្សា និង លោកគ្រូ អ្នកគ្រូ ទាំងអស់ ដែលមិនបានរៀបរាប់ឈ្មោះដោយលោកបានជួយ បង្ហាត់បង្រៀន ណែនាំ ប្រឹក្សាល្អ ចំណាយពេលវេលាដ៏មមាញឹក មានតម្លៃរបស់លោកផ្តល់ជាគំនិតយោបល់ល្អៗ ផ្តល់ការដាស់តឿនល្អ និងបទពិសោធន៍ជាច្រើនមកដល់យើងខ្ញុំរហូតមក

- លោកស្រីសាស្ត្រាចារ្យ **សំណាង ផលដេត** ដែលបានជួយសម្រួលរាល់ឯកសារទាំងឡាយដែលពាក់ព័ន្ធនឹងការចុះស្រាវជ្រាវឯកសារ និងជួយពិនិត្យរចនាបថនៃសារាណារបស់យើងខ្ញុំ។
- លោកជំទាវ **ជូ ពុទ្ធានី** ជាអគ្គលេខាធិការរងនៃក្រសួងផែនការ ដែលបានអនុញ្ញាតិឲ្យយើងខ្ញុំចុះស្រាវជ្រាវឯកសារនានាដែលពាក់ពន្ធ័ រួមទាំងបុគ្គលនៃក្រសួងផែនការទាំងអស់ដែលបានជួយណែនាំ និងផ្តល់ឯកសារ។
- ក្រុមការងារ បងប្អូន សាច់ញាតិ មិត្តនិស្សិតទាំងអស់ដែលបានជួយផ្តល់នូវមតិយោបល់ គំនិត ការពិភាក្សា ការប្រឹក្សាយោបល់ ជួយជ្រុមជ្រែង ជំនួយផ្នែកស្មារតីរហូតមក។

ជាចុងបញ្ចប់យើងខ្ញុំសូមប្រសិទ្ធពរជ័យមហាបវរដ៍ថ្លៃថ្លាជូនចំពោះលោកអ្នកមានគុណទាំងពីរ ឯកឧត្តមសាកលវិទ្យាធិការ លោក និងលោកស្រីសាស្ត្រាចារ្យ រួមទាំងបុគ្គលិកសិក្សាទាំងអស់ មិត្តរួមជំនាន់និងអ្នកដែលបានរៀបរាប់ខាងលើទាំងអស់ដែលបានជួយឲ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាតៗឡើយ។

# មាតិកា

ទំព័រ


អក្សរកាត់ ............ iv

បញ្ជីតារាង ............ v

បញ្ជីរូប ............ vi

បញ្ជីក្រាហ្វិក ............ vii


## សេចក្តីផ្តើម


១.លំនាំបញ្ហានៃការស្រាវជ្រាវ ............ ១

២.ចំណោទបញ្ហានៃការស្រាវជ្រាវ ............ ២

៣. គោលបំណងនៃការស្រាវជ្រាវ ............ ៣

៤. ទំហំ និង ដែនកំណត់នៃការស្រាវជ្រាវ ............ ៣

៥.សារៈសំខាន់របស់ការស្រាវជ្រាវ ............ ៣

៦.វិធីសាស្រ្តនៃការស្រាវជ្រាវ ............ ៤

៦.១ វិធីសាស្រ្តនៃការស្រាវជ្រាវ ............ ៤


## ជំពូកទី១ រំលឹកទ្រឹស្តី

## ទ្រឹស្តីកំណើនប្រជាជននិងការអភិវឌ្ឍសេដ្ឋកិច្ច


១.១. ទ្រឹស្តីក្លាសុិក (Classical Theory) ............ ៧

១.១.១ ទ្រឹស្តីអំពីកំណើនមនុស្សរបស់លោក THOMAS ROBERT MALTHUS ............ ៧

១.១.២ ទ្រឹស្តីកំណើនប្រជាជនរបស់លោក Karl Marx ............ ៨

១.២ ទ្រឹស្តី Neo-Classical ............ ១០

១.២.១ ទ្រឹស្តី គំរូ Model លោក Solo ............ ១០

១.២.២. ទ្រឹស្តីកំណើនសេដ្ឋកិច្ចរបស់លោក Michael P, TODARO ............ ១២

# ជំពូកទី២
# ស្ថានភាពកំណើនប្រជាជនកម្ពុជាចន្លោះឆ្នាំ ២០១៣-២០១៨


២.១. ស្ថានភាពប្រជាសាស្ត្រ ........ ១៤

២.១.១ អត្រាប្រជាជនសរុប ........ ១៥

២.១.២ អត្រាកំណើនប្រជាជន ........ ១៨

២.១.៣ អត្រាពលកម្ម ........ ១៩

២.២ ស្ថានភាពទូទៅរបស់ប្រជាជនកម្ពុជា ........ ២០

២.២.១ អត្រាប្រជាជនក្រីក្រ ........ ២០

២.២.១.១ មូលហេតុដែលបណ្តាលអោយមានភាពក្រីក្រ ........ ២១

២.២.២ អត្រាប្រជាជនចំណាកស្រុក ........ ២៥

២.២.២.១ មូលហេតុដែលបណ្តាលអោយប្រជាជនចំណាកស្រុក ........ ២៧

២.៣. ប្រព័ន្ធសុខភាព និង ប្រព័ន្ធនៃការអប់រំរបស់ប្រជាជនកម្ពុជា ........ ២៨

២.៣.១ សុខភាព ........ ២៨

២.៣.១.១ អត្រាកើត ........ ២៨

២.៣.១.២ អត្រាមរណភាព ........ ២៨

២.៣.១.៣ អត្រាចំនួនលទ្ធភាពមានកូន និង អត្រាអាពាហ៍ពិពាហ៍ ........ ២៩

២.៣.២ ការអប់រំ ........ ៣២

២.៣.២.១ អត្រាអក្ខរជន ........ ៣២

២.៣.២.២ អត្រាចូលរៀន ........ ៣២

២.៤.១ អត្រាចូលរួមកំលាំងពលកម្ម ........ ៣៤

២.៤.២ អត្រាអនិកម្មភាព និង និកម្មភាព ........ ៣៥

២.៥ គោលនយោបាយប្រជាសាស្ត្រ ២០១៦-២០៣០ ........ ៣៦

## ជំពូកទី៣
## ស្ថានភាពការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា

៣.១ ស្ថានភាពកំណើនសេដ្ឋកិច្ចកម្ពុជាចន្លោះឆ្នាំ ២០១១-២០១៨ ........................................ ៤១

៣.១.១ ស្ថានភាពកំណើនសេដ្ឋកិច្ចកម្ពុជា ........................................................................ ៤១

៣.១.១.១ អត្រាកំណើនផលិតផលក្នុងស្រុកសរុប(ផ.ស.ស)............................................ ៤១

៣.១.១.២ ចំណូលប្រជាជនក្នុងពលរដ្ឋម្នាក់ ................................................................. ៤២

៣.១.១.២ អត្រាកំណើនតាមវិស័យ ............................................................................ ៤២

៣.២ កត្តាជំរុញអោយមានកំណើនសេដ្ឋកិច្ច .......................................................................៤៥

៣.២.១ ធនធានរូបដែលធម្មជាតិផ្តល់អោយ.................................................................. ៤៥

៣.២.២ ធនធានមនុស្ស.......................................................................................................... ៤៨

## ជំពូកទី៤
## ការសិក្សាលើលទ្ធផល

៤.១ ទំនាក់ទំនងរវាងកំណើនប្រជាជន និងការអភិវឌ្ឍសេដ្ឋកិច្ច ............................................ ៥០

៤.២. ការវិភាគលើផលវិជ្ជមាន និងអវិជ្ជមាន ..................................................................... ៥១

## សេចក្តីសន្និដ្ឋាន និង អនុសាសន៍

សេចក្តីសន្និដ្ឋាន និង អនុសាសន៍ ........................................................................................ ៥៣

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# អក្សរកាត់

- GDP Gross Domestic Product
- NIS National Institute Statistics
- ASFR Age-Specific Fertility Rate
- DHS Demographic and Health Survey
- CSES Cambodia Socio-Economic Survey
- ផ.យ.អ.ជ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ
- គ.ន.ជ.ប គោលនយោបាយអភិវឌ្ឍជាតិ
- ផ.ស.ស ផលិតផលជាតិក្នុងស្រុកសរុប

# បញ្ជីតារាង

ទំព័រ

តារាងទី១៖ចំនួនប្រជារាស្ត្រនៅកម្ពុជាយោងតាមប្រភពផ្សេង ............................................ ១៦
តារាងទី២៖កំណើនប្រជាជន ........................................................................................ ១៩
តារាងទី៣៖ស្ថានភាពអាពាហ៍ពិពាហ៍ .............................................................................. ៣១
តារាងទី៤៖អត្រាអក្ខរជននៅឆ្នាំ ២០១៣ ដល់ ២០១៨ ........................................................ ៣២
តារាងទី៥៖សូចនាករទាក់ទងនឹងការអប់រំបឋមសិក្សា(ថ្នាក់ជាតិ) ........................................៣៣
តារាងទី៦៖សូចនាករទាក់ទងនឹងមធ្យមសិក្សាបឋមភូមិ(ថ្នាក់ជាតិ).......................................៣៣
តារាងទី៧៖កំណើនផលិតផលក្នុងស្រុកសរុប ពីឆ្នាំ ២០១៣-២០១៨ ....................................៤២
តារាងទី៨៖ចំណែកនិងកំណើននៃវិស័យកសិកម្មឧស្សាហាកម្មនិងសេវាកម្មក្នុងផ.ស.ស ........ ៤៥
តារាងទី៩៖ចំនួនប្រជាជនសរុបនិងផលិតផលក្នុងស្រុកសរុបឆ្នាំ២០១៣ដល់២០១៨.............. ៥១
តារាងទី១០៖លទ្ធផលនៃការសិក្សា.............................................................................៥២

# បញ្ជីរូប

ទំព័រ

រូបភាពទី១៖ ទ្រឹស្តីរបស់លោក Malthus នៃចំនួនប្រជាជន ........................................................ ៨
រូបភាពីទី២ ៖ អត្រាកំណើនប្រជាជនកម្ពុជាចាប់ពីឆ្នាំ ២០១៣ ដល់ ឆ្នាំ២០១១៦ ........................ ១៧
រូបភាពទី៣៖ អាយុកាលសង្ឃឹមរស់របស់ប្រជាពលរដ្ឋកម្ពុជា .................................................. ១៨
រូបភាពទី៤ ៖ អត្រាមរណភាពមាតា និង ទារក ........................................................................ ២៩
រូបភាពទី៥ ៖ ការព្យាករណ៍អំពីលទ្ធភាពមានកូនសរុប(១៩៩០ - ២០៣០) ................................ ៣០

# បញ្ជីក្រាហ្វិក

ទំព័រ

ក្រាហ្វិកទី១ ៖ ការបែងចែកដីតាមតំបន់ ..........................................................................២២
ក្រាហ្វិកទី២៖ ភាពក្រីក្រក្នុងប្រជាជនម្នាក់ៗនៅទីក្រុង ជនបទ និងកម្ពុជា.............................. ២៣
ក្រាហ្វិកទី៣៖វដ្តវិលវល់នៃភាពក្រីក្រ (The Vicious Circle of Poverty)..................................២៤
ក្រាហ្វិកទី៤៖ បម្រែបម្រួលកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ច៖ កម្ពុជា ................................. ៣៦
ក្រាបទី៥ ៖ និន្នាការនៃសន្ទស្សន៍អភិវឌ្ឍធនធានមនុស្ស , ឆ្នាំ១៩៩០-២០១៤.........................៤៩

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា ជាប្រទេសមួយដែលហែកហួរដោយសង្គ្រាមអស់រយៈពេលជាច្រើនទសវត្សន៍មកហើយ។ កម្ពុជាបានឆ្លងកាត់បញ្ហាសង្គ្រាមមិនថាជាមួយប្រទេសដទៃ សង្គ្រាមស៊ីវិល និង វិបត្តិផ្ទៃក្នុងរាប់សិបដងមកហើយ ដែលវាបានបន្សល់ទុកអោយប្រជាជនកម្ពុជាទទួលទុក្ខវេទនា ទទួលរងនូវផលលំបាកយ៉ាងធ្ងន់ធ្ងរ ផលលំបាកយ៉ាងច្រើនឥតគណនានេះ ហើយដែលប្រជាជនកម្ពុជាយើងទទួលបានពីសង្គ្រាម អសន្តិសុខសង្គមជាដើម។ ជាពិសេសនៅក្នុងរបបដ៏ខ្មៅងងឹត របបប្រល័យពូជសាសន៍ប៉ុល ពត(១៩៧៥-១៩៧៩) ដែលប្រជាជនខ្មែរទូទាំងប្រទេសចងចាំមិនអាចបំភ្លេចបាននោះ គឺជាការសំលាប់ពូជសាសន៍ខ្លួនឯង ជាពិសេសគឺប្រជាជនដែលចំណេះដឹង និង ប្រជាជនទន់ខ្សោយដោយសំលាប់រង្គាល សម័យកម្ពុជាប្រជាធិបតេយ្យធ្វើអោយកម្ពុជាបាត់បង់ចំនួនប្រជាជនរាប់លាននាក់។ បើយោងទៅតាមប្រភពរបស់ **លោកព្រុជ ខោម** ប៉ានស្មានចំនួនប្រជាជនកម្ពុជាស្មើនឹង ៦,៩ លាននាក់នៅក្នុងឆ្នាំ១៩៧០ និង ៧,៩ លាននាក់នៅក្នុងឆ្នាំ១៩៧៥។ នៅក្នុងឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាត្រូវបានប៉ាន់ស្មានថាមានចំនួន ៦,៣លាននាក់។ យោងតាមអង្កេតប្រជាសាស្រ្តឆ្នាំ ១៩៨០ ចំនួនប្រជាជនកម្ពុជាត្រូវបានប៉ានស្មានថាមានចំនួន៦,៥លាននាក់។ ប្រការនេះមានន័យថាប្រជាជនកម្ពុជាជាង១លាននាក់ត្រូវបានបាត់បង់ជីវិតក្នុងរបបប្រល័យពូជសាសន៍ប៉ុល ពត រួមទាំងកុមារ មនុស្សពេញវ័យ មន្ត្រីរាជការ សាស្ត្រាចារ្យ អ្នកមានចំនេះដឹង និងប្រជាជនស្លូតត្រង់ជាដើម។ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំនៅឆ្នាំ ១៩៧៩ វាបានបន្សល់ទុកបញ្ហាជាច្រើនដោយសាររបបមួយនេះ មានដូចជា ការខូចខាតរចនាសម្ពន្ធ័ ផ្លូវថ្នល់ ស្ពាន មន្ទីរពេទ្យ សាលារៀន និង វត្តអារាមជាដើម បូករួមទាំងការខូចខាតទាំងស្រុងនៃប្រពន្ធ័សេដ្ឋកិច្ច ។ អ្វីដែលសំខាន់ជាងនេះទៅទៀតនោះគឺកម្ពុជាបានបាត់បង់នូវ ធនធានមនុស្ស បញ្ញាវ័ន្ត បុគ្គលសំខាន់ៗ អ្នកមានចំនេះដឹងជាច្រើន ដែលជាកត្តាសំខាន់សំរាប់ស្តារ និងអភិវឌ្ឍន៍ប្រទេសជាតិឡើងវិញ ដែលជាបញ្ហាប្រឈមធំបំផុតដែលត្រូវធ្វើការដោះស្រាយ ហើយចំនួនប្រជាជនដែលនៅសេសសល់ពីរបបនេះមានចំនួនត្រឹមតែ៦,៥លាននាក់ប៉ុណ្ណោះ។

ជាធម្មតា នៅក្រោយសង្គ្រាម គេតែងតែសង្កេតឃើញនូវដំណាក់កាល " ប្រជាជនមានចំនួនកើនឡើងខ្លាំងគួរអោយកត់សំគាល់ " ហើយនៅកម្ពុជាដំណាក់កាលនេះបានកើតមានឡើងនៅក្នុងអំលុងទស្សវត្សន៍ទី៨០ផងដែរ។ក្រោយពីបានជួបប្រទះបញ្ហាទាំងអស់នេះហើយ កម្ពុជា

បានស្តារឡើងវិញនូវ រចនាសម្ពន្ធ័ នយោបាយសង្គម និង សេដ្ឋកិច្ចរបស់ខ្លួន ជាជំហាន ដែលបានផ្តល់អាទិភាពខ្ពស់គឺការដោះស្រាយបញ្ហាដែលពាក់ពន្ធ័នឹង ប្រជាជន និង ការអភិវឌ្ឍ និងការជាប់ទាក់ទងគ្នាទៅវិញទៅមករបស់បញ្ហានេះ។ ដោយស្របទៅតាមតិកាសញ្ញាអន្តរជាតិនានាទិសដៅនៃគោលនយោបាយរួមនេះគឺ ដើម្បីធានាអោយមានការអភិវឌ្ឍសេដ្ឋកិច្ចអោយមានសន្ទុះខ្លាំងខ្លាលឿនជាងមុន ប្រកបដោយនិរន្តរ៍ភាព សំដៅលើកកម្ពស់និងធ្វើអោយប្រសើរឡើងនូវ គុណភាពជីវភាព សុខុលមាលភាពសង្គម ស្តង់ដានៃការរស់នៅ របស់ប្រជាជនកម្ពុជាយើង ។

ជាការពិតណាស់ថា កំណើនប្រជាជនអាចជះឥទ្ធិពលដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ហើយរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយជាតិ និងធ្វើជំរឿនប្រជាជនជារៀងរាល់ ១០ឆ្នាំម្តង ដើម្បីធ្វើផែនការគ្រប់គ្រងនៅស្ថានភាពដែលកើតឡើងពីការកើនឡើងនៃសន្ទុះប្រជាជន ជាមួយការអភិវឌ្ឍសេដ្ឋកិច្ច ដោយផ្អែកលើការបណ្តុះបណ្តាលធនធានមនុស្ស និងវិនិយោគខ្លាំងទៅលើវិស័យអប់រំ ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច ។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

កំណើនប្រជាជនគឺជាកត្តាគន្លឹះមួយចំពោះការរីកចំរើន និង ការអភិវឌ្ឍប្រកបដោយចីរភាពរបស់ប្រទេសទូទៅលើសាកលលោក។ដោយមានការបែងចែកជាទស្សនៈជាច្រើន ដែលទាក់ទងនឹងផលវិបាកនៃកំណើនប្រជាជនមកលើកំណើនសេដ្ឋកិច្ច ។ ជាហេតុធ្វើអោយមានការជជែកវែកញែកគ្នារវាងផលប៉ះពាល់វិជ្ជមាន និង អវិជ្ជមាននៃកំណើនប្រជាជនទៅកាន់សេដ្ឋកិច្ចនៅតែបន្តកើតមានឡើង។ នៅក្នុងផ្នែកវិជ្ជមាន កំណើនប្រជាជនបានធ្វើអោយមានការរីកចំរើននៃបច្ចេកវិទ្យា ការបង្កើតថ្មីធ្វើអោយមានការប្រកួតប្រជែងគ្នា បង្កើតជាអាជីវកម្មជាច្រើន ។ ផ្ទុយទៅវិញ កំណើនប្រជាជនបានធ្វើអោយប៉ះពាល់ដល់ស្បៀងអាហារ បញ្ហាប្រឈមថ្មីៗ ពេលខ្លះអាចធ្វើអោយមានការប៉ះពាល់ដល់សេដ្ឋកិច្ចជាតិផងដែរ។

យ៉ាងណាមិញប្រទេសកម្ពុជា ក៏បានខិតខំប្រឹងប្រែងធ្វើយ៉ាងណាដើម្បីអោយមានការលើកកម្ពស់ជីវភាពរបស់ប្រជាជន សុខុលមាលភាពរបស់ប្រជាជនគ្រប់ស្រទាប់វណ្ណៈ តាមរយៈការដាក់ចេញនៅគោលនយោបាយប្រជាសាស្ត្រ កំនត់អោយបានពីបំរែបំរួលប្រជាជន ដើម្បីងាយស្រួលក្នុងការធ្វើអោយសេដ្ឋកិច្ចមានការអភិវឌ្ឍ។ ក្នុងពេលថ្មីៗនេះ ប្រទេសកម្ពុជាយើងបានធ្វើជំរឿន ចាប់ពីថ្ងៃទី០៣ ដល់ ១១ ខែ មីនា ឆ្នាំ២០១៩ ដើម្បីមានទិន្នន័យគ្រប់គ្រាន់សំរាប់ដាក់ចេញជាចក្ខុវិស័យទៅអនាគត ព្រមទាំងងាយស្រួលដល់ការអភិវឌ្ឍប្រទេសជាតិយើង។

ប្រជាជនគឺជាប្រភពទិន្នន័យ ដើម្បីរដ្ឋាភិបាលដាក់ចេញគោលនយោបាយត្រឹមត្រូវ និង អនុវត្តត្រឹមត្រូវ ក្នុងការឈានដល់ការអភិវឌ្ឍប្រទេសជាតិប្រកបដោយនិរន្តរភាព។ តាមរយៈបញ្ហាខាងលើ ការសិក្សានឹងធ្វើការផ្តោតលើបញ្ហាចោទដូចជា៖

- តើស្ថានភាពសេដ្ឋកិច្ច និង ស្ថានភាពប្រជាជនមានលក្ខណៈដូចម្តេច?
- តើកំណើនប្រជាជននៅកម្ពុជាមានទំនាក់ទំនងយ៉ាងដូចម្តេចជាមួយនឹងកំណើនសេដ្ឋកិច្ច?
- តើគោលនយោបាយប្រជាសាស្ត្ររបស់កម្ពុជាមានគោលដៅយ៉ាងណាខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងរបស់សារាណានេះ គឺចង់ដឹងអំពីធ្វើយ៉ាងណាដើម្បីកំណត់ទំនាក់ទំនង ក៏ដូចជាមូលហេតុនៃកំណើនប្រជាជន និង កំណើនសេដ្ឋកិច្ច។ ដើម្បីកំនត់ថា

- កំណើនប្រជាជន និង កំណើនសេដ្ឋកិច្ចជាបាតុភូតរយៈពេលខ្លី ឬ រយៈពេលវែង
- ដើម្បីកំនត់ទំនាក់ទំនង មូលហេតុនៃកំណើនប្រជាជន និង សេដ្ឋកិច្ចកម្ពុជា
- តើកំណើនប្រជាជន ផ្តល់ផលប៉ះពាល់អ្វីខ្លះដល់សេដ្ឋកិច្ចកម្ពុជា

## ៤. ទំហំ និង ដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះទាក់ទងនឹងកំណើនប្រជាជន និង ការអភិវឌ្ឍសេដ្ឋកិច្ចសំរាប់អំឡុងឆ្នាំ ២០១៣ ដល់ ២០១៨ ។ ដោយសារវិសាលភាពដ៏ធំធេងនៃប្រធានបទលើចំនួនប្រជាជន ការស្រាវជ្រាវនេះគឺត្រូវបានថយចុះត្រឹមតែការសិក្សាអំពីកំណើនប្រជាជន និង ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា តែប៉ុណ្ណោះ ។ ចំពោះទំហំនៃការសិក្សា អត្ថបទស្រាវជ្រាវនេះ គឺយើងធ្វើការសិក្សាតែក្នុងរង្វង់សេដ្ឋកិច្ច និង ប្រជាជនកម្ពុជា ដោយផ្តោតទៅលើសេដ្ឋកិច្ចកម្ពុជា ចាប់ពីឆ្នាំ២០១៣ ដល់ ២០១៨ ក្នុងគោលបំណងកំណត់ពីកំណើនប្រជាជនផ្តល់ផលប៉ះពាល់ ( ជាវិជ្ជមាន និង អវិជ្ជមាន) ទៅលើសេដ្ឋកិច្ចកម្ពុជា ។ គួរអោយកត់សំគាល់ដែលថាយើងយកអថេរចំនួន២ មកធ្វើការសិក្សាស្រាវជ្រាវរួមមាន ចំនួនប្រជាជន និង ផលិតផលក្នុងស្រុកសរុប ( GDP ) មកធ្វើការសិក្សាដើម្បីវិភាគថា អថេរទាំងពីរមានការជាប់ពាក់ពន្ធ័គ្នាយ៉ាងដូចម្តេច?

## ៥.សារៈសំខាន់របស់ការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទ " **កំណើនប្រជាជនផ្តល់ផលប៉ះពាល់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា** " នេះនឹងផ្តល់ការរួមចំណែកយ៉ាងចាំបាច់ក្នុងការផ្តល់ជាចំនេះដឹង ព័ត៌មាន ឯកសារប្រភពទិន្នន័យ សម្រាប់បងប្អូនមិត្តនិស្សិត អ្នកស្រាវជ្រាវទាំងឡាយ។ ម្យ៉ាងវិញទៀត វាមានសារៈ

សំខាន់សំរាប់អ្នកសិក្សា និង អ្នកអនុវត្តក្នុងការស្វែងយល់ពីទំនោរ ស្ថានភាពបច្ចុប្បន្ន ការអភិវឌ្ឍ និង លទ្ធផលរំពឹងទុកលើកំណើនប្រជាជនក្នុងលក្ខខណ្ឌប្រទេសកម្ពុជា ដើម្បីរួមចំណែកលើកំណើនសេដ្ឋកិច្ច និង ការស្រាវជ្រាវបន្ត ថាតើយើងគួរធ្វើយ៉ាងណា ក្នុងការជំរុញកំណើនប្រជាជន និងកំណើនសេដ្ឋកិច្ច។ តាមរយៈប្រធានបទខាងលើ បានផ្តល់នូវសារៈប្រយោជន៍ជាច្រើនក្នុងការជួយជាគំនិត ពុទ្ធិ ក្នុងការសិក្សាទៅលើកំណើនប្រជាជន និងសេដ្ឋកិច្ចកម្ពុជាទៅថ្ងៃអនាគត ហើយវាអាចជាប្រភពឯកសារ និង ជាមតិយោបល់ក្នុងការកំនត់ពីគោលការណ៍ គោលនយោបាយ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដោយវាជួយបង្ហាញពី ៖

- ស្ថានភាពកំណើនប្រជាជន និង ការអភិវឌ្ឍសេដ្ឋកិច្ច
- ឥទ្ធិពលកំណើនប្រជាជនមកលើសេដ្ឋកិច្ចកម្ពុជា
- ឥទ្ធិពលកំណើនសេដ្ឋកិច្ចមកលើប្រជាជន

# ៦.វិធីសាស្ត្រនៃការស្រាវជ្រាវ

## ៦.១ វិធីសាស្ត្រនៃការស្រាវជ្រាវ

ក្នុងការស្រាវជ្រាវ និង ការសិក្សារបស់អត្ថបទស្រាវជ្រាវនេះ យើងនឹងសិក្សាដោយ ការប្រើប្រាស់វិធីសាស្ត្រគុណវិស័យ និង បរិមាណវិស័យដើម្បីឆ្លើយតប នឹងចំនោទបញ្ហានិងគោលបំណងនៃការសិក្សា។

- ទិន្នន័យផ្នែកគុណវិស័យ(QualitativeData) : ជាទិន្នន័យបែបពិព័រណ៌នាពីការយល់ឃើញ
- ទិន្នន័យផ្នែកបរិមាណ( QuantitativeData ) :ជាទិន្នន័យបែបតួលេខនិងតួលេខដែលអាចគណនាបាន។

### ក.ប្រភពទិន្នន័យ

ដើម្បីចងក្រងនូវឯកសារនេះឡើង គឺត្រូវការប្រើប្រាស់នូវប្រភពទិន្នន័យកម្រិតទី២ ( Second Data ) យកមកធ្វើការបកស្រាយ ដោយយើងខ្ញុំបានចុះទៅស្រាវជ្រាវឯកសារដោយផ្ទាល់នៅក្រសួងផែនការ ដើម្បីស្វែងរកទិន្នន័យ ក៏ដូចជាឯកសារដែលពាក់ពន្ធ័ និងប្រមូលទិន្នន័យសំខាន់ៗដែលដកស្រង់ចេញពីប្រភពនានាជាច្រើន ទាំងអត្ថបទបោះពុម្ពផ្សាយ សៀវភៅ របាយការណ៍ ទិន្នន័យក្នុង អត្ថបទស្រាវជ្រាវ ប្រព័ន្ធអេឡិចត្រូនិច និងតាមគេហទំព័រផ្សេងៗរបស់ក្រសួងក្នុងការឆ្លើយតបនឹងចំណោទស្រាវជ្រាវ និងគោលបំណងនៃការសិក្សាដូចដែលបានបង្ហាញខាងលើ។ ការសិក្សាក៏ធ្វើការដកស្រង់ទិន្នន័យ ដទៃផ្សេងទៀតដែលបានបោះពុម្ពជាលក្ខណៈផ្លូវការ ដោយឆ្លើយតបទៅនឹងគោលបំណងនៃការ

ស្រាវជ្រាវ នឹងការសិក្សាដូចជា សៀវភៅ កាសែត ទស្សនាវដ្ដី ព្រឹត្តិប័ត្រ របាយការណ៍នានាប្រភពផ្សេងៗ ឯកសារស្រាវជ្រាវ និងគេហទំព័រមួយចំនួនផ្សេងទៀត ដើម្បីជាប្រភពនៃការសារណានេះ។

### ខ. ការវិភាគទិន្នន័យ

កិច្ចការស្រាវជ្រាវនេះ បានជ្រើសរើសវិធីសាស្ត្រមួយដែលជាវិធីសាស្ត្របរិមាណវិស័យ និងទិន្នន័យដែលទទួលបាន។ ចំពោះការវិភាគ ការសិក្សានឹងធ្វើការប្រើប្រាស់ ការពណ៌នា ពីទិន្នន័យ និងការវិភាគ Regression ដែលប្រើប្រាស់ ជាមួយនឹងកម្មវិធី Microsoft Excel រៀងគ្នា។ ទាក់ទងនឹង កំណើនប្រជាជន និង GDP ( ផលិតផលក្នុងស្រុកសរុប ) គឺយើងធ្វើការប្រមូលទិន្នន័យចាប់ពីឆ្នាំ២០១៣-២០១៨មកធ្វើការបកស្រាយ។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

អត្ថបទសារណាក្រោមប្រធានបទ **កំណើនប្រជាជនផ្តល់ផលប៉ះពាល់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា** បានបែងចែកជា៤ ជំពូកធំៗដូចជា ៖

- ជំពូកទី១ ការរំលឹកទ្រឹស្តីដែលពាក់ពន្ធ័ ៖បង្ហាញពីការលើកឡើងពីទស្សនៈរបស់សេដ្ឋកិច្ចវិទូមួយចំនួនស្តីពីកំណើនប្រជាជន និង ការអភិវឌ្ឍសេដ្ឋកិច្ច ។ ធ្វើការពន្យល់ពីរបៀបនៃការគណនារកផលិតផលក្នុងស្រុកសរុបតាមរយៈវិធីសាស្ត្រផ្សេងៗ និងធ្វើការបង្ហាញពីសមាសធាតុដែលចូលរួមក្នុងការជំរុញអោយមានកំណើនប្រជាន និងការអភិវឌ្ឍសេដ្ឋកិច្ច។
- ជំពូកទី២ ស្ថានភាពកំណើនប្រជាជនកម្ពុជាចន្លោះឆ្នាំ ២០១៣-២០១៨ ៖ ជំពូកនេះ គឺធ្វើការបង្ហាញពីស្ថានភាពកំណើនប្រជាជនពីឆ្នាំ២០១៣-២០១៨ និងដំណាក់ការនៃកំណើនប្រជាជនក្នុងឆ្នាំនីមួយៗ។ រៀបរាប់អំពីអត្រាកំណើនប្រជាជនរៀងរាល់ឆ្នាំ អត្រាប្រជាជនក្រីក្រ សុខភាព ការអប់រំ កំលាំងពលកម្ម ដែលមានឥទ្ធិពលលើកំណើនប្រជាជន និងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។ បញ្ហាពីមូលហេតុ ដែលធ្វើអោយប្រជាជនក្រីក្រ ចំណាកស្រុក និងគោលនយោបាយរបស់រដ្ឋាភិបាល គោលនយោបាយដែលទាក់ទងនឹងប្រជាសាស្ត្រនៅកម្ពុជា។
- ជំពូកទី៣ ស្ថានភាពការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ៖ ជំពូកនេះ រៀបរាប់ពី ការស្វែងយល់ពីសេដ្ឋកិច្ចកម្ពុជាជាមួយនឹង ទំនោរនៃកត្តាសេដ្ឋកិច្ចផ្សេងៗក៏ដូចជា កត្តាដែលជំរុញសេដ្ឋ

កិច្ចកម្ពុជា ស្ថានភាពកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ និងស្ថានភាពជាក់ស្តែងដោយផ្តល់ជាការសិក្សា ដល់ការកំណត់ពីអថេរសិក្សា។

- ជំពូកទី៤ ការវិភាគលើលទ្ធផល ៖ បង្ហាញពីការវិភាគ និង លទ្ធផលដែលយើងបានសិក្សា ទៅលើគំរូដែលបានបង្កើត។ ការសិក្សាពីមេគុណ និងធ្វើការបកស្រាយពីអថេរនីមួយៗ។

# ជំពូកទី១ រំលឹកទ្រឹស្តី

# ទ្រឹស្តីកំណើនប្រជាជននិងការអភិវឌ្ឍសេដ្ឋកិច្ច

នៅក្នុងផ្នែកនេះយើងនឹងសិក្សាទៅលើទ្រឹស្តីសេដ្ឋកិច្ចដូចជា ទ្រឹស្តីក្លាស៊ិក(classic) ទ្រឹស្តីNeo-Classical ទ្រឹស្តីModern និង ទ្រឹស្តីនឹងគោលគំនិតរបស់សេដ្ឋកិច្ចវិទូនានា។

## ១.១. ទ្រឹស្តីក្លាស៊ិក ( Classical Theory )

### ១.១.១ ទ្រឹស្តីអំពីកំណើនមនុស្សរបស់លោក THOMAS ROBERT MALTHUS

Thomas Robert Malthus ផ្តើមចេញពីបាតុភូតនៃជីវិតរស់ក្នុងលោកអំពីលទ្ធភាពនៃការចាប់កំណើត ធំធាត់គ្មានព្រំដែន និងភាពមានកំរិតនៃការបំរុងស្បៀង ក៏ដូចជាតុល្យភាពដែលមានចរិតក្រិតក្រមរបស់ធម្មជាតិដើម្បីអនុវត្តន៍ទៅក្នុងសង្គមមនុស្ស។ គាត់បានសរសេរថា″ មនុស្សក៏ត្រូវការគោរពក្រិតក្រមនោះដូចមនុស្សដទៃទៅតាមធម្មជាតិដែលមានស្រាប់ ″ ។ តាមគាត់ចំនួនប្រជាជនកើនឡើងទៅតាមផលគុណ គឺ២៥ឆ្នាំ នឹងកើនទ្វេជាពីរ (១ , ២ , ៤ , ៨, ១៦,.....) រីឯមធ្យោបាយសំរាប់ការរស់នៅ កើនតាមផលបូក (១ , ២ , ៣ , ៤ ,៥ ,....)។ T.R.Malthus ទាញចេញនូវការសន្និដ្ឋានថា ‟ មូលហេតុសំខាន់នៃភាពក្រលំបាក អាស្រ័យលើការគ្រប់គ្រង និងការបែងចែកទ្រព្យធនមិនមានសមធម៌ ″ ។ វិធីតែមួយគត់គឺ សម្របសម្រួលកំណើនប្រជាជនកាត់បន្ថយកំណើនប្រជាជនអោយស្មើនឹងកំរិតនៃមធ្យាបាយរស់នៅ ។ គាត់បានលើកឡើងនូវវិធីពីរ ក្នុងការសម្របសម្រួលកំណើនរបស់ប្រជាជន ។ **ទីមួយ** តាមសមិទ្ធិផលនៃកំលាំងក្រិតក្រមធម្មជាតិចាំបាច់ដែលមានលក្ខណៈ ‟លុបបំបាត់ ″ នូវគ្រោះអត់ឃ្លាន ភាពដុនដាប ជំងឺឈឺថ្កាត់ សង្គ្រាម គ្រោះធម្មជាតិ ...។ ទីពីរ គឺវិធីសាស្ត្រខាងក្រៅ ‟ កំលាំងបំផ្លេចបំផ្លាញ ″ អាស្រ័យដោយការយល់ដឹងរបស់មនុស្ស ។

ពិនិត្យជារួម T.R.Malthus ចង់បង្ហាញចេញនូវនិន្នាការមានចរិតជាក្រិតក្រម ដែលចំនួនប្រជាជន កើនលឿនជាងមធ្យោបាយនៃរស់នៅក្នុងសង្គម ។ បញ្ហានេះត្រូវបានពិនិត្យមើលក្រោមរូបភាពនៃប្រវត្តិគំនិតសេដ្ឋកិច្ច ដែលវាមានអត្ថន័យបំពេញអោយកត្តាសំខាន់មួយគឺ ចំនួនប្រជាជន និង ចំណងទាក់ទងរវាងចំនួនប្រជាជនជាមួយនឹង ការរីកចំរើនសេដ្ឋកិច្ចក្នុងលក្ខខណ្ឌប្រវិត្តសាស្ត្រជាក់ស្តែង។[1]

រូបខាងក្រោមបង្ហាញពីវដ្តនៃកំណើនប្រជាជននិងមធ្យោបាយសំរាប់ការរស់នៅ

[1] សាស្ត្រាចារ្យ ម៉ម ចរិយាវុធ និង ងួន ហេង , សេដ្ឋកិច្ចនយោបាយ,២០១៦,ទំព័រទី១៤០

រូបភាពទី១ ទ្រឹស្តីរបស់លោក Malthus នៃចំនួនប្រជាជន




លោក Malthus បាននិយាយថា កំណើនប្រជាជនមានសារៈសំខាន់ក្នុងការកំណត់ពីភាពខុសគ្នានៃ កំណើនប្រជាជនជាក់ស្តែង និង លទ្ធភាពនៃកំណើនទិន្នផលស្បៀងរបស់ប្រទេសមួយ។ ហើយតាមការយល់ឃើញរបស់លោកបានយល់ឃើញថា ការកើនឡើងនៃចំនួនប្រជាជនវាមិនបានផ្តល់នូវផលវិជ្ជមានដល់កំណើនសេដ្ឋកិច្ចទេ ។ ម្យ៉ាងវិញទៀតគាត់កំណត់ថា កំណើនប្រជាជន នឹងមិននាំអោយមានប្រសិទ្ធភាពក្នុងកំណើននៃតម្រូវការនោះទេ ព្រោះពលករភាគច្រើនខ្វះសមត្ថភាព ឬ អំណាចទិញ ក្នុងការទិញ ដោយសារតែការប្រាក់ឈ្នួលនឹង ថយចុះពេលប្រជាជនកើនឡើង ។

មានន័យថា ក្នុងករណីដែលប្រជាជនមានការកើនឡើង នោះ ពលកម្មមានការកើនឡើងដូចគ្នា។ នៅពេលដែលពលកម្មមានការកើនឡើងនោះប្រាក់ឈ្នួលនឹងថយចុះ ហើយប្រសិនបើក្នុងករណីដែលពលកម្មកើនឡើងលើសពីការស្រូបទាញបានរបស់សេដ្ឋកិច្ច នោះធ្វើអោយមានភាពអត់ការងារធ្វើ។ ពេលនោះប្រាក់ចំណូលនឹងថយចុះ ហើយអំណាចទិញនឹងថយចុះដូចគ្នា ។

### ១.១.២ ទ្រឹស្តីកំណើនប្រជាជនរបស់លោក Karl Marx

យោងទៅតាមទ្រឹស្តីកំណើនប្រជាជនរបស់លោក Karl Marx បញ្ហាប្រជាជនកើតឡើងនៅក្នុង សង្គមមូលធននិយម ដែលធ្វើអោយមានការបរាជ័យក្នុងការផ្តល់ការងារដល់កម្មករ ពីព្រោះ

ការផ្គត់ផ្គង់កម្លាំងពលកម្មគឺច្រើនជាងតម្រូវការរបស់ខ្លួន។ ជាលទ្ធផល បណ្តាលអោយមមាន ចំនួនប្រជាជនលើស ធ្វើអោយប្រាក់ឈ្នួលពលកម្មមានការធ្លាក់ចុះ។

**ក.ទ្រឹស្តីតំលៃពលកម្ម**

Marx ជាមនុស្សដំបូងគេដែលបានរកឃើញលក្ខណៈពីរមុខរបស់ពលកម្មផលិតកម្មទំនិញគឺ ពលកម្មជាក់ស្តែងនិងពលកម្មអរូបី។ ការរកឃើញនេះក្លាយទៅជាកូនសោវិទ្យាសាស្ត្រសំរាប់ បង្កើតទ្រឹស្តីសេដ្ឋកិច្ចរបស់ខ្លួនអោយត្រឹមត្រូវ។ លក្ខណៈពីរមុខរបស់ពលកម្មផលិតកម្មទំនិញ កំណត់ពលកម្ម ជាក់ស្តែងជាអ្នកបង្កើតតំលៃប្រើប្រាស់ និងពលកម្មអរូបីជាអ្នកបង្កើតតំលៃ ទំនិញ។ គាត់បានធ្វើការវិភាគ ដើម្បីបំភ្លឺពីទំនាក់ទំនងរវាងតំលៃប្រើប្រាស់ និងតំលៃរបស់ទំនិញ ដែល Smith និងRichardo មិនអាចបកស្រាយបានរហូតដល់ពួកគេឈានទៅដល់ការបង្ហាញពី ភាពដូចគ្នារវាងតំលៃប្រើប្រាស់និងតំលៃដោះដូរ។ ក្នុងដំណើរវិភាគ K.Marx បានចាប់ផ្តើមពី ទំនិញរហូតដល់តំលៃដោះដូរ និងបានរកឃើញនូវធាតុពិតខាងក្នុង និងលក្ខណៈរបស់តំលៃ គឺ ពលកម្ម។ ក្រោយមកគាត់បានធ្វើការវិភាគទៅលើតំលៃរបស់ទំនិញគឺជា បរិមាណរយៈពេល ដែលពលកម្មសង្គមអាចផលិតទៅតាមតម្រូវការចាំបាច់បន្ទាប់មកគាត់វិភាគពីចំណងទាក់ទង រវាងតំលៃទំនិញនិងទិន្នផលនៃលទ្ធភាពពលកម្ម។ គាត់បានធ្វើការវិភាគដើម្បីបង្ហាញអោយ ឃើញច្បាស់នូវការស្តែងឡើងរបស់តំលៃទំនិញតាមដំណើរការអភិវឌ្ឍន៍របស់ផលិតកម្ម និងការ ដោះដូរទំនិញ។ តាមរយៈការស្វែងយល់របស់គាត់បានបង្ហាញច្បាស់ពីប្រភពលក្ខណៈនិង មុខងាររបស់រូបិយវត្ថុ។ គាត់បានរកឃើញនូវធាតុពិតនៃបាតដៃអរូបីដែលមានឥទ្ធិពលទៅលើ តំលៃ និងរូបភាពស្តែងឡើងរបស់តំលៃនោះគឺជាក្រិតក្រមតំលៃដែលវាជាក្រិតក្រមសេដ្ឋកិច្ចមូល ដ្ឋាននៃផលិតកម្មទំនិញដោះដូរទំនិញនិងក្រិតក្រមចរាចររូបិយវត្ថុ។ ជាមួយនឹងការរកឃើញខាង លើMarxសំរេចបាននូវការបង្កើតចេញទ្រឹស្តីតំលៃ-ពលកម្មដែលធ្វើអោយទ្រឹស្តីនេះបានប្រែក្លាយ ទៅជាវិទ្យាសាស្ត្រ និងធ្វើជាមូលដ្ឋានដើម្បីធ្វើការទិទៀនទ្រឹស្តីសេដ្ឋកិច្ចផ្សេងទៀត។

**ខ.ទ្រឹស្តីតំលៃលើស**

គាត់ចាប់ផ្តើមបកស្រាយចេញពីការបំលែងលុយទៅជាមូលធន គឺជាលក្ខ័ខណ្ឌដែលកំលាំង ពលកម្មក្លាយទៅជាទំនិញ។ លើមូលដ្ឋាននៃការយកលក្ខណៈពីរផ្នែក របស់ពលកម្ម ផលិតកម្មទំនិញធ្វើជាគន្លឹះដើម្បីបកស្រាយ Marx បានបែងចែកមូលធនទៅជាមូលធនថេរ និងមូលធនប្រែប្រួល ដើម្បីធ្វើការវិភាគបញ្ជាក់ពីប្រភពនិងលក្ខណៈចរិតរបស់មូលធន និងតំលៃលើស។ តាមរយៈអត្រាតំលៃលើសបរិមាណលើសនិងវិធីពីរយ៉ាងក្នុងការបង្កើតតំលៃ

លើសគាត់បានបង្ហាញចេញនូវទំនាក់ទំនងនៃការជិះជាន់របស់ពួកមូលធនទៅលើកម្មករ និង ទាញចេញបាននូវចរិតជាក្រិតក្រមតំលៃលើស គឺជាក្រិតក្រមមូលដ្ឋានរបស់លទ្ធិមូលធននិយម។ ជាមួយនឹងវិធីសាស្ត្រវិភាគខាងលើ Marx បានបង្ហាញច្បាស់នូវតួនាទីនិងសារៈសំខាន់របស់ទ្រឹស្តីតំលៃលើសដែលជាការរកឃើញដ៏អស្ចារ្យមួយរបស់គាត់។

**គ.ទ្រឹស្តីអំពីប្រាក់ខែ**

លើមូលដ្ឋាននៃការវិភាគបែងចែករវាងពលកម្មនិងកំលាំងពលកម្មគាត់បានរកឃើញនៃកំលាំងពលកម្ម មិនមែនថ្លៃពលកម្មដូចដែលបានស្តែងឡើងនៅខាងក្រៅនោះទេ។ Marx សរសេរថា" អ្វីដែលកម្មករលក់ហើយពួកមូលធនទិញគឺជាកំលាំងពលកម្មមិនមែនពលកម្មទេ។ ដោយហេតុនោះហើយបានជាពួកមូលធនអាចទាញយកបានមួយផ្នែកនូវតំលៃថ្មីដែលកម្មករបង្កើតឡើង(គឺតំលៃលើស)"។ គាត់បានយកចិត្តទុកដាក់ទៅលើចំណែកផ្សំនៃប្រាក់ខែរាល់កត្តាដែលមានឥទ្ធិពលដល់ប្រាក់ខែ និង រូបភាពបង្កើតឡើងរបស់ប្រាក់ខែ។

**១.២ ទ្រឹស្តី** Neo-Classical

**១.២.១ ទ្រឹស្តី គំរូ** Model **លោក** Solo

គំរូ Model Solow បានយកកត្តាចំនួនបីយកមកពិពណ៌នា គឺ ការសន្សំ កំណើនប្រជាជន និង ការរីកចម្រើននៃបច្ចេកវិទ្យា ដែលជះឥទ្ធិពលលើកំណើនពលរដ្ឋម្នាក់ៗទៅតាមពេលវេលា។ លោកបានជឿជាក់ថា ការកើនឡើងនូវ មូលធន និង ពលកម្ម នឹងនាំអោយមានកំណើនសេដ្ឋកិច្ច តែកំណើននោះ មានតែក្នុងអំលុងពេលខ្លីមួយប៉ុណ្ណោះ ដោយសារតែការបាត់បង់ធនធានក្នុងការផលិត ( ការសិករិចរិលនៃមូលធន )។ ក្នុងបញ្ហានេះលោកបានបង្ហាញទៀតថា ក្នុងការដោះស្រាយបញ្ហានេះបាន មានតែបច្ចេកវិទ្យាទេដែលអាចដោះស្រាយបាន។ ដោយការរីកចំរើនបច្ចេកវិទ្យា ជួយអោយ ផលិតភាពកើនឡើង និងប៉ះប៉ូវនូវការបាត់បង់មូលធនមានរូបពិត។

ក្នុងការសិក្សា និងបកស្រាយ Solow និងលោក Solow បានធ្វើការកំនត់ដូចខាងក្រោម

- សមីការផលិតកម្ម មានរាងទូទៅដូចខាងក្រោម

$$Y(t)=F(K(t),A(t)L(t))$$

- សមីការផលិតកម្ម បង្ហាញពីភាព Constant Returns to Scale

$$F(cK,cAL)=cF(K,AL)$$

- សមីការផលិតកម្មបំពេញលក្ខខណ្ឌដូចខាងក្រោម

$$f(0)=0$$

$f'(k)>0$

$f''(k)<0$

- តម្លៃនៃ អថេរមូលធន ពលកម្ម និងចំណេះដឹង ត្រូវបានផ្តល់ឲ្យ។ ហើយពលកម្ម និង ចំណេះដឹងកើនឡើងក្នុងកំរិតថេរ។

$$\frac{\partial L(t)}{\partial t} = \dot{L}(t) = nL(t)$$

$$\frac{\partial A(t)}{\partial t} = \dot{A}(t) = gA(t)$$

ផលិតផលសរុប ដែលផលិតបានត្រូវបានប្រើប្រាស់ ឬសន្សំ (វិនិយោគ) ក្នុងអត្រាសន្សំមួយ(s)។ ហើយរាល់ការវិនិយោគ ដែលបានមកពីការសន្សំ នាំអោយបង្កើតនូវមូលធន។ ហើយមានការ រំលស់របស់មូលធនសម្រាប់មូលធនដែលមានស្រាប់ដែលស្ថិតក្នុងអត្រារំលស់មួយ($\delta$)។

ការសិក្សា គេបានកំណត់នូវគំរូកំណើនសេដ្ឋកិច្ច ដូចខាងក្រោម ដែលបង្ហាញពី[2]

$$Y = AK^{\alpha}L^{1-\alpha}$$

តាមការបកស្រាយលោកបានបង្ហាញថា ប្រសិទ្ធភាពនៃមូលធនក្នុងពលរដ្ឋម្នាក់ៗ កំណត ដូចខាងក្រោម

$$k(t) = \left(\frac{s}{n+g+\delta}\right)^{\frac{1}{1-\alpha}}$$

រីឯ ប្រសិទ្ធភាពនៃផលិតភាព ក្នុងពលកម្មម្នាក់ៗ កំណត់បានដូចខាងក្រោម

$$y(t) = A(t)\left(\frac{s}{n+g+\delta}\right)^{\frac{\alpha}{1-\alpha}}$$

គំរូកំណើន

$$\ln y = C + \beta_1 \ln(s) + \beta_2 \ln(n+g+\delta)$$

ហើយមូលធនសរុបក្នុងសេដ្ឋកិច្ច កំណត់បានដូចខាងក្រោម

$$K(t) = L(t)A(t)\left(\frac{s}{n+g+\delta}\right)^{\frac{1}{1-\alpha}}$$

រីឯ ផលិតផលសរុបក្នុងសេដ្ឋកិច្ច ត្រូវកំណត់ដូចខាងក្រោម

$$Y(t) = L(t)A(t)\left(\frac{s}{n+g+\delta}\right)^{\frac{\alpha}{1-\alpha}}$$

[2] N.Gregory Mankiw; David Romer ; David N.Weil ; A Contribution to The Empirics of Economic Growth

ការបកស្រាយរបស់លោកបានបង្ហាញពី កត្តាផលិតកម្មពីរ ក្នុងសេដ្ឋកិច្ច គឺពលកម្ម និងមូលធន ហើយកត្តាផលិតកម្មទាំងពីរនេះ ត្រូវបានទទួលរងឥទ្ធិពលពីកត្តាដទៃទៀត ដែលលោកអាចបំពេញលែងលំអិតដូចបានបង្ហាញក្នុងគំរូ ខាងលើរបស់លោក ដែលក្នុងនោះមានដូចជា៖

n កំណើនប្រជាជន

s អត្រាសន្សំ ឬ វិនិយោគ (កំណត់ សន្សំ ស្មើ វិនិយោគ)

g កំណើនបច្ចេកវិទ្យា

δការរំលស់ រឺ សឹករិចរិលនៃមូលធន

L ចំនួនពលកម្ម

### ១.២.២. ទ្រឹស្តីកំណើនសេដ្ឋកិច្ចរបស់លោក Michael P, TODARO

តាមទ្រឹស្តីរបស់សេដ្ឋកិច្ចវិទូ Michael P, TODARO ដើម្បីអោយឲ្យមានកំណើនសេដ្ឋកិច្ចចាំបាច់បំផុតត្រូវមានកត្តាសំខាន់បីយ៉ាង ដូចខាងក្រោម៖

Y= f (L, K, A)

- ការកើនឡើងនៃមូលធនរួមបញ្ចូលទាំងការវិនិយោគថ្មីៗ ទាំងឡាយលើដីធ្លីសំភារៈបរិក្ខារ និង ធនធានមនុស្ស។
- ការកើនឡើងចំនួនប្រជាជនដែលនាំឲ្យមានកំណើនកម្លាំងពលកម្មជាយថាហេតុ
- ភាពជឿនលឿននៃបច្ចេកវិទ្យា

កំណើនប្រជាជន និងការកើនឡើងជាយថាហេតុនៅក្នុងកម្លាំងពលកម្ម ត្រូវបានគេពិចារណាតាមទម្លាប់ជាកត្តាវិជ្ជមានមួយក្នុងការធ្វើឲ្យមានកំណើនសេដ្ឋកិច្ច។ កម្លាំងពលកម្មដ៏ធំធេង មានន័យថាកម្មករផលិតគឺ មានចំនួនច្រើន ហើយនិងចំនួនប្រជាជនសរុបមានការកើនឡើងយ៉ាងធំធេងនោះកើននូវទំហំជាសក្តានុពលនៃទីផ្សារក្នុងស្រុកផងដែរ។ ម្យ៉ាងវិញទៀតវាជាបញ្ហាថាតើកំណើនភ្លាមៗនេះបានផ្តល់កម្លាំងពលកម្មបន្ថែមដើម្បីអភិវឌ្ឍន៍ប្រទេសដែលបានដាក់ឥទ្ធិពលវិជ្ជមាន និង អវិជ្ជមានទៅលើកំណើនសេដ្ឋកិច្ច។

ជាក់ស្តែងវាអាស្រ័យទៅលើប្រព័ន្ធសេដ្ឋកិច្ចដើម្បីស្រូបយក ហើយនិងធ្វើការយ៉ាងសកម្មដែលបន្ថែមឲ្យកម្មករ ដូចជាសមត្ថភាពដែលជាប់ពាក់ពន្ធ័យ៉ាងខ្លាំងជាមួយអត្រា និងប្រភេទនៃកំណើនមូលធន និងភាពដែលអាចរក្សាបាន ដូចជាជំនាញគ្រប់គ្រងរដ្ឋបាល។

ការផ្តល់នូវការយល់ដឹងដំបូងនៃសមាសភាគជាមួយមូលដ្ឋានគ្រឹះទាំងពីរនៃកំណើនសេដ្ឋកិច្ច ហើយនិងការមិនគិតគូរដល់បច្ចេកវិទ្យា ជាចំណុចទីបីភ្លាមៗនោះទេ អនុញ្ញាតឲ្យយើង

មើលឃើញនូវវិធីដែលវាធ្វើអន្តរកម្មគ្នាតាមរយៈព្រំដែនលទ្ធភាពផលិតកម្ម (Production Possibility Curve ) ដើម្បីពង្រឹងនូវផលិតផលសរុបជាសក្តានុពលនៃទំនិញទាំងអស់របស់សង្គម ចំពោះបច្ចេកវិទ្យា ហើយនិងធនធានមនុស្សដែលបានផ្តល់ឲ្យព្រំដែនលទ្ធភាពផលិតកម្មបាន គូសបង្ហាញនូវចំនួនអតិបរមា នូវការបូកបញ្ចូលផលិតផលដែលទទួលបាននៃផលរបរ នៅពេល ធនធានទាំងអស់មានគ្រប់គ្រាន់ និង ត្រូវបានប្រើប្រាស់មានប្រសិទ្ធភាព។

ឥលូវនេះឧបមាថា វាមិនមានការផ្លាស់ប្តូរនៃបច្ចេកវិទ្យាទេ ចំនួននៃធនធានមនុស្សឡើងទ្វេ ដែលជាលទ្ធផលនៃការវិនិយោគមួយក្នុងការបង្កើនគុណភាពនៃធនធានដែលមានស្រាប់ ឬក៏ការវិនិយោគនៅក្នុងធនធានថ្មីដូចជា ដី មូលធន ក្នុងករណីដែលមានពលកម្មច្រើន និង គ្រួសារខ្នាតធំ។

ពីព្រោះវាត្រូវបានគេសន្មតថា ជាទំនិញដែលត្រូវបានគេផលិតឡើងតាមរយៈសេដ្ឋកិច្ចនេះវាបង្ហាញនូវ GDP ខ្ពស់ជាងពីមុន ម្យ៉ាងវិញទៀតដំណើរនៃសេដ្ឋកិច្ចគឺស្ថិតនៅក្រោមមធ្យោបាយ។

ឥលូវនេះជំនួសឲ្យការសន្មត់កំណើនសមាមាត្ររបស់កត្តាទាំងអស់នៃផលិតកម្ម យើងអាចសន្និដ្ឋានបានថាមានតែដី និងមូលធនតែប៉ុណ្ណោះដែលបានកើនឡើងនៅក្នុងបរិមាណ និងគុណភាព។[3]

[3] Todaro,M.P.,&Smith,S.C.(2009).Economic Development .New York: Pearson Addison Wesley.

# ជំពូកទី២

# ស្ថានភាពកំណើនប្រជាជនកម្ពុជាចន្លោះឆ្នាំ ២០១៣-២០១៨

ក្នុងការសិក្សាពីស្ថានភាពសេដ្ឋកិច្ចកម្ពុជា យើងនឹងសិក្សាទៅលើ ស្ថានភាពនៃការប្រែប្រួលនៃកំណើនប្រជាជន ស្ថានភាពពលកម្ម ស្ថានភាពនៃការអប់រំ ស្ថានភាពនៃសុខភាពរបស់កម្ពុជាដែលការសិក្សារបស់យើង កំណត់ត្រឹមចន្លោះឆ្នាំ ២០១៣ ដល់ ២០១៨ ដែលតទៅនេះ យើងនឹងធ្វើការសិក្សាផ្នែកនីមួយៗ ដូចខាងក្រោម៖

## ២.១. ស្ថានភាពប្រជាសាស្ត្រ

បើយោងតាមច្បាប់ស្ដីអំពីស្ថិតិបានចែងក្នុងជំពូកទី១ បទប្បញ្ញត្តិទូទៅ មាត្រា៥ និង៦ បានចែងថា ជំរឿនសំដៅដល់ការប្រមូលស្ថិតិពីបុគ្គល គ្រួសារ សហគ្រាស ឬអង្គភាពចាត់តាំងផ្សេងទៀត ដែលអង្គភាពទាំងអស់ត្រូវបានធ្វើសម្ភាសន៍។ អង្កេត សំដៅដល់ការប្រមូលទិន្នន័យតាមបែបវិទ្យាសាស្ត្រពីបុគ្គល គ្រួសារ សហគ្រាស ឬអង្គភាពចាត់តាំងផ្សេងទៀត ដែលអង្គភាពជ្រើសរើសគំរូតែប៉ុណ្ណោះ ត្រូវសម្ភាសន៍។ ជំពូកទី៣ ការប្រមូលទិន្នន័យស្ថិតិ មាត្រា៦ បានចែងថា ទិន្នន័យស្ថិតិត្រូវបានប្រមូលតាមរយៈ៖

ក. ការធ្វើជំរឿន។

ខ. ការធ្វើអង្កេត។

គ. ការទទួលទិន្នន័យរដ្ឋបាលពីប្រភពរាជរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល។

មាត្រា៧ បានចែងថា ជំរឿនដូចមានចែងក្នុងមាត្រា៦ កថាខណ្ឌ ក ខាងលើនេះត្រូវដំណើរការយ៉ាងតិចមួយដងក្នុងរយៈពេល ១០( ដប់ ) ឆ្នាំ។

ជំរឿនមាន ៣ ប្រភេទ ៖

ក. ជំរឿនប្រជាជន។

ខ. ជំរឿនកសិកម្ម។

គ. ជំរឿនសេដ្ឋកិច្ច។

ជំរឿនទាំងនេះត្រូវអនុវត្ត ដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ដោយសហការជាមួយស្ថាប័នពាក់ពន្ធ័។

មាត្រា៩ បានចែងថា អង្កេតចន្លោះជំរឿនទាំងឡាយ អាចត្រូវបានដំណើរការ ក្នុងចន្លោះជំរឿនពីរ សម្រាប់ធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំនូវទិន្នន័យជំរឿនគោល ដើម្បីចងក្រងស្ថិតិសេដ្ឋកិច្ច និងសង្គមកិច្ចត្រឹមត្រូវគួរទុកចិត្តបាន ដែលឆ្លើយតបទៅនឹងសេចក្ដីត្រូវការរបស់អ្នកធ្វើគោលនយោបាយ

របស់រាជរដ្ឋាភិបាល និងអ្នកប្រើប្រាស់នានា។ មាត្រា១០ បានចែងថា អង្កេតដូចមានចែងក្នុងមាត្រា៦ កថាខណ្ឌ ខ នៃច្បាប់នេះ ត្រូវដំណើរការតាមពេលកំណត់ ដើម្បីផលិតស្ថិតិជាតិជាគ្រឹះដ៏ត្រឹមត្រូវ គួរទុកចិត្តបាន និងជាពិសេសដើម្បីបម្រើឲ្យសេចក្តីត្រូវការទិន្នន័យស្ថិតិបន្ទាន់របស់រាជរដ្ឋាភិបាល។ ក្នុងគោលបំណងធ្វើអង្កេតសេដ្ឋកិច្ចវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការត្រូវបង្កើតបញ្ជីពាណិជ្ជកម្ម ឬគ្រោងសំណាកគំរូសម្រាប់អង្កេតដើម្បីរក្សាទុក និងធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំ។[4]

## ២.១.១ អត្រាប្រជាជនសរុប

### ក.និន្នាការប្រជាជននៅកម្ពុជា

ចំនួនប្រជារាស្រ្តនៅកម្ពុជាមានចំនួន ៥,៧ លាននាក់ តាមជំរឿនឆ្នាំ ១៩៦២ ដែលជាជំរឿនផ្លូវការលើកទីមួយ បន្ទាប់ពីប្រទេសទទួលបានឯករាជ្យពីអាណានិគមនិយមបារាំង។ លក្ខណៈប្រជាសាស្រ្តរបស់ប្រទេសកម្ពុជា មានការផ្លាស់ប្តូរទាំងស្រុងបន្ទាប់ពីជំរឿននោះ មានសង្រ្គាម និងភាពវឹកវរ។

ជំរឿនមិនបានធ្វើរហូតដល់ឆ្នាំ១៩៩៨ និងមិនមែនប្រព័ន្ធអង្កេតថ្នាក់ជាតិ រហូតដល់ឆ្នាំ១៩៩៣-៩៤។ ទោះបីយ៉ាងណាក៏ដោយ ប្រជារាស្រ្តមានការផ្លាស់ប្តូរ ក្នុងអឡុងទសវត្សឆ្នាំ១៩៧០ ដែលត្រូវបានពិនិត្យលម្អិតដោយអ្នកប្រជាសាស្រ្តវិទូ និងអ្នកស្រាវជ្រាវ ដែលមានការប៉ាន់ស្មានខុសៗគ្នា និងរដ្ឋាភិបាលនៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជា បានអនុវត្តរាប់ចំនួនប្រជារាស្រ្តនៅឆ្នាំ ១៩៧៩ និង ១៩៨០។

មិនមែនការអះអាងណាមួយ អំពីព័ត៌មានប្រជាសាស្រ្តរហូតដល់ឆ្នាំ១៩៩២។ អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា ( UNTAC ) បានចុះឈ្មោះអ្នកបោះឆ្នោតមានអាយុចាប់ពី ២០ឆ្នាំឡើងមានចំនួន ៤.២៨លាននាក់។ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចនៅកម្ពុជាបានអនុវត្តធ្វើដោយវិទ្យាស្ថានជាតិស្ថិតិ នៅក្នុងឆ្នាំ១៩៩៤ បានប៉ាន់ស្មានចំនួនប្រជាសាស្រ្តនៅកម្ពុជា មានចំនួន៨.៤៧លាននាក់ ។ វិទ្យាស្ថានជាតិស្ថិតិ បានអនុវត្តអង្កេតប្រជាសាស្រ្ត នៅឆ្នាំ១៩៩៦ គ្របដណ្តប់ ២០.០០០គ្រួសារ និងប៉ាន់ស្មានចំនួនប្រជារាស្រ្តមាន ១០,៧លាននាក់។

តួលេខនេះជាប្រភពតែមួយគត់រហូតដល់ការធ្វើជំរឿនប្រជារាស្រ្តឆ្នាំ ១៩៩៨ ដែលបានប្រារព្ធធ្វើនៅខែ មីនា ឆ្នាំ១៩៩៨។ ចំនួនប្រជារាស្រ្តកម្ពុជាមានចំនួន ១១,៤ លាននាក់ យោងតាម

[4] ច្បាប់ស្តីពីស្ថិតិ

លទ្ធផលជំរឿនឆ្នាំ ១៩៩៨។ ទិន្នន័យនេះ មានការកើនឡើងប្រហែល ១,៩៦ លាននាក់ ពីទសវត្ស ១៩៩៨-២០០៨ អាចឈានដល់ចំនួន ១៤,៦៨ លាននាក់។[5]

**តារាងទី១ ៖ចំនួនប្រជារាស្ត្រនៅកម្ពុជា យោងតាមប្រភពផ្សេងៗ**

| ប្រភព | ប្រជារាស្ត្រ | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទាំងពីរភេទ | បុរស | ស្ត្រី | |
| (1) | (2) | (3) | (4) | (5) |
| ជំរឿនឆ្នាំ ១៩៦២ | 5728771 | 2862939 | 2865832 | កាលបរិច្ឆេទជំរឿនថ្ងៃទី១៧-១៩ ខែមេសា ឆ្នាំ១៩៦២ |
| អង្កេតទូទៅនូវប្រជាសាស្ត្រឆ្នាំ ១៩៨០ | 6589954 | 3049450 | 3540504 | កាលបរិច្ឆេទរាប់នៅជំណាច់ឆ្នាំ ១៩៦២ |
| អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ ១៩៩៣-៩៤ | 9870000 | 4714000 | 5156000 | កាលបរិច្ឆេទប៉ាន់ស្មានប្រជាសាស្ត្រខែមេសាឆ្នាំ១៩៩៨ លើមូលដ្ឋានគំរូដែលមានសំណាកគំរូ៥៤៧៩គ្រួសារ |
| អង្កេតប្រជាសាស្ត្រកម្ពុជាឆ្នាំ ១៩៩៦ | 10702329 | 5119587 | 5582742 | កាលបរិច្ឆេទប៉ាន់ស្មានប្រជាសាស្ត្រថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៩៨ លើមូលដ្ឋានគំរូដែលមានសំណាក២០០០០គ្រួសារ |
| ជំរឿនឆ្នាំ ១៩៩៨ | 11437656 | 5119587 | 5926248 | កាលបរិច្ឆេទកំណត់ជំរឿនថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨។ មិនរាប់បញ្ចូលតំបន់មួយចំនួនមានការប្រយុទ្ធនៅពេលធ្វើជំរឿន។តាមការប៉ានស្មានចំនួនប្រជារាស្ត្រនៅតំបន់ មិនរាប់បញ្ចូលនោះមាន៤៥០០០នាក់។ |
| អង្កេតប្រជាសាស្ត្រចន្លោះ ជំរឿនកម្ពុជាឆ្នាំ២០០៨ | 12824000 | 6197000 | 6627000 | ចំនួនប្រជាសាស្ត្រប៉ាន់ស្មានពីគ្រួសារធម្មតានាថ្ងៃទី០៣ ខែមីនាឆ្នាំ២០០៨ ដោយមិនគ្របដណ្តប់ប្រជាសាស្ត្រស្ថាប័នគ្មានផ្ទះសំបែង។ល។ |
| ជំរឿន ឆ្នាំ ២០០៨ | 13395682 | 6516054 | 6879628 | កាលបរិច្ឆេទកំណត់ជំរឿនថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨។ រាប់បញ្ចូលទាំងគ្រួសារខ្លះដែលមិនបានឆ្លើយ។ |
| អង្កេតប្រជារាស្ត្រចន្លោះ ជំរឿនកម្ពុជាឆ្នាំ ២០១៣ | 14676591 | 7121508 | 7555083 | ចំនួនប្រជាសាស្ត្រប៉ាន់ស្មានពីគ្រួសារធម្មតានាថ្ងៃទី០៣ ខែមីនាឆ្នាំ២០១៣ |

**ខ.ការប៉ាន់ស្មានចំនួនប្រជាជន**

[5] អង្កេតចន្លោះជំរឿននៃប្រជាសាស្ត្រឆ្នាំ ២០១៣ របាយការណ៍លទ្ធផលសរុបបណ្តោះអាសន្ន,២០១៣,១០

កម្ពុជា ត្រូវបានចាត់ទុកជាប្រទេសដែលមានប្រជាជនវ័យក្មេងច្រើន ដោយសារប្រជាជនដែលមានអាយុលើសពី ៦៥ ឆ្នាំមានចំនួនប្រមាណតែ ៥ ភាគរយប៉ុណ្ណោះនៃចំនួនប្រជាជនសរុបនៅឆ្នាំ២០១៥។ទោះយ៉ាងណា អត្រាកំណើនប្រជាជនមាននិន្នាការថយចុះជាបន្តបន្ទាប់ពី ១.៤៦ ភាគរយនៅឆ្នាំ ២០១៣ មកនៅ១.៣៦ ភាគរយនៅឆ្នាំ ២០១៨។

**រូបភាពីទី២ ៖ អត្រាកំណើនប្រជាជនកម្ពុជាចាប់ពីឆ្នាំ ២០១៣ ដល់ ឆ្នាំ២០១៨**




ប្រភព៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ២០១៤-២០១៨

ដោយសារអត្រាកំណើនប្រជាជនបានថយចុះជាបន្តបន្ទាប់ ស្របពេលដែលអាយុកាលសង្ឃឹមរស់របស់ប្រជាជនមាននិន្នាការកើនឡើង កម្ពុជាក៏បាននិងកំពុងបោះជំហានក្លាយទៅជាសង្គមដែលមានមនុស្សចាស់ច្រើន ឬសង្គមចាស់ជរា ( Aging Society )បន្តិចម្តងៗផងដែរ។

ការអភិវឌ្ឍនៃវិស័យសុខាភិបាល និងការទទួលបាននូវចំណីអាហារ និងជីវជាតិគ្រប់គ្រាន់ គឺជាកត្តាចម្បងដែលនាំឲ្យមានការកើនឡើងនៃអាយុកាលសង្ឃឹមរស់របស់ប្រជាជនកម្ពុជា។ យោងតាមការព្យាករណ៍របស់អង្គការសហប្រជាជាតិ ចាប់ពីឆ្នាំ ២០៣០ ទៅ កម្រិតអាយុកាលសង្ឃឹមរស់របស់ប្រជាជនកម្ពុជានឹងកើនឡើងខ្ពស់ជាង ៧០ឆ្នាំ ដែលកត្តានេះ ក៏មានផលប៉ះពាល់ផងដែរចំពោះអត្រាទ្រទ្រង់មនុស្សចាស់ (កម្លាំងពលកម្មដែលមានអាយុពី ១៥ឆ្នាំដល់៥៩ឆ្នាំទ្រទ្រង់ជនចាស់ជរាដែលមានអាយុ ចាប់ពី៦០ឆ្នាំឡើងទៅ)។ និន្នាការនៃការប្រែក្លាយទៅជាសង្គមដែលមានមនុស្សច្រើន បង្ហាញពីតម្រូវការចាំបាច់ក្នុងការសន្សំប្រាក់សម្រាប់គាំពារនៅពេលចាស់ជរា ដើម្បីទ្រទ្រង់ការរស់នៅនិងដើម្បីជៀសវាងពីការធ្លាក់ចូលក្នុងភាពក្រីក្រ។[6]

[6] ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥,៦

**រូបភាពទី៣៖ អាយុកាលសង្ឃឹមរស់របស់ប្រជាពលរដ្ឋកម្ពុជា**




ប្រភព៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ២០១៤-២០១៨

### ២.១.២ អត្រាកំណើនប្រជាជន

បើការអង្កេតចន្លោះជំរឿនខែមីនា ឆ្នាំ២០១៣ ប្រជាជនកម្ពុជាមានចំនួនប្រជាជនសរុបចំនួន ១៤,៧ លាននាក់ ។ ដង់ស៊ីតេប្រជាជនក្នុងមួយគម$^2$ នៅឆ្នាំ២០១៣ មានចំនួន ៨២ ។ នៅចន្លោះឆ្នាំ២០១៤ ដល់ ឆ្នាំ ២០១៨ ដង់ស៊ីតេប្រជាជនក្នុងមួយគម$^2$ មានការកើនឡើងពីចំនួន ៨៥ ដល់ ៩០ ដោយមានការកើនឡើងជារៀងរាល់ឆ្នាំ។រីឯចំនួនបុរសធៀបនឹងស្ត្រី (ស្ត្រីក្នុង១០០នាក់)ចាប់ពីឆ្នាំ២០១៣ ដល់ ២០១៨ មានការកើនឡើងពីចំនួន ៩៤,៣ ដល់៩៦,៧។ ចំណែកឯអាយុ0-១៤ នៅឆ្នាំ២០១៣-២០១៤ មានចំនួនពី ២៩,៤% ដល់ ២៩,៦%នៃប្រជាជន។ ចាប់ពីឆ្នាំ២០១៥ ដល់ ២០១៨ មានការធ្លាក់ចុះពី២៩,២%ដល់ ២៨,៥%នៃប្រជាជន។ ម្យ៉ាងវិញទៀត អាយុ១៥-៦៤ គឺនៅឆ្នាំ២០១៣ រហូតដល់ ឆ្នាំ២០១៨ មានការកើនឡើងគួរអោយកត់សម្គាល់ ពី ៦២,៦% ដល់ ៦៦,៥%នៃប្រជាជន។ហើយអាយុ៦៥ឆ្នាំឡើងមានការថយចុះបន្តិចបន្តួចគឺពីឆ្នាំ២០១៣ ដល់ ២០១៨ គឺមាន៥,0% ហើយមានការធ្លាក់ចុះរហូតដល់ឆ្នាំ២០១៨ មាន៥,0%នៃប្រជាជន។បន្ថែមជាងនេះទៅទៀត យើងឃើញថា អត្រាកំណើនប្រចាំនៅឆ្នាំ២០១៣ ដល់ ២០១៨ មានការធ្លាក់ចុះបន្តិច គឺធ្លាក់ចុះពី ១,៤៦% នៅឆ្នាំ២០១៣ ដល់ ១,៣៦% នៅឆ្នាំ២០១៨។

**តារាងទី២ ៖ កំណើនប្រជាជន**[7]

| សូចនករសំខាន់ៗ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ប្រជាជន | | | | | | | |
| សរុប: អង្កេតចន្លោះជំរឿន ខែមីនា ឆ្នាំ២០១៣ | លាននាក់ | ១៤,៧ | | | | | |
| ដង់ស៊ីតេប្រជាជន | ក្នុងមួយគម² | ៨២ | ៨៥ | ៨៧ | ៨៨ | ៨៩ | ៩០ |
| បុរសធៀបនឹងស្ត្រី | ស្ត្រី១០០នាក់ | ៩៤,៣ | ៩៦ | ៩៦,២ | ៩៦,៣ | ៩៦,៥ | ៩៦,៧ |
| អាយុ ០-១៤ | %នៃប្រជាជន | ២៩,៤ | ២៩,៦ | ២៩,២ | ២៨,៩ | ២៨,៧ | ២៨,៥ |
| អាយុ ១៥-៦៤ | %នៃប្រជាជន | ៦២,៦ | ៦៥,៩ | ៦៦,២ | ៦៦,៤ | ៦៦,៥ | ៦៦,៥ |
| អាយុ ៦៥ឆ្នាំឡើង | %នៃប្រជាជន | ៥,០ | ៤,៥ | ៤,៦ | ៤,៧ | ៤,៨ | ៥,០ |
| ជនបទ | %នៃប្រជាជន | ៧៨,៦ | ៧៨,៥ | ៧៨,៤ | ៧៨,៣ | ៧៨,២ | ៧៨,១ |
| ទីប្រជុំជន | %នៃប្រជាជន | ២១,៤ | ២១,៥ | ២១,៦ | ២១,៧ | ២១,៨ | ២១,៩ |
| អត្រាកំណើនប្រចាំឆ្នាំ | % | ១,៤៦ | ១,៤៤ | ១,៤២ | ១,៤១ | ១,៣៩ | ១,៣៦ |

ប្រភព៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨

### ២.១.៣ អត្រាពលកម្ម

លទ្ធផលនៃការអង្កេតចន្លោះជំរឿននៅឆ្នាំ ២០១៣ បានបង្ហាញថា ៦៥ ភាគរយនៃចំនួនប្រជាជនសរុបមានអាយុចាប់ពី ១៥ ដល់ ៦៤ ឆ្នាំស្ថិតនៅក្នុងកម្លាំងពលកម្ម។ រៀងរាល់ឆ្នាំ ប្រជាជនវ័យក្មេងប្រមាណ ២៣ ០០០នាក់ បានហក់ចូលក្នុងទីផ្សារការងារ។

[7] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

ទិន្នន័យខាងលើ បង្ហាញអំពីតម្រូវការខ្ពស់លើការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ។ ការបណ្តុះបណ្តាលវិជ្ជាជីវៈ គឺជាកត្តាចម្បងដែលរួមចំណែកក្នុងការលើកកម្ពស់ទីផ្សារការងារ។ យុវជនស្ថិតក្នុងអាយុធ្វើការដែលមានជំនាញវិជ្ជាជីវច្បាស់លាស់មានឱកាសច្រើនក្នុងការទទួលបានការងារ ដែលមានប្រាក់ចំណូលខ្ពស់និងផ្តល់នូវផលិតភាពខ្ពស់។

ចំពោះការចូលរួមកម្លាំងពលកម្មរបស់ប្រជាជន ជំរឿនទូទៅប្រជារាស្ត្រឆ្នាំ ២០០៨ បង្ហាញថា ៤ភាគ៥នៃប្រជាជនដែលមានអាយុ ១៥-៦៤ឆ្នាំ បានចាត់ទុកខ្លួនឯងថាមានការងារធ្វើ(៨២% ក្នុងចំណោមបុរស និង៧៩% ក្នុងចំណោមស្ត្រី)។ នៅក្នុងឆ្នាំ២០១៣ ភាគរយនេះបានកើនឡើង៣% ចំពោះបុរស ប៉ុន្តែគ្មានការកើនឡើងទេចំពោះស្ត្រី។ អត្រាចូលរួមកម្លាំងពលកម្មរបស់យុវជនអាយុ ១៥-២៤ឆ្នាំ បានកើនឡើងតិចតួចសម្រាប់ទាំងពីរភេទ ប៉ុន្តែអត្រាចូលរួមកម្លាំងពលកម្មរបស់មនុស្សចាប់ពីអាយុ ៦៥ឆ្នាំឡើងបានថយចុះ។ ទោះបីជាលទ្ធផលនេះមានលក្ខណៈវិជ្ជមានក៏ដោយ ក៏ការគិតគូរដល់គុណភាពនៃកម្លាំងពលកម្មដែលនឹងចូលក្នុងទីផ្សារការងារ គឺជាប្រការសំខាន់។ នៅពេលដែលយើងធ្វើការវិភាគរួមគ្នា អំពីការទទួលបានការអប់រំរបស់ប្រជាជន និងការចូលទៅក្នុងកម្លាំងពលកម្ម យើងអាចកត់សម្គាល់ឃើញថា យុវវ័យដែលចូលរួមក្នុងកម្លាំងពលកម្ម គឺគ្មានជំនាញ ឬមានជំនាញតិចតួច ដោយភាគច្រើនមិនបានសិក្សាលើសពីកម្រិតបឋមសិក្សា។ ឈរលើទស្សនវិស័យនៃកាលានុវត្តភាពប្រជាសាស្ត្រ សង្គមជាតិទាំងមូលនឹងមានការលំបាកក្នុងការទទួលបានអត្ថប្រយោជន៍តាមរយៈកំលាំងពលកម្មវ័យក្មេងដែលគ្មានជំនាញ ឬមានជំនាញតិចតួចបែបនេះ។[8]

## ២.២ ស្ថានភាពទូទៅរបស់ប្រជាជនកម្ពុជា

### ២.២.១ អត្រាប្រជាជនក្រីក្រ

កំណើនសេដ្ឋកិច្ចកើនឡើងធ្វើឲ្យមានឥទ្ធិពលយ៉ាងខ្លាំងនិងមានភាពវិជ្ជមានលើការកាត់បន្ថយភាពក្រីក្រ។ ភាពក្រីក្រត្រូវបានកាត់បន្ថយពី២១,១% ក្នុងឆ្នាំ២០១០ មកនៅ ១៣,៥% នៅឆ្នាំ២០១៤ កម្រិតនៃការធ្លាក់ចុះនេះសម្រេចបានមុនឆ្ងាយពីចំណុចដៅរបស់ *គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា* ដែលបានកំណត់នៅត្រឹម ១៩,៥% និង ១៣,៨% ក្នុង ផ.យ.អ.ជ នៅឆ្នាំ២០១៨។ ទោះបីយ៉ាងណាការកាត់បន្ថយភាពក្រីក្រនៅមានភាពមិនស្មើគ្នាទៅតាមតំបន់នៃប្រទេស តំបន់ខ្លះសម្រេចបាននូវកម្រិតខ្ពស់នៃការកាត់បន្ថយភាពក្រីក្រ ខណៈដែលនៅតំបន់

[8] គោលនយោបាយប្រជាជន ២០១៦-២០៣០,៥

ផ្សេងទៀតដូចជា នៅភាគឦសាននៅមានអត្រាខ្ពស់ការកាត់បន្ថយភាពក្រីក្រនៅមានកម្រិតជីវភាពតិចតួចនៅឡើយ។ កម្រិតភាពក្រីក្រនៅតែបន្តមានច្រើនតំបន់ជនបទបើធៀបនឹងតំបន់ទីប្រជុំជន។[9]

### ២.២.១.១ មូលហេតុដែលបណ្តាលអោយមានភាពក្រីក្រ

**ដីកសិកម្ម**

ដីកសិកម្មគឺជាកត្តាមួយដ៏សំខាន់នៅក្នុងដំណើរការផលិតកម្មកសិកម្ម ពីព្រោះវាកំណត់នូវកម្រិតផលិតភាពកសិកម្ម និង ភាពក្រីក្រ។ ទោះបីជាយ៉ាងនេះក្តី អត្រាគ្រួសារកសិករដែលកំពុងរស់នៅតំបន់ទំនាបដែលកាន់កាប់ដីកសិកម្មតិចជាង ០១ហិចតា បានកើនឡើងពី ៥៦% (ឆ្នាំ ២០០៩)ដល់ ៧៣% (ឆ្នាំ២០១១)និងធ្លាក់ចុះមក ៦៩% (ឆ្នាំ២០១២) និង ៦៦% (ឆ្នាំ២០១៣)។ជាងនេះទៅទៀត ប្រជាជនតែប្រមាណ ២០% ប៉ុណ្ណោះដែលកាន់កាប់ដីកសិកម្មក្នុងចន្លោះពី ០១ហិកតា និង ០២ ហិកតា។ ដូច្នេះ សរុបមក ប្រជាជនប្រមាណ ៩៥% ដែលកំពុងរស់នៅក្នុងតំបន់ទំនាប កាន់កាប់ដីកសិកម្មដែលមានក្បាលដីតូច ជាង ០៣ ហិកតា។ ជារួមប្រជាជនកម្ពុជាភាគច្រើនលើសលប់ ដែលធ្វើការក្នុងវិស័យកសិកម្ម និង ចិញ្ចឹមជីវិតដោយពឹងផ្អែកលើដីកសិកម្មដដែល មានទំហំតូច ងាយនឹងប្រឈមនឹងហេតុការណ៍ដែលមិនបានព្រៀងទុក(ឧ, ទិន្នផលទាប និង ទឹកជំនន់)ដែលកើតាមានឡើងនៅក្នុងកម្រិតគ្រួសារ និងកម្រិតភូមិ និងអាចរុញច្រានពួកគេឲ្យធ្លាក់ទៅក្នុងក្រីក្រ ព្រោះពួកគេត្រូវបង្ខំចិត្តលក់ទ្រព្យតាមលទ្ធភាពដែលមានដើម្បីសម្រាលផលប៉ះពាល់ដែលបណ្តាលមកពីហេតុការណ៍មិនបានព្រមព្រៀងទុកទាំងនោះ។

[9] របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០១៦ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨, ១៩

**ក្រាហ្វិកទី១ ៖ ការបែងចែកដីតាមតំបន់**




| | Plain | | | Tonle Sap | | | Cambodia | | |
|---|---|---|---|---|---|---|---|---|---|
| | Less than 1 ha | 1 ha - 2 ha | 2 ha - 3 ha | Less than 1 ha | 1 ha - 2 ha | 2 ha - 3 ha | Less than 1 ha | 1 ha - 2 ha | 2 ha - 3 ha |
| 2009 | 56.1 | 26.7 | 8.8 | 34.4 | 30.0 | 15.4 | 46.9 | 27.7 | 11.5 |
| 2010 | 57.0 | 25.0 | 10.0 | 41.0 | 28.0 | 15.0 | 49.0 | 28.0 | 12.0 |
| 2011 | 73.4 | 21.8 | 3.3 | 49.8 | 32.5 | 10.1 | 64.4 | 25.8 | 6.1 |
| 2012 | 69.4 | 22.4 | 4.3 | 46.8 | 32.8 | 8.4 | 58.8 | 27.4 | 6.7 |
| 2013 | 66.6 | 24.4 | 4.9 | 41.9 | 35.5 | 11.7 | 56.2 | 29.6 | 7.5 |

**ប្រភព៖** NIS ( CSES 2009-2013 )

ដីកសិកម្មដែលមាន ទំហំតូចក៏ឆ្លុះបញ្ចាំងពីអត្រាខ្ពស់នៃភាពក្រីក្រនៅតាមបណ្តាលតំបន់ជនបទ និងវិសមភាពរយៈពេលវែងដែរ ដែលជាលទ្ធផលនៃវិសមភាពនៃការបែងចែកដីកសិកម្ម ភាពខុសគ្នារវាងទីតាំងភូមិសាស្ត្រនិងរវាងបុរសនិងស្ត្រី។ ថ្វីបើអត្រាភាពក្រីក្របានធ្លាក់ចុះយ៉ាងខ្លាំងប្រមាណពាក់កណ្តាលនៅក្នុងឆ្នាំ២០១២ អត្រានៅជនបទគឺប្រមាណ ២១% ប្រៀបធៀបនឹង ៦,៤% នៅទីក្រុង។

**ក្រាហ្វិកទី២៖ ភាពក្រីក្រក្នុងប្រជាជនម្នាក់ៗនៅទីក្រុង ជនបទ និងកម្ពុជា**




**ប្រភព៖** អ្នកស្រាវជ្រាវរៀបចំក្រាហ្វិកនេះដោយប្រើប្រាស់ទិន្នន័យពីធនាគារពិភពលោក(២០១៥)

**ហេតុការណ៍ដែលមិនបានព្រៀងទុក( Shock )**

នៅពេលដែលមានបណ្តាញសន្តិសុខសង្គម ក្រុមគ្រួសារកសិករនៅជនបទ ងាយនឹងទទួលរងគ្រោះដោយហេតុការណ៍មិនបានព្រៀងទុក (ឧ, គ្រោះរាំងស្ងួត និង ទឹកជំនន់ )។ ក្នុងការសិក្សាដ៏លម្អិតមួយ *ស្តីពីរបៀបដែលគ្រួសារកសិករឆ្លើយតបចំពោះហេតុការណ៍មិនបានព្រៀងទុកមុន* បានបង្ហាញថាជារឿយៗ គ្រួសារទាំងនោះប្រឈមនឹងជំងឺ និងភាពអត់ការងារធ្វើ ដែលធ្វើឲ្យពួកគេប្រឈមនឹងភាពក្រីក្រ ឬភាពក្រីក្ររ៉ាំរ៉ៃ ដែលតម្រូវឲ្យពួកគេបង្ខំចិត្តត្រូវតែលក់ទ្រព្យសកម្ម ដូចជាដីកសិកម្ម សត្វពាហនៈ និងសម្ភារៈកសិកម្ម ដើម្បីចំណាយទៅលើការព្យាបាលជំងឺ។ ទិន្នន័យពីវិទ្យាស្ថានស្ថិតិជាតិ (ការអង្កេតសេដ្ឋកិច្ច-សង្គម ២០០៩-២០១៣)ក៏បង្ហាញផងដែរថានៅចន្លោះឆ្នាំ ២០០៩-២០១៣ នៅតំបន់ជនបទនៃប្រទេសកម្ពុជា បានចំណាយលើសុខភាពមានប្រមាណ១០% គ្រឿងឧបភោគបរិភោគ ៥០% និងថ្លៃទឹក ផ្ទះ និងភ្លើង ៣០%។ ហេតុនេះ ការចំណាយក្នុងគ្រួសារនីមួយៗគឺត្រូវប៉ាន់ប្រមាណថានឹងធ្លាក់ចុះ ៧,៩៦% ប្រសិនបើគ្រួសារកសិករជួបប្រទះហេតុការណ៍មិនបានព្រៀងទុក។ ផលប៉ះពាល់អាចនាំឲ្យមានវិសមភាពក្នុងរយៈពេលវែងរវាងអ្នកក្រនិងអ្នកមាន និងរវាងមេគ្រួសារជាបុរស និងមេគ្រួសារជាស្ត្រី ។ គ្រួសារកសិករដែលមានដីធំជាង ៣ហិកតា អាចនឹងធ្លាក់ក្នុងភាពក្រីក្ររ៉ាំរ៉ៃតិចជាងគ្រួសារដែលគ្មានដី ឬមានដីទំហំតូច។

ផលប៉ះពាល់កាន់តែធ្ងន់កើតមានឡើងចំពោះគ្រួសារដែលមានស្ត្រីជាមេគ្រួសារ ដែលមានតែប្រមាណ១៥% កាន់កាប់ដីកសិកម្ម។ការប៉ាន់ស្មានបានឲ្យដឹងទៀតថា បើសិនជាមេគ្រួសារឬសមាជិកណាមួយក្នុងគ្រួសារមិនអាចធ្វើការបាន គ្រួសារអាចបាត់ចំណូលប្រមាណ ០,២លានរៀលក្នុងមួយគ្រួសារ/ឆ្នាំ និងការខាតបង់ដែលបណ្តាលមកពីភាពគ្មានការងារធ្វើអាចឡើងដល់ ០,៧ លានរៀលក្នុង១គ្រួសារ/ឆ្នាំ។

**ការអប់រំ**

ធនធានមនុស្ស គឺជាកត្តាដែលសំខាន់បំផុតក្នុងដំណើរការអភិវឌ្ឍន៍។កម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការពង្រឹងគុណភាពនៃការអប់រំ និងធ្វើឲ្យអត្រាការចូលរៀននៅកម្រិតបឋមសិក្សាមានការកើនឡើងក៏ដោយ ក៏ការសិក្សានៅកម្រិតអនុវិទ្យាល័យ និង វិទ្យាល័យមានអត្រាទាបនៅឡើយ សម្រាប់ចំនួនសិស្សនៅតាមជនបទ និងសិស្សស្រី។

**ក្រាហ្វិកទី៣៖វដ្តវិលវល់នៃភាពក្រីក្រ (The Vicious Circle of Poverty )**




ប្រភព៖ យកតាម Soubbontina, Tatyana P. and Chaterine A. Sheram ( 2000 )

**សម្គាល់៖** ការអប់រំដែលមានកម្រិតទាប នាំឲ្យមានវិសមភាពនៃការបែងចែកឱកាសនៃការអប់រំ គឺអាចជាមូលហេតុចំបងនៃភាពក្រីក្រ និងវិសមភាពសង្គមរយៈពេលវែង។ ការសិក្សាជាច្រើន

បង្ហាញថា គ្រួសារដែលមានកម្រិតការអប់រំទាបមានភាពក្រីក្រ គឺក្រជាងគ្រួសារ ដែលមានការអប់រំកម្រិតខ្ពស់។ ដោយសារពួកគេក្រ ពួកគេទំនងជាមិនវិនិយោគច្រើនលើការអប់រំកូនៗរបស់គេទេ ហើយមួយចំណែកធំនៃចំណូលធំនៃចំណូលដែលអាចចាយបាន គឺចាយលើអាហារូបត្ថម្ភ និងមួយភាគតូចលើការសន្សំ។ ជាលទ្ធផល ពួកគេរកចំណូលបានទាប ចាយច្រើនលើអាហារូបត្ថម្ភសន្សំបានតិច ឬមិនអាចសន្សំប្រាក់បាន និងចាយតិចលើការសិក្សារបស់កូន។ ទាំងនេះគេហៅថា វដ្តវិលវល់នៃភាពក្រីក្រដែលមិនអាចបំបែកបាន លុះត្រាតែមនុស្សគ្រប់រូបទទួលបានឱកាសស្មើៗគ្នាក្នុងការអប់រំ។

ដូច្នេះ ប្រសិនជាមេគ្រួសារមានការអប់រំខ្ពស់ នឹងនាំឲ្យមានប្រាក់ចំណូលខ្ពស់ និងកម្រិតភាពក្រីក្រទាប។ ដោយសារតែចំណូល និងចំណាយជាសន្ទស្សន៍នៃភាពក្រីក្រសំខាន់បំផុតនោះ ការកើនឡើងចំណូល ឬចំណាយ នឹងធ្វើឲ្យស្ថានភាពនៃភាពក្រីក្រធ្លាក់ចុះ។ ការសិក្សាតាមបែបអង្កេតនៅកម្ពុជាបង្ហាញយ៉ាងច្បាស់ថា កម្រិតនៃការអប់រំជួយដល់ការកាត់បន្ថយភាពក្រីក្រ។ការរកឃើញនេះបញ្ជាក់យ៉ាងច្បាស់ថា ការអប់រំដែលមានកម្រិតទាបឬគ្មានការអប់រំ ក៏ជាឬសគល់នៃភាពក្រីក្រផងដែរ។[10]

### ២.២.២ អត្រាប្រជាជនចំណាកស្រុក

### ក.ស្ថានភាពការធ្វើចំណាកស្រុកនៅក្នុងប្រទេសកម្ពុជា

ការធ្វើចំណាកស្រុក គឺជាបញ្ហាសកលដែលត្រូវបានជំរុញដោយសកលភាវូបនីយកម្ម សង្គមនយោបាយ និងការអភិវឌ្ឍខាងសេដ្ឋកិច្ច។ បញ្ហានេះគឺមិនមែនជាបញ្ហាថ្មីសម្រាប់ប្រទេសកម្ពុជាទេ។មុនទសវត្សឆ្នាំ ១៩៩០ ការធ្វើចំណាកស្រុករបស់ប្រជាជនកម្ពុជាគឺជាការគេចចេញពីសង្គ្រាម។ចាប់តាំងពីបាន សន្តិភាពពេញលេញឡើងវិញ ចំនួនប្រជាជនធ្វើចំណាកស្រុកទៅកាន់ប្រទេសដទៃ ដោយសារតែមូលហេតុសេដ្ឋកិច្ចបានកើនឡើង។

ប្រទេសកម្ពុជាមានប្រជាជន ចំនួន១៤,៩លាននាក់ ដែលមានអត្រាកំណើន១,៣ភាគរយ និងកម្លាំងពលកម្មប្រហែល ៧លាននាក់។ ស្ថានភាពប្រជាសាស្ត្រនេះមានន័យថាប្រទេសកម្ពុជាបាននឹងកំពុងព្យាយាមផ្តល់ឱកាសការងារឲ្យបានគ្រប់គ្រាន់សម្រាប់យុវជន និងកំណើនប្រជាជន។ មានការប៉ាន់ប្រមាណថាកម្លាំងពលកម្មវ័យក្មេង ចំនួន៣០០.០០០នាក់ បានចូលក្នុងទីផ្សារការងារនៅក្នុងប្រទេសកម្ពុជាជារៀងរាល់ឆ្នាំ ហើយភាគច្រើននៃពួកគេគ្មានជំនាញឡើយ។

[10] បណ្ឌិត លុជ្ស លីកាណាន់,*មូលហេតុនៃភាពក្រីក្រ&គោលនយោបាយពាក់ពន្ធ័ទីជនបទនៅកម្ពុជា*(វិទ្យាស្ថានសភាកម្ពុជា,២០១៥),២

វិស័យរោងចក្រកាត់ដេរ ដែលជាផ្នែកមួយដ៏សំខាន់សម្រាប់វិស័យឧស្សាហកម្ម បានប្រើប្រាស់កម្លាំងពលកម្មប្រហែល ២៥០.០០០នាក់។ នេះមានន័យថា ភាគច្រើននៃប្រជាជនកម្ពុជាដែលឋិតក្នុងអាយុធ្វើការកំពុងស្ថិតនៅក្នុងវិស័យដ៏ទៃទៀតជាពិសេសក្នុងវិស័យកសិកម្ម។ រាជរដ្ឋាភិបាលបានប្រឈមនឹងបញ្ហាជាច្រើនក្នុងការផ្តល់ឲ្យយុវជនកម្ពុជានូវជំនាញដែលត្រូវការដើម្បីចូលក្នុងទីផ្សារការងារ។ នេះបង្ហាញឲ្យឃើញយ៉ាងច្បាស់ថាការខ្វះខាតជំនាញតាមតម្រូវការក្នុងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានជម្រុញឲ្យប្រជាជនធ្វើចំណាកស្រុកទៅកាន់ប្រទេសដ៏ទៃដើម្បីស្វែងរកការងារធ្វើនៅកន្លែងផ្សេង។

ការធ្វើចំណាកស្រុកនៅក្នុងប្រទេស កើតមានច្រើននៅតាមព្រំដែនកម្ពុជា ថៃ និងវៀតណាម។ ការសិក្សាផ្សេងទៀតបានសង្កត់ធ្ងន់ថាពលករចំណាកស្រុកភាគច្រើនមកពីខេត្តព្រៃវែង ស្វាយរៀង កំពង់ចាម បន្ទាយមានជ័យ និង ខេត្តពោធិសាត់។ដោយមានការថយចុះអត្រាកំណើត សេដ្ឋកិច្ចរឹងមាំ និងតម្រូវការកម្លាំពលកម្ម ប្រទេសថៃគឺជាគោលដៅទាក់ទាញបំផុតសម្រាប់ការធ្វើចំណាកស្រុកឆ្លងដែនសម្រាប់យុវជនកម្ពុជា។ យោងតាមស្ថិតិដែលផ្តល់ដោយក្រសួងការងារនៅចុងឆ្នាំ២០១៦ ចំនួនសរុបនៃពលករចំណាកស្រុក នៅក្នុងប្រទេសថៃឈានដល់ចំនួន១.០៥៦៣៥៨នាក់(៣១០.០០០ជនចំណាកស្រុកគ្មានឯកសារ )។ ប្រទេសកូរ៉េខាងត្បូងបានក្លាយជាគោលដៅទីពីរសម្រាប់ការធ្វើចំណាកស្រុករបស់ប្រជាជនកម្ពុជាដោយសារតែប្រាក់ឈ្នួលមានតម្លៃខ្ពស់ជាង។ បច្ចុប្បន្ននេះពលករចំនួន ៤៥.២៣០ នាក់កំពុងធ្វើការនៅក្នុងប្រទេសនេះ។ ចំនួនពលករចំណាកស្រុកកម្ពុជានៅប្រទេសម៉ាឡេស៊ីមាន ចំនួន១,៧៧៦នាក់ ក្នុងឆ្នាំ ២០០៥ ហើយកើនឡើង ចំនួន១០ដង ក្នុងរយៈពេល៥ឆ្នាំ និងនៅឆ្នាំ២០១៦ សមាមាត្រស្ថិតនៅចំនួន ៩៦.៥៩១ នាក់។មានការប៉ានប្រមាណថាមានពលករចំណាកស្រុកកម្ពុជា ចំនួន ៣.៨៩៧ នាក់ បានធ្វើការនៅក្នុងប្រទេសជប៉ុន និងរាប់រយនាក់នៅក្នុងប្រទេសសិង្ហបុរី។

ក្នុងទសវត្សរ៍កន្លងមក ភាគច្រើននៃអ្នកទាំងនោះធ្វើចំណាកស្រុកទៅប្រទេសថៃ គឺជាជនចំណាកស្រុក " មិនទៀងទាត់ " ។ ការធ្វើចំណាកស្រុកមិនទៀងទាត់អាចត្រូវបានកំណត់ថាជា " ចលនាខុសច្បាប់ដើម្បីធ្វើការនៅក្នុងប្រទេសផ្សេងទៀតដោយពុំមានការអនុញ្ញាត "។ ការសិក្សាដូចគ្នានេះបានគូសបញ្ជាក់ពីភាពខុសគ្នាយ៉ាងខ្លាំងនៅក្នុងស្ថានភាពសង្គមសេដ្ឋកិច្ចរវាងអ្នកធ្វើចំណាកស្រុកទៀងទាត់ និង មិនទៀងទាត់។ ឧទាហរណ៍ អ្នកធ្វើចំណាកស្រុកមិនទៀងទាត់ច្រើនតែទៅធ្វើការងារដែលគ្មានជំនាញ មានការអប់រំទាប ការចំណាយលើការប្រើប្រាស់ និងទ្រព្យ

សម្បត្តិ។ អ្នកធ្វើការចំណាកស្រុកមិនទៀងទាត់ឬដោយខុសច្បាប់ ត្រូវបានគេរកឃើញថាមានភាពងាយរងគ្រោះជាងអ្នកដែលធ្វើចំណាកស្រុកដោយស្រប ច្បាប់។[11]

### ២.២.២.១ មូលហេតុដែលបណ្តាលអោយប្រជាជនចំណាកស្រុក

មូលហេតុនៃការធ្វើចំណាកស្រុកត្រូវបានបូកបញ្ចូលគ្នារវាងកត្តា " ទាក់ទាញ " និង កត្តា " ជំរុញ " ។កត្តាជំរុញត្រូវបានគេយល់ថា វាពាក់ពន្ធ័នឹងលក្ខខ័ណ្ឌដែលជំរុញឲ្យមានការសម្រេចចិត្តធ្វើចំណាកស្រុកទៅប្រទេសផ្សេងដើម្បីស្វែងរកជីវភាពប្រសើរជាងមុន។ ទាំងនេះរួមមានកង្វះឱកាសការងារ សេវាកម្ម សង្គមទន់ខ្សោយ វិបត្តិគ្រួសារ ឬ វិបត្តិតំណាលគ្នាដទៃ និង ភាពក្រីក្រ។ កត្តាទាក់ទាញ សំដៅទៅលើលក្ខខណ្ឌដែលទាក់ទាញមនុស្សពីកន្លែងផ្សេងមករស់នៅក្នុងគោលបំណងលើកកម្ពស់ជីវភាពរស់នៅកាន់តែប្រសើរឡើង។កត្តាទាំងនោះរួមមានឱកាសការងារ សម្បូរធនធានធម្មជាតិ សេវាកម្មសង្គមល្អ សន្តិភាព និងស្ថេរភាព។ នៅប្រទេសកម្ពុជាការរួមផ្សំនៃកត្តាទាំងពីរបានធ្វើអោយមានការធ្វើចំណាកស្រុក។

ការគេចចេញពីភាពក្រីក្រដើម្បីស្វែងរកជីវភាពល្អប្រសើរ និង ប្រាក់ចំណូលខ្ពស់គឺជាហេតុផលមូលដ្ឋានសម្រាប់ការធ្វើចំណាកស្រុក។ ការសិក្សាជាច្រើនដែលតាមដានលើបញ្ហាការធ្វើចំណាកស្រុកនៅប្រទេសកម្ពុជាបញ្ជាក់ថា កត្តាជំរុញសំខាន់បំផុតសម្រាប់ការធ្វើចំណាកស្រុកក្នុងប្រទេសកម្ពុជាគឺកង្វះការងារនៅក្នុងសហគមន៍ និងប្រាក់ឈ្នួលទាប។ របកគំហើញនេះទទួលបានពី របាយការណ៍ដែលបានមកពីការធ្វើបទសម្ភាសន៍ជាង៧០%នៃជនចំណាកស្រុកដែលបានត្រឡប់មកវិញ។ ប្រាក់ឈ្នួលអប្បបរមាដែលបានរាយការណ៍នៅក្នុងប្រទេសកម្ពុជាមានតម្លៃចន្លោះពី ២,៥ដុល្លារ ដល់ ៨ ដុល្លារក្នុងមួយថ្ងៃ។ នៅក្នុងប្រទេសថៃ ប្រាក់ឈ្នួលអប្បរមាមានតម្លៃប្រមាណជា ៣០០បាត ( ប្រហែល១០ដុល្លារ )ហើយវាជាកត្តាមួយក្នុងចំនោមកត្តាសំខាន់ៗដែលទាក់ទាញការធ្វើចំណាកស្រុក។

ការសិក្សាជាច្រើនបានរកឃើញថា ការជាប់បំណុលក៏ជាមូលហេតុមួយជម្រុញឲ្យប្រជាជនធ្វើចំណាកស្រុកដែរ។ភាពកង្វះជំនាញដែលធ្វើឲ្យមនុស្សពិបាកក្នុងការរកការងារធ្វើនៅក្នុងប្រទេសបានជំរុញឲ្យពួកគេធ្វើចំណាកស្រុកដើម្បីធ្វើការងារជាបណ្តោះអាសន្ន ឬយូរអង្វែងនៅប្រទេសថៃ។ កង្វះដីដែលអំណោយផលក៏ជាកត្តាជំរុញដ៏សំខាន់មួយដែលជំរុញឲ្យប្រជាជនចាកចេញពីសហគមន៍របស់ពួកគេ និងចំណាកស្រុកទៅធ្វើការនៅកន្លែងផ្សេងទៀត។ស្ថានភាពនេះ

---

[11] រស់ បណ្តែត និង កឹម សុធន ,*ការធ្វើចំណាកស្រុក ការទប់ស្កាត់ការជួញដូរមនុស្ស&ការធ្វើអាជីវកម្មផ្លូវភេទ(វិទ្យាស្ថានសភាកម្ពុជា,២០១៧)*,១

ឆ្លុះបញ្ចាំងពីការកើនឡើងនៃចំនួនអ្នកគ្មានដីធ្លីក្នុងចំណោមអ្នកក្រីក្រនៅជនបទ។ ការសិក្សាផ្សេងទៀតបង្ហាញពីមូលហេតុដែលពាក់ពន្ធ័ ការខូចខាតផលដំណាំ ដែលជំរុញឲ្យប្រជាជន ផ្លាស់ទីលំនៅចេញពីសហគមន៍។

ជនចំណាកស្រុកខ្លះបានជ្រើសរើសយកការធ្វើចំណាកស្រុកដោយខុសច្បាប់ ឬដោយគ្មានឯកសារ ជាពិសេសទៅប្រទេសជិតខាងដូចជា ប្រទេសថៃ ដោយសារតែការចំណាយខ្ពស់ និងការដាក់ពាក្យសុំឯកសារ (ជាពិសេសលិខិតឆ្លងដែន ) មានរយៈពេលយូរៗ ។ ការធ្វើចំណាកស្រុកទៅប្រទេសថៃស្របច្បាប់មានតម្លៃប្រហែល ៧៤៧ដុល្លារ ដែលមានអត្រាខ្ពស់ជាង ៥ដងបើប្រៀបធៀបទៅនឹងការធ្វើចំណាកស្រុកដោយខុសច្បាប់ហើយ ក្នុងករណីភាគច្រើនអ្នកធ្វើចំណាកស្រុកត្រូវខ្ចីបុលដើម្បីចំណាយ ។ កម្រិតអប់រំមិនមានជាប់ទាក់ទងទៅនឹងការសម្រេចចិត្តជ្រើសរើសការធ្វើចំណាកស្រុកដែលមានសុវត្ថិភាពនោះទេ។[12]

## ២.៣. ប្រព័ន្ធសុខភាព និង ប្រព័ន្ធនៃការអប់រំរបស់ប្រជាជនកម្ពុជា

### ២.៣.១ សុខភាព

#### ២.៣.១.១ អត្រាកើត

ការកើត ( ឬកំណើត)ជាកត្តាឌីណាមិកប្រជាសាស្ត្រមួយ ដែលនាំឲ្យមានកំណើនប្រជាជន។កាលណាប្រជាជនមួយមានកំណើតទារកច្រើនក្នុងពេលដ៏ខ្លី ប្រជាជននោះនឹងទទួលរងបាតុភូតប្រជាសាស្ត្រមួយ ហៅថា **បន្ទុះទារក**។ ឧទាហរណ៍ បន្ទុះទារកនៅកម្ពុជាក្រោយរបប ប៉ុល ពត។

កំណើតទារកអាចជា កំណើតរស់ ( Live birth ) ឬ កំណើតស្លាប់ ( Still birth )។ សូចនាករដែលគេនិយមប្រើ ដើម្បីវាស់វែងពីកំណើតនៃប្រជាជនមួយ មាន៖

១. អត្រាកំណើតដុល ( Crude Birth Rate, CBR )៖ ជាចំនួនកំណើតរស់ក្នុងចំណោមប្រជាជនទូទៅ ១០០០នាក់ ក្នុងឆ្នាំណាមួយ។ នៅឆ្នាំ២០១៣ អត្រាកំណើតដុលរបស់កម្ពុជាស្មើនឹង ១៧,៨នាក់ (១៥,៩នាក់នៅទីប្រជុំជន និង ១៨,៣៣១នាក់ នៅជនបទ)។[13]

#### ២.៣.១.២ អត្រាមរណភាព

ការលើកកម្ពស់សុខភាពរបស់ប្រជាជនក៏ទទួលបានវឌ្ឍនភាពគួរឲ្យកត់សម្គាល់។

[12] រស់ បណ្ដេត និង កឹម សុធន ,*ការធ្វើចំណាកស្រុក ការទប់ស្កាត់ការជួញដូរមនុស្ស&ការធ្វើអាជីវកម្មផ្លូវភេទ(វិទ្យាស្ថានសភាកម្ពុជា,២០១៧)*,៣

[13] សៀវភៅណែនាំសម្រាប់បណ្ដុះបណ្ដាលស្ដីពីគោលនយោបាយប្រជាជននិងប្រជាសាស្ត្រម៉ូឌុល១,៦

អត្រាមរណភាពមាតាថយចុះពី ២០៦នៅឆ្នាំ២០១៣ មកនៅត្រឹម ១៤០ នៅឆ្នាំ២០១៥ ក្នុងកំណើតទារក(១០០ ០០០) នាក់។ រីឯ អត្រាមរណភាពទារកក៏ថយចុះផងដែរពី ២៧ នៅឆ្នាំ ២០១៣ មកនៅត្រឹម ២២ នៅឆ្នាំ២០១៥ ក្នុងកំណើតទារក ១ ០០០នាក់។[14]

**រូបភាពទី៤ ៖ អត្រាមរណភាពមាតា និង ទារក**




ប្រភព៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ២០១៤-២០១៨

## ២.៣.១.៣ អត្រាចំនួនលទ្ធភាពមានកូន និង អត្រាអាពាហ៍ពិពាហ៍

### ក.អត្រាចំនួនលទ្ធភាពមានកូន

ការថយចុះអត្រាមានកូន ធ្វើឲ្យមានការថយចុះចំនួនកុមារដែលបានកើត ហើយជាលទ្ធផល ក៏ធ្វើឲ្យអត្រាកំណើនប្រជាជនជាកុមារមានការថយចុះផងដែរ។ អាយុកាលមធ្យមសង្ឃឹមរស់មានភាពប្រសើរឡើង មានន័យថា មនុស្សអាចរស់បានអាយុកាន់តែវែង ហើយការកើនឡើងនៃសមាមាត្រប្រជាជនដែលអាចរស់នៅរហូតដល់វ័យចាស់ និងបន្តរស់នៅក្នុងរយៈពេលកាន់តែវែងជាងមុនក្រោយពីបានឈានដល់អាយុ៦០ឆ្នាំហើយ។ ហេតុនេះប្រជាជនវ័យចាស់នឹងកើនឡើងក្នុងអត្រាលឿនជាងប្រជាជនវ័យក្មេង។ លទ្ធភាពកាន់តែច្រើនក្នុងការទទួលបានសេវាសុខភាពបន្តពូជដោយគុណភាព បានធ្វើឲ្យលទ្ធភាពមានកូន មានការថយចុះគួរឲ្យកត់សម្គាល់ និងជាបន្តបន្ទាប់ ក្នុងរយៈពេលបីទសវត្សរ៍ចុងក្រោយនេះ។ ដូចបានបង្ហាញនៅក្នុងរូបភាពខាងក្រោម អត្រាលទ្ធភាពមានកូនសរុប ដែលត្រូវបានឲ្យនិយមន័យថាជាចំនួនមធ្យមនៃកូនដែលបានកើតជាមួយស្ត្រីម្នាក់ក្នុងអំឡុងអាយុអាចមានកូន ( ១៥-៤៩ឆ្នាំ ) បានថយចុះពី ៥,៧% នៅឆ្នាំ១៩៩០ មកនៅត្រឹម ២,៧% នៅឆ្នាំ ២០១០ ហើយតួលេខនេះត្រូវបានព្យាករណ៍ថានឹងថយចុះមកនៅ

[14] ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥,៤

ត្រឹមកម្រិតជំនួសក្នុងឆ្នាំ ២០២៥ រួចហើយចំនួននេះនឹងបន្តថយចុះតិចតួចជាបណ្តើរៗថែមទៀត។[15]

**រូបភាពទី៥ ៖ ការព្យាករណ៍អំពីលទ្ធភាពមានកូនសរុប(១៩៩០ - ២០៣០)**




ប្រភព៖ ការព្យាករណ៍ចំនួនប្រជាជនកម្ពុជា៖ របាយការណ៍លេខ១២ នៃជំរឿនទូទៅនូវប្រជារាស្ត្រកម្ពុជាឆ្នាំ២០០៨

អត្រាលទ្ធភាពមានកូនដែលបានរៀបអាពាហ៍ពិពាហ៍អាយុវ័យក្មេង មានប្រេវ៉ាឡង់ខ្ពស់ក្នុងតំបន់ជនបទ បើធៀបនឹងតំបន់ទីប្រជុំជន។ អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ( NIS 2014 ) បានរកឃើញថាអត្រាលទ្ធភាពមានកូនអាយុជាក់លាក់ ( ASFR ) សម្រាប់ស្ត្រីវ័យក្មេងអាយុ ១៥-១៩ឆ្នាំ មាន ៥៧ នាក់ ក្នុងចំណោម ១០០នាក់ ក្នុងឆ្នាំ ២០១៤ និង សម្រាប់អាយុ ២០-២៤ ឆ្នាំ មាន ១៦២ នាក់ ក្នុងចំណោម ១០០០នាក់។ យោងតាមការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ( NIS 2014 )ប្រមាណជា ១ ក្នុងចំណោម ៨ ( ១២ភាគរយ ) នៃស្ត្រីវ័យក្មេងអាយុ ១៥-១៩ឆ្នាំ បានក្លាយជាម្តាយ ឬបច្ចុប្បន្នមានផ្ទៃពោះកូនដំបូងនៅពេលអង្កេត។ ភាគរយស្ត្រីវ័យក្មេងអាយុ ១៥-១៩ឆ្នាំ ដែលចាប់ផ្តើមបង្កើតកូនបានកើនឡើងតិចតួចលទ្ធភាពមានកូនក្នុងវ័យជំទង់ពេលថ្មីៗនេះនៅកម្ពុជា។

**ខ.អត្រាអាយុរៀបអាពាហ៍ពិពាហ៍**

ក្នុងចំណោមយុវវ័យអាយុ ១៥-២៤ឆ្នាំ បច្ចុប្បន្នអត្រាធ្លាប់រៀបអាពាហ៍ពិពាហ៍បានកើន

[15] គោលនយោបាយជាតិស្តីពីមនុស្សចាស់ ២០១៧-២០៣០,៤

ឡើង សម្រាប់ស្ត្រី មាន២៥.៨% ក្នុងឆ្នាំ ២០០០ និង ៣៨.៧% ក្នុងឆ្នាំ ២០១៤។ សម្រាប់បុរសក៏មានអត្រាកើនឡើងផងដែរពី ១៦.៥% ក្នុងឆ្នាំ ២០០៥ ទៅ ១៩.០% ក្នុងឆ្នាំ ២០១៤។ សម្រាប់ស្ត្រីវ័យក្មេងអាយុ ១៥-២៤ឆ្នាំ បច្ចុប្បន្នធ្លាប់រៀបអាពាហ៍ពិពាហ៍បន្តនៅរក្សាចន្លោះពី ៤-៦% ទាំងបួនអង្កេត។ ក្នុងចំណោមយុវវ័យអាយុ ១៨-១៩ឆ្នាំ មានតែមួយភាគប្រាំប៉ុណ្ណោះដែលបច្ចុប្បន្នធ្លាប់រៀបអាពាហ៍ពិពាហ៍ក្នុងឆ្នាំ ២០០០ និងឆ្នាំ ២០១០ ប៉ុន្តែសមាមាត្រនេះបានកើនឡើងជាងសាមសិបភាគរយ (៣០.៦%) ក្នុងឆ្នាំ២០១៤។ ស្រដៀងគ្នាដែរស្ត្រីវ័យក្មេងក្នុងក្រុមអាយុ ២០-២៤ ឆ្នាំ ភាគរយបច្ចុប្បន្នធ្លាប់រៀបអាពាហ៍ពិពាហ៍បានកើនឡើងពី ៥០.៩% ក្នុងឆ្នាំ ២០០០ ទៅ ៦០.៨% ក្នុងឆ្នាំ២០១៤។ ក្នុងចំណោមស្ត្រីអាយុ ១៥-២៤ឆ្នាំ មានតែ ២% ដែលបានរៀបអាពាហ៍ពិពាហ៍ពី មុន។

មានការកើនឡើង អត្រាភាគរយតិចតួចនៃបុរសបច្ចុប្បន្នធ្លាប់រៀបអាពាហ៍ពិពាហ៍ទាំងបួនអង្កេតយ៉ាងណាក្តីក៏មានការប្រែប្រួលគួរសមពី ១៦.៥% ក្នុងឆ្នាំ២០០៥ ទៅ ១៩.០% ក្នុងឆ្នាំ២០១៤។ សម្រាប់ស្ត្រីមានតែក្រោម ២% ប៉ុណ្ណោះនៃបុរសវ័យក្មេងអាយុ ១៥-២៤ឆ្នាំ ដែលធ្លាប់បានរៀបអាពាហ៍ពិពាហ៍ពីមុន។[16]

**តារាងទី៣៖ ស្ថានភាពអាពាហ៍ពិពាហ៍**

ភាគរយស្ត្រី បុរសវ័យក្មេង និង យុវជន អាយុ ១៥-២៤ឆ្នាំតាមស្ថានភាពអាពាហ៍ពិពាហ៍បច្ចុប្បន្ន និងឆ្នាំអង្កេតកម្ពុជា DHS ២០០៥-២០១៤

| ចរិតលក្ខណៈអង្កេត | 2000 | | | | 2005 | | | | 2010 | | | | 2014 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ស្ថានភាពអាពាហ៍ពិពាហ៍ | 15-17 | 18-19 | 20-24 | 15-24 | 15-17 | 18-19 | 20-24 | 15-24 | 15-17 | 18-19 | 20-24 | 15-24 | 15-17 | 18-19 | 20-24 | 15-24 |
| **ស្ត្រី** | | | | | | | | | | | | | | | | |
| មិនដែលរៀបការ | 94.1 | 75.4 | 44.5 | 72.0 | 95.9 | 77.3 | 40.8 | 67.0 | 95.5 | 77.8 | 43.1 | 68.0 | 93.5 | 67.6 | 35.8 | 59.1 |
| បច្ចុប្បន្នរៀបការរួច | 5.8 | 22.6 | 50.9 | 25.8 | 4.0 | 20.8 | 54.9 | 30.6 | 4.1 | 21.0 | 53.2 | 29.9 | 6.1 | 30.6 | 60.8 | 38.7 |
| រៀបការពីមុន | 0.1 | 2.0 | 4.6 | 2.2 | 0.1 | 1.9 | 4.3 | 2.4 | 0.4 | 1.2 | 3.7 | 2.1 | 0.4 | 1.8 | 3.4 | 2.2 |
| **បុរស** | | | | | | | | | | | | | | | | |
| មិនដែលរៀបការ | | | | | 99.7 | 94.4 | 60.5 | 82.1 | 99.4 | 95.5 | 66.8 | 84.6 | 98.8 | 93.5 | 59.4 | 79.1 |
| បច្ចុប្បន្នរៀបការរួច | | | | | 0.3 | 4.2 | 36.7 | 16.5 | 0.6 | 3.4 | 30.2 | 13.9 | 1.1 | 6.2 | 36.9 | 19.0 |
| រៀបការពីមុន | | | | | 0.0 | 1.4 | 2.8 | 1.4 | 0.0 | 1.1 | 3.0 | 1.5 | 0.1 | 0.4 | 3.7 | 1.9 |

[16] របាយការណ៍វិភាគស៊ីជម្រៅស្តីពីសុខភាពបន្តពូជ&សិទ្ធទទួលបានសេវាសុខភាពយុវវ័យកម្ពុជា,ភ្នំពេញ,២០១៦,៥១

### ២.៣.២ ការអប់រំ

#### ២.៣.២.១ អត្រាអក្ខរជន

អត្រាអក្ខរជនបែងចែកជាពីរ គឺអាយុពី១៥ ដល់ ២៤ឆ្នាំ និង អាយុពី ១៥ ដល់ ៤៥ឆ្នាំ ។អត្រាអក្ខរជននៅឆ្នាំ២០១៣ ដល់ ២០១៨ អាយុពី ១៥ ដល់ ២៤ឆ្នាំ មានការកើនឡើងពី៩១,៥% ដល់ ៩៦,៥%។ រីឯ អាយុពី ១៥ ដល់ ៤៥ឆ្នាំ នៅឆ្នាំ ២០១៤ ដល់ ២០១៨ ក៏មានការកើនឡើងផងដែរ គឺកើនឡើង ពី ៨៧,៧% រហូតដល់ ៩០,៥% ។

**តារាងទី៤៖ អត្រាអក្ខរជននៅឆ្នាំ ២០១៣ ដល់ ២០១៨**

| សូចនាករសំខាន់ៗ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ចំនួនវិទ្យាល័យបច្ចេកទេស | ចំនួន | ៤ | ៤ | ៥ | ៥ | ៦ | ៧ |
| ចំនួនសិស្សនៅមធ្យមសិក្សាបច្ចេកទេស | ចំនួន | ៧៣០ | ៩៨៤ | ១ ២៣៨ | ១ ៤៩២ | ១ ៧៤៦ | ២ ០០០ |
| អត្រាអក្ខរជន(១៥-២៤ ឆ្នាំ) | % | ៩១,៥ | ៩២,៥ | ៩៣,៥ | ៩៤,៥ | ៩៥,៥ | ៩៦,៥ |
| អត្រាអក្ខរជន(១៥-៤៥ឆ្នាំ) | % | | ៨៧,៧ | ៨៨,៤ | ៨៩,១ | ៨៩,៨ | ៩០,៥ |

ប្រភព៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨

#### ២.៣.២.២ អត្រាចូលរៀន

**ក.ទិដ្ឋភាពទូទៅ និង ការអភិវឌ្ឍនភាពនៃការអប់រំមូលដ្ឋាន**

ដើម្បីកែលម្អវិស័យអប់រំ ទាំងគុណភាព និងបរិមាណ រដ្ឋាភិបាលបានអនុវត្តគោលនយោបាយមួយចំនួនដូចជាកម្មវិធីទ្រទ្រង់វស័យអប់រំ ឆ្នាំ២០០១-២០០៥ ផែនការជាតិដើម្បីការអប់រំសម្រាប់ទាំងអស់គ្នា ឆ្នាំ២០០៣-២០១៥ ផែនការយុទ្ធសាស្ត្រជាតិវិស័យអប់រំ ឆ្នាំ២០០៦-២០១០ ផែនការយុទ្ធសាស្ត្រជាតិវិស័យអប់រំឆ្នាំ២០០៩-២០១៣ និង ផែនការយុទ្ធសាស្ត្រជាតិវិស័យអប់រំឆ្នាំ២០១៤-២០១៨ ដោយមានភ្ជាប់ទំនាក់ទំនងទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។[17]

[17] ធន ប៉ូល និង គឹម កែវធីតា ,*បញ្ហាប្រឈមក្នុងការអប់រំថ្នាក់មូលដ្ឋាននៅខេត្តព្រះវិហារ ឧត្តរមានជ័យ&បន្ទាយមានជ័យ*(វិទ្យាស្ថានសភាកម្ពុជា,២០១៧),១

**តារាងទី៥៖ សូចនាករទាក់ទងនឹងការអប់រំបឋមសិក្សា(ថ្នាក់ជាតិ)**

| សូចនាករ | ២០០០-២០០១ | ២០១២-២០១៣ | ២០១៣-២០១៤ | ២០១៤-២០១៥ | ២០១៥-២០១៦ | ២០១៦-២០១៧ |
|---|---|---|---|---|---|---|
| អត្រាពិតចូលរៀនថ្មី | ៧៦,៤០ | ៩៤,៣០ | ៩៨,១០ | ៩៤,៥០ | ៩៥,៩០ | ៩៥,១០ |
| អត្រាពិតនៃការសិក្សា | ៨៣,៨០ | ៩៧,០០ | ៩៨,២០ | ៩៧,៩០ | ៩៨,៤០ | ៩៧,៧០ |
| អត្រាបោះបង់ការសិក្សា | - | ១០,៥០ | ៨,៣០ | ៦,២០ | ៤,១០ | - |
| អត្រាបញ្ចប់ការសិក្សា | ៤៦,៨០ (២០០៤-២០០៥) | ៨៧,៣៥ | ៨៨,៩៤ | ៨៤,១០ | ៨០,៦០ | ៧៩,៩០ |
| អត្រាត្រួតថ្នាក់ | ៤២,៩០ (២០០៥-២០០៦) | ៤,៨០ | ៥,១០ | ៦,៧០ | ៦,៦០ | - |
| អត្រាឆ្លងភូមិសិក្សា | ៨២,៦០ | ៧៦,៨០ | ៧៦,៨០ | ៧៨,៧០ | ៨២,១០ | ៨៥,៥០ |

ប្រភព៖ ស្ថិតិ និងសូចនាករអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា

តារាងនេះបង្ហាញថា កម្ពុជាមានវឌ្ឍនភាពដ៏ធំធេងក្នុងការអប់រំបឋមសិក្សា។អត្រាពិតចូលរៀនថ្មីបានកើនឡើងជាលំដាប់ពី ៨៣,៨០% នៅឆ្នាំ ២០០០ ដល់ ៩៧,៧០% នៅឆ្នាំ ២០១៦។ នេះមានន័យថា កុមារអាយុ៦ឆ្នាំ ស្ទើរតែទាំងអស់ ត្រូវបានចុះឈ្មោះចូលរៀនថ្នាក់ទី១។ កុមារអាយុពី ៦ឆ្នាំ ដល់១១ឆ្នាំ ស្ទើរតែទាំងអស់ ត្រូវបានចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា ។ សូចនករផ្សេងទៀតក៏មានលក្ខណៈវិជ្ជមានដែរ។ អត្រាបញ្ចប់ការសិក្សា មានស្ថេរភាព និង អត្រាឆ្លងភូមិសិក្សាបានបន្តកើនឡើងពី ៨២,១០ភាគរយ នៅឆ្នាំ ២០១៥-២០១៦ ដល់ ៨៥,៥% នៅឆ្នាំបន្ទាប់។នេះមានន័យថា សិស្សតិចជាង១៥% មិនបានឆ្លងទៅរៀននៅមធ្យមសិក្សាបឋមភូមិទេ។

**តារាងទី៦ ៖ សូចនាករទាក់ទងនឹងមធ្យមសិក្សាបឋមភូមិ(ថ្នាក់ជាតិ)**

| សូចនាករ | ២០០០-២០០១ | ២០១២-២០១៣ | ២០១៣-២០១៤ | ២០១៤-២០១៥ | ២០១៥-២០១៦ |
|---|---|---|---|---|---|
| អត្រារួមនៃការសិក្សា | - | - | - | ៥៥,១០ | ៦៥,៥០ |
| អត្រាឡើងថ្នាក់ | - | ៧៧,៤០ | ៧៧,២០ | ៧៨,៦០ | ៨០,៦០ |
| អត្រាត្រួតថ្នាក់ | - | ១,៤០ | ១,៨០ | ២,២០ | ២,៥០ |
| អត្រាបោះបង់ការសិក្សា | - | ២១,២០ | ២១,០០ | ១៩,២០ | ១៧,០០ |
| អត្រាឆ្លងភូមិសិក្សា | ៦៣,០០ | ៦៩,១០ | ៧១,១០ | ៧២,៩០ | ៧៦,៦០ |

ប្រភព៖ ស្ថិតិ និងសូចនាករអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា

បើយោងតាមតារាង ខាងលើ មានវឌ្ឍនភាពនៃការអប់រំថ្នាក់មធ្យមសិក្សាបឋមភូមិ មានកម្រិតទាបជាងវឌ្ឍនភាពនៃការអប់រំថ្នាក់បឋមសិក្សា ។ អត្រាឡើងថ្នាក់ និង អត្រាឆ្លងភូមិសិក្សាគឺ ៨០,៦០ ភាគរយ និង ៧៦,៦០ ភាគរយ ដែលមានន័យថា ប្រហែល ២៣,៤០ភាគរយ នៃសិស្សមធ្យមសិក្សាបឋមភូមិ មិនបានឆ្លងទៅសិក្សានៅវិទ្យាល័យ ។ អត្រាបោះបង់ការសិក្សានៅមានកម្រិតខ្ពស់ ( ១៧% )ហើយអត្រាឡើងថ្នាក់បានបន្តកើនឡើង ប៉ុន្តែនៅត្រឹម ៨០,៦០ភាគរយ នៅ

ឆ្នាំសិក្សា ២០១៥-២០១៦ ។នេះមានន័យថា សិស្សមធ្យមសិក្សាបឋមភូមិបានឡើងថ្នាក់នៅឆ្នាំបន្ទាប់អត្រាឆ្លងភូមិសិក្សានៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិគឺ ៨៥,៥០ ភាគរយ និង ៧៦,៦០ភាគរយ។ អត្រានេះ រួមនឹងអត្រាបោះបង់ការសិក្សាខ្ពស់ មានន័យថា មានកុមារមួយចំនួនមិនបានឆ្លងទៅរៀននៅវិទ្យាល័យទេ។

កម្រិតថ្នាក់ជាតិ កម្ពុជាបានសម្រេចនូវវឌ្ឍនភាពគួរឲ្យកត់សម្គាល់ទាក់ទងនឹងសូចនាករខាងលើ។ លើសពីនេះទៀត ចំនួនសាលាបឋមសិក្សា និង សាលាមធ្យមសិក្សាបឋមភូមិបានកើនឡើង ពី ៥.៨៣៥ ក្នុងឆ្នាំ២០០០ ដល់ ៨.៣៣៦ នៅឆ្នាំ ២០១៥។ ចំនួនសិស្ស និងគ្រូបង្រៀន ក៏បានកើនឡើង។ក្រៅពីគោលនយោបាយដែលបានលើកឡើងខាងលើ មានគោលនយោបាយផ្សេងទៀតត្រូវបានរៀបចំឡើង និងអនុវត្តដូចជា កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន ការកែលម្អកម្មវិធីសិក្សា គោលនយោបាយសាលាកុមារមេត្រី។[18]

## ២.៤ កំលាំងពលកម្ម

### ២.៤.១ អត្រាចូលរួមកំលាំងពលកម្ម

ភាគលាភប្រជាសាស្ត្ររបស់ប្រទេសកម្ពុជាត្រូវបានជួយជំរុញកំណើនសេដ្ឋកិច្ច និងប្រាក់ចំណូលសម្រាប់ប្រជាជនម្នាក់។ នេះគឺជាលទ្ធផលនៃកម្លាំងពលកម្មកើនឡើងលឿនជាងចំនួនប្រជាជនដែលពឹងផ្អែកក្នុងបន្ទុក ដែលជាធនធានបន្ថែមសម្រាប់នៃការវិនិយោគ។ប្រជាជនក្នុងអាយុធ្វើការរបស់កម្ពុជា( ១៥-៦៤ឆ្នាំ ) បានកើនឡើង៖ ជាមធ្យមប្រជាជនប្រមាណ ១៦២ ០០០ បន្ថែមទៀតក្នុងមួយឆ្នាំក្លាយទៅជាកម្លាំងពលកម្ម។ចំណែកនៃវិស័យកសិកម្មក្នុងការងារសរុប បានធ្លាក់ចុះពី ៥៧,៦% ក្នុងឆ្នាំ ២០០៩ ដល់ ៤៥,៣% នៅឆ្នាំ ២០១៤ គឺទាបជាងការព្យាករ ក្នុង ផ.យ.អ.ជ. ៥៧% នៅឆ្នាំ២០១៨ ។ អំឡុងពេលដូចគ្នានេះដែរចំណែកនៃការងារក្នុងវិស័យឧស្សាហកម្ម និងសេវាកម្មបានកើនឡើង ២៤,៣% និង ៣០,៤% ។ ចំណែកវិស័យឧស្សាហកម្មវិញ កើនខ្ពស់ជាងការព្យាករក្នុង ផ.យ.អ.ជ. ដែលកំណត់ ១៣% សម្រាប់ឆ្នាំ២០១៨ ។ ចំណែកនៃការងារនៅក្នុងវិស័យសេវាកម្ម គឺស្របតាមការព្យាករក្នុង ផ.យ.អ.ជ.សម្រាប់ឆ្នាំ២០១៨។ ការផ្លាស់ប្តូរចំណែកវិស័យការងារនេះអាចឆ្លុះបញ្ចាំងពីការកែតម្រូវចនាសម្ពន្ធ័ខាងលើ។ និន្នាការនេះអាចនឹងបន្ត ក្នុងការផលិតភាព និង ប្រាក់ឈ្នួលខ្ពស់ជាងនៅទីប្រជុំជនដែលជាការទាក់ទាញជនចំណាកស្រុកពីតំបន់ជនបទ។នៅក្នុងពេលយូរអង្វែង បង្កើនផលិតភាពនៃកម្លាំងពលកម្មគឺ

[18] ធន ប៉ូល និង គីម កែវធីតា ,*បញ្ហាប្រឈមក្នុងការអប់រំថ្នាក់មូលដ្ឋាននៅខេត្តព្រះវិហារ ឧត្តរមានជ័យ&បន្ទាយមានជ័យ*(វិទ្យាស្ថានសភាកម្ពុជា,២០១៧),២

អាស្រ័យលើការពង្រឹងសមត្ថភាពរបស់ប្រជាជនកម្ពុជាក្នុងការពង្រឹង ការអភិវឌ្ឍធនធានមនុស្ស និងការលើកកម្ពស់ការវិនិយោគលើសេដ្ឋកិច្ចចម្រុះ។[19]

### ២.៤.២ អត្រាអនិកម្មភាព និង និកម្មភាព

ចំពោះការចូលរួមកម្លាំងពលកម្មរបស់ប្រជាជន ជំរឿនទូទៅប្រជារាស្ត្រឆ្នាំ ២០០៨ បង្ហាញថា ៤ភាគ៥ នៃប្រជាជនដែលមានអាយុ១៥-៦៤ឆ្នាំបានចាត់ទុកខ្លួនឯងថាមានការងារធ្វើ(៨២% ក្នុងចំណោមបុរស និង ៧៩%ក្នុងចំណោមស្ត្រី )។ នៅក្នុងឆ្នាំ ២០១៣ភាគរយនេះបានកើនឡើង៣% ចំពោះបុរស ប៉ុន្តែគ្មានការកើនឡើងចំពោះស្ត្រី។

ដោយឡែក គ.ន.ជ.ប. ២០១៦-២០៣០ មិនបាននិយាយពីអត្រានិកម្មភាព(អ្នកគ្មានការងារធ្វើ)ទេ។តាមរបាយការណ៍ឆ្នាំ២០១៣ ភាគរយនៃអ្នកគ្មានការងារធ្វើ៖

- ក្នុងចំណោមប្រជាជន អាយុ៥ឆ្នាំ ឡើង៖ សរុប ១,៥% បុរស១,៤% ស្ត្រី ១,៧%
- ក្នុងចំណោមប្រជាជនអាយុ ១៥-៦៤ឆ្នាំ ៖ សរុប២,៣% បុរស ២,១% ស្ត្រី២,៥%[20]

### ២.៤.៣ អត្រាពលកម្មតាមវិស័យ

វិស័យសេដ្ឋកិច្ច ចែកចេញជាបី៖ វិស័យទី១គឺ វិស័យកសិកម្ម វិស័យទី២គឺវិស័យឧស្សាហកម្ម និងវិស័យទី៣គឺ វិស័យសេវាកម្ម។ ការសិក្សាពីការចូលរួមនៃកម្លាំងពលកម្មទៅតាមវិស័យសេដ្ឋកិច្ច មានសារៈសំខាន់ណាស់ ពីព្រោះយើងអាចយល់ដឹងពីកម្រិតអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេសនីមួយៗ និងបម្រែបម្រួលនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចតាមវិស័យនីមួយៗ។ បច្ចុប្បន្ន ប្រទេសដែលមានការអភិវឌ្ឍតិចតួចឬកំពុងអភិវឌ្ឍន៍ កម្លាំងពលកម្ម ភាគច្រើនគរផ្តុំនៅក្នុងវិស័យកសិកម្ម។ ប្រទេសដែលមានការអភិវឌ្ឍន៍ខ្លាំង កម្លាំងពលកម្ម ភាគច្រើនគរផ្តុំនៅក្នុងវិស័យសេវាកម្ម។

យោងតាមទិន្នន័យឆ្នាំ២០០៨ និងឆ្នាំ២០១៣ ការចូលរួមតាមវិស័យសេដ្ឋកិច្ចរបស់ប្រជាជនកម្ពុជាអាយុ១៥ឆ្នាំឡើង មាន៖

- ឆ្នាំ២០០៨ ៖ ៦៤,២% បានចូលរួមការងារក្នុងវិស័យកសិកម្ម ១១,៥%បានចូលរួមការងារក្នុងវិស័យឧស្សាហកម្ម និង ២៤,៣% បានចូលរួមការងារវិស័យសេវាកម្ម
- ឆ្នាំ២០១៣ ៖ ៦៤,២% បានចូលរួមការងារក្នុងវិស័យកសិកម្ម ១១,៥%បានចូលរួមការងារក្នុងវិស័យឧស្សាហកម្ម និង ២៤,៣% បានចូលរួមការងារវិស័យសេវាកម្ម[21]

[19] របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០១៦ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨,២០

[20] ប៉ូច ប៉ុណ្ណាក់,សៀវភៅណែនាំសំរាប់បណ្តុះបណ្តាលស្តីពីគោលនយោបាយជាតិប្រជាជន&ប្រជាសាស្ត្រម៉ូឌុល១,រាជធានីភ្នំពេញ,២០១៨,៣១

**ក្រាហ្វិកទី៤៖ បម្រែបម្រួលកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ច៖ កម្ពុជា**




## ២.៥ គោលនយោបាយប្រជាសាស្ត្រ ២០១៦-២០៣០

### ចក្ខុវិស័យនិងទិសដៅនៃគោលនយោបាយ

ចក្ខុវិស័យនៃគោលនយោបាយជាតិប្រជាជន គឺដើម្បីបន្តលើកកម្ពស់ និងធ្វើឲ្យកាន់តែប្រសើរឡើងនូវគុណភាពនៃជីវិតរបស់ប្រជាជនកម្ពុជា ដោយផ្តោតយ៉ាងជាក់លាក់ និងច្បាស់លាស់ទៅលើវិធានការ និង សកម្មភាពអភិវឌ្ឍន៍ប្រកបដោយចីរភាព។ដូច្នេះ គោលដៅ ដ៏សំខាន់បំផុតរបស់គោលនយោបាយជាតិប្រជាជន គឺសម្របសម្រួលការបញ្ចូលឌីណាមិកប្រជាសាស្ត្រ ទៅក្នុងផែនការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ច និងធានាឲ្យបាននូវការអនុវត្តពីគ្រប់ភាគីពាក់ពន្ធ័ទាំងអស់ រហូតដល់ឆ្នាំ២០៣០។

ជាលក្ខណៈអន្តរជាតិ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ត្រូវបានជំនួសដោយគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ក្នុងន័យនេះ ទិសដៅនៃគោលនយោបាយជាតិប្រជាជន ត្រូវសម្របទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលមានដូចខាងក្រោម៖

[21] ប៉ូច ប៉ុណ្ណាក់,សៀវភៅណែនាំសំរាប់បណ្តុះបណ្តាលស្តីពីគោលនយោបាយជាតិប្រជាជន&ប្រជាសាស្ត្រម៉ូឌុល១,រាជធានីភ្នំពេញ,២០១៨,៣២

(i) កាត់បន្ថយសមាមាត្រប្រជាជន ដែលមានចំណូលទាបជាងខ្សែបន្ទាត់នៃភាពក្រីក្រថ្នាក់ជាតិ ដោយបង្កើនសមាមាត្រនៃចំណាយលើការប្រើប្រាស់ថ្នាក់ជាតិរបស់ក្រុមបញ្ចភាគក្របំផុត និង ប្រជាជនដែលទទួលរងនូវភាពអត់ឃ្លាន ពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០៣០។

(ii) កែលម្អនិងពង្រីកលទ្ធភាពនិងបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធស្រោចស្រព ដើម្បីបង្កើនរដូវដាំដុះ នៅក្នុងតំបន់ដាំដុះដំណាំកសិកម្ម។

(iii) កែលម្អនិងពង្រីកវិសាលភាពនៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទឹកជំនន់ និង គ្រោះរាំងស្ងួត ដើម្បីកាត់បន្ថយហានិភ័យ ដែលកើតឡើងដោយសារគ្រោះមហន្តរាយទាំងនេះ។

(iv) បង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាត និង អនាម័យដល់ប្រជាជនដែលមិនមានលទ្ធភាពទទួលបានពីឆ្នាំ២២០១៦ ដល់ ឆ្នាំ២០៣០។

(v) កាត់បន្ថយអត្រាគ្មានការងារធ្វើ ក្នុងចំណោមប្រជាជនក្នុងវ័យធ្វើការងារ តាមរយៈពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនកញ្ចប់ជំនាញរបស់យុវជន។លុបបំបាត់ពលកម្មកុមារនិងវិសមភាពយេនឌ័រនៃការងារដែលមានប្រាក់កម្រៃ និង ក្នុងស្ថាប័នសាធារណ: យ៉ាងយូរនៅឆ្នាំ២០៣០។

(vi) រៀបចំផែនការកាត់បន្ថយការកកស្ទះនៅទីក្រុងភ្នំពេញ តាមរយៈការរៀបចំផែនការនគរូបនីយកម្មត្រឹមត្រូវ និងការអភិវឌ្ឍទីក្រុងនិងទីប្រជុំជនផ្សេងទៀត ដោយភ្ជាប់នឹងគោលនយោបាយឧស្សាហកម្ម ដើម្បីកាត់បន្ថយភាពខុសគ្នាក្នុងតំបន់ យ៉ាងយូរនៅឆ្នាំ ២០៣០។

(vii) ធានាសម្រេចឲ្យបានការអប់រំមូលដ្ឋាន៩ឆ្នាំដល់កុមារទាំងអស់ ដោយជំរុញសមភាពយេនឌ័រ និងបង្កើនការចុះឈ្មោះចូលរៀនរបស់ក្មេងប្រុសនិងក្មេងស្រីក្នុងការសិក្សាបច្ចេកទេស និងវិជ្ជាជីវ: យ៉ាងយូរនៅឆ្នាំ២០៣០។

(viii) បង្កើនល្បឿនក្នុងការកាត់បន្ថយបន្ថែមទៀតនូវអត្រាមរណភាពមាតា អត្រាមរណភាពកុមារ និងអត្រាមរណភាពទារក យ៉ាងយូរនៅឆ្នាំ២០៣០។

(ix) សម្រេចឲ្យបាននូវតម្រូវការការបន្តពូជរបស់យុវជននិងគូស្វាមីភរិយា ហើយការមានកូនតាមបំណងត្រូវបានបំពេញនិងបង្កើនល្បឿននៃស្ថិរភាពប្រជាជន យ៉ាងយូរនៅឆ្នាំ២០៣០។

(x) កាត់បន្ថយអត្រាប្រេវ៉ាឡង់នៃមេរោគហ៊ីវ ជំងឺអេដស៍ និង កាត់បន្ថយការរីករាលដាលនៃជំងឺគ្រុនចាញ់ ជំងឺរបេង និងជំងឺឆ្លងផ្សេងឆ្ពោះទៅរកការលុបបំបាត់ការរីករាលដាលទាំងស្រុង យ៉ាងយូរនៅឆ្នាំ ២០៣០។

(xi) ធានាឲ្យបាននូវរបបសន្តិសុខសង្គមនិងសុខភាពដល់គ្រប់មនុស្សចាស់ទាំងអស់ និងជាពិសេស អ្នកដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រថ្នាក់ជាតិ យ៉ាងយូរនៅឆ្នាំ២០៣០។

(xii) ជំរុញកំណើននៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ដើម្បីឈានឆ្ពោះទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ដោយផ្អែកលើការគាំទ្រនិងការចូលរួមរបស់ប្រជាជននៅក្នុងវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដែលជាមូលដ្ឋានចំណេះដឹងនិងបច្ចេកទេស សម្រាប់ជាកាតាលីករដើម្បីផលិតភាព ប្រសិទ្ធភាពតម្លៃបន្ថែមកាន់តែទូលំទូលាយ។

ដើម្បីសម្រេចបាននូវចក្ខុវិស័យនិងទិសដៅគោលនយោបាយទាំងនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រ ដូចខាងក្រោម៖

(i) រាជរដ្ឋាភិបាលចាត់ទុកជាការចាំបាច់តម្រូវឲ្យមានទិសដៅគោលនយោបាយជាក់លាក់ដែលផ្តល់ការណែនាំដល់ក្រសួងនានានិងដៃគូអភិវឌ្ឍន៍ទាំងអស់ រួមមានផ្នែកឯកជនអង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នដែលបានរៀបរយ។ ការតម្រង់ទិសគោលនយោបាយទាំងនេះត្រូវមានទស្សនវិស័យរួម។

(ii) រាជរដ្ឋាភិបាលបានចែងរួចហើយនូវយុទ្ធសាស្ត្រតាមវិស័យដែលមានក្នុងឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ បន្ថែមលើការប្តេជ្ញាចិត្តរបស់ខ្លួននេះ កម្ពុជានឹងបន្តផ្តល់អាទិភាពខ្ពស់ចំពោះការរៀបចំផែនការដែលមានបញ្ចូលបញ្ហាប្រជាជននិងការអភិវឌ្ឍ ហើយកម្ពុជានឹងផ្តល់អាទិភាពដល់ផ្នែកសំខាន់ៗនៃវិស័យសុខាភិបាល អប់រំ សុខុមាលភាពសង្គម ការអភិវឌ្ឍតំបន់ទីក្រុងនិងជនបទ កសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ និង បរិស្ថាន ដើម្បីបង្កើតជម្រើសជីវភាពដល់ប្រជាជន។

(iii) រាជរដ្ឋាភិបាលនឹងបន្តផ្តោតលើកម្មវិធីកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍធនធានមនុស្សនិងការបង្កើតកញ្ចប់ជំនាញ ដើម្បីជួយបំពេញតម្រូវការនៃកំណើនកម្លាំងពលកម្ម យុវជនដ៏ច្រើន ដែលអាចធ្វើឲ្យគុណភាពនៃជីវិតរបស់ប្រជាជនក្នុងប្រទេសកាន់តែប្រសើរឡើង។ការយកចិត្តទុកដាក់ជាពិសេស ត្រូវបានផ្តល់

ចំពោះក្រុមដែលមាន ឱកាសតិចតួច និងទទួលបានប្រយោជន៍តិចតួច គឺប្រជាជនដែលរស់នៅតំបន់ពិបាកទៅដល់ស្រ្តី កុមារ និង មនុស្សចាស់ជរា។

(iv) បន្ថែមទៅលើការធ្វើឲ្យកាន់តែប្រសើរឡើងនូវការអប់រំមូលដ្ឋាន និងការផ្តល់ការអប់រំសម្រាប់ទាំងអស់គ្នាដល់កម្រិតមធ្យមសិក្សាបឋមភូមិ រាជរដ្ឋាភិបាលនឹងបន្តផ្តល់ការយកចិត្តទុកដាក់ ជាពិសេស ដល់ការបង្កើនធនធានមនុស្សនៅក្នុងប្រទេស ដោយការពង្រីកបណ្តាញ ស្ថាប័នអប់រំថ្នាក់ឧត្តមសិក្សានិងថ្នាក់ជំនាញវិជ្ជាជីវៈ ។ ជាមួយគ្នានេះដែរ ក្នុងន័យជាវិធានការបណ្តោះអាសន្ន កម្ពុជានឹងផ្តោតទៅលើការអប់រំបំណិនជីវិត និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីធានាឲ្យបាននូវធនធានមនុស្សដែលមានជំនាញ។

(v) រាជរដ្ឋាភិបាលនឹងមានផែនការអភិក្រមតាមដំណាក់កាលក្នុងការពង្រីកសេដ្ឋកិច្ចតាមវិស័យ រួមជាមួយនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ទាំងនៅតំបន់ជនបទទាំងនៅតំបន់ទីប្រជុំជនតូចៗ ដោយបង្កើតនូវឱកាសការងារថ្មីៗ ដែលនឹងអាចបង្អាក់ទេសន្តរប្រវេសន៍ ពីជនបទទៅតំបន់ទីប្រជុំជន។

(vi) រាជរដ្ឋាភិបាលនឹងសម្រេចឲ្យបាននូវស្ថិរភាពប្រជាជន ដោយបន្តដោះស្រាយដល់បុគ្គលគូស្វាមីភរិយា អំពីតម្រូវការពន្យាកំណើតដែលមិនបានឆ្លើយតប និងតាមរយៈការលើកទឹកចិត្តដល់បុរសឲ្យមានការទទួលខុសត្រូវស្មើភាពគ្នា ក្នុងការប្រើប្រាស់វិធីសាស្រ្តពន្យាកំណើត។ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តតាមវិធីសាស្រ្តវដ្តជីវិតចំពោះបញ្ហាសុខភាពមនុស្សវ័យជំទង់ យុវជន និងស្រ្តី ដោយផ្តោតសំខាន់ទៅលើសុវត្ថិភាព មាតុភាព ហើយធ្វើឲ្យសេវាសុខភាពបន្តពូជកាន់តែមានប្រសិទ្ធភាពខ្ពស់ ដើម្បីកាត់បន្ថយមរណភាពនិងភាពមានជំងឺរបស់មាតា ព្រមទាំងពិនិត្យមើលបញ្ហាជំងឺមិនឆ្លងនានា ដូចជាជំងឺមហារីកមាត់ស្បូន។ រាជរដ្ឋាភិបាលនឹងផ្តោតជាសំខាន់ចំពោះបញ្ហាសុខភាពកុមារ រួមទាំងសិទ្ធិកុមារនិងអាហារូបត្ថម្ភ។

(vii) រាជរដ្ឋាភិបាលនឹងបន្តខិតខំប្រឹងប្រែងរៀបចំយុទ្ធសាស្រ្តនិងក្របខណ្ឌវិនិយោគឆ្ពោះទៅរកការបិទបញ្ចប់ការឆ្លងរាលដាលទាំងស្រុងនៃមេរោគហ៊ីវ ជំងឺអេដស៍យ៉ាងយូរនៅឆ្នាំ២០៣០ និងដោះស្រាយបញ្ហាដែលទាក់ទងនឹងការគ្រប់គ្រងជំងឺកាមរោគនិងបង្កើតសេវាថែទាំនិងផ្តល់ប្រឹក្សានៅតាមមូលដ្ឋានសុខាភិបាល ដើម្បីផ្លាស់ប្តូរ ឥរិយាបថ លើកកម្ពស់ការរួមភេទដោយសុវត្ថិភាពក្នុងចំណោមយុវជន។

បង្កើត និងពង្រីកការផ្តល់សេវាថែទាំសុខភាពមនុស្សចាស់ជរា ជាពិសេសសម្រាប់ជំងឺមិនឆ្លងនៅតាម មូលដ្ឋានសុខាភិបាល។

(viii) រាជរដ្ឋាភិបាលនឹងព្យាយាមសម្រេចឲ្យបាននូវសមធម៌ ដោយការដោះស្រាយបញ្ហាដែលទាក់ទងទៅនឹងភាពខុសគ្នារវាងខេត្តមួយនិងខេត្តមួយ គម្លាតយេនឌ័រ និងបញ្ហាសិទ្ធិមនុស្សនៃប្រជាជនទូទៅ និងជាពិសេសគឺស្ត្រី។

(ix) រាជរដ្ឋាភិបាលនឹងបន្តលើកកម្ពស់ការសម្របសម្រួលអន្តរវិស័យ ដោយឲ្យស្ថាប័នដែលធ្វើការងារពាក់ពន្ធ័នឹងការអភិវឌ្ឍនិងសុខុមាលភាពទាំងអស់របស់រាជរដ្ឋាភិបាលចូលរួមអនុវត្តជាលក្ខណៈប្រព័ន្ធ និងជំរុញការផ្តល់សេវារួមនៅថ្នាក់មូលដ្ឋាន។រាជរដ្ឋាភិបាលនឹងបន្តបង្កើតភាពជាដៃគូជាមួយនឹងភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងអ្នកតំណាងនៅថ្នាក់មូលដ្ឋាន ដើម្បីរៀបចំផែនការនិងអនុវត្តកម្មវិធីតាមបែបវិមជ្ឈការ។

(x) រាជរដ្ឋាភិបាលនឹងបន្តអភិវឌ្ឍន៍រចនាសម្ព័ន្ធនិងប្រព័ន្ធទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ខេត្ត ដើម្បីប្រមូលទិន្នន័យអំពីការអនុវត្ត សម្រាប់ធ្វើឲ្យប្រសើរឡើងនូវកម្មវិធីតាមដានត្រួតពិនិត្យ ហើយនិងជំរុញលើកទឹកចិត្តដល់ការប្រកាន់ខ្ជាប់នូវក្រមសីលធម៌ គណនេយ្យភាព និងការចែករំលែកព័ត៌មាន នៅគ្រប់ប្រតិបត្តិការទាំងអស់ និង លើកកម្ពស់ដល់ការអនុវត្តប្រកបដោយក្រមសីលធម៌។

(xi) រាជរដ្ឋាភិបាលនឹងបន្តបង្កើតធនធាន ដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈរូបវន្តផ្សេងទៀត ហើយជាមួយគ្នានេះដែរ ក៏មានការយកចិត្តទុកដាក់ខ្ពស់ទៅលើការប្រើប្រាស់ធនធានដែលមាន ឲ្យបានត្រឹមត្រូវ។[22]

[22] គោលនយោបាយជាតិប្រជាជន ២០១៦-២០១៨

# ជំពូកទី៣

# ស្ថានភាពការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា

## ៣.១ ស្ថានភាពកំណើនសេដ្ឋកិច្ចកម្ពុជាចន្លោះឆ្នាំ ២០១១-២០១៨

### ៣.១.១ ស្ថានភាពកំណើនសេដ្ឋកិច្ចកម្ពុជា

#### ៣.១.១.១ អត្រាកំណើនផលិតផលក្នុងស្រុកសរុប(ផ.ស.ស)

ព្រះរាជាណាចក្រកម្ពុជា ទទួលបាននូវជោគជ័យគួរឲ្យកត់សម្គាល់ក្នុងវិស័យសេដ្ឋកិច្ច ដែលសម្រេចបានកំណើនរឹងមាំសម្រាប់រយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ ជាមួយនឹងអត្រាកំណើនមធ្យមប្រចាំឆ្នាំ៧,៧%។នៅក្នុងឆ្នាំ២០១៤សេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើនតាមការរំពឹងទុក ដែលក្នុងនោះកំណើនផ.ស.ស ប្រចាំឆ្នាំស្ថិតក្នុងអត្រា ៧,១%ដោយសារកំណើនខ្ពស់នៃវិស័យសំណង់ ទោះបីមានការថមថយកំណើននៃការនាំចេញ សម្លៀកបំពាក់ និងចំនួនភ្ញៀវទេសចរក្តី។កំណើនផ.ស.ស ដែលសម្រេចបាននេះត្រូវបានជំរុញដោយកំណើននៃវិស័យឧស្សាហកម្ម(១០,១%) ដែលក្នុងនោះវិស័យសំណង់បាន នាំមុខជាលើកទីមួយ វិស័យសេវាកម្ម (៨,៧%) , និង វិស័យកសិកម្ម (០,៣%) ។ សកម្មភាពសេដ្ឋកិច្ចឆ្នាំ២០១៥ នៅតែបន្តកំណើនខ្ពស់ក្នុងអត្រា ៧% ដែលជំរុញជាសំខាន់ដោយវិស័យឧស្សាហកម្ម(១១,៧%) ជាពិសេសគឺវិស័យកាត់ដេរ។ កំណើនវិស័យសេវាកម្មនៅបន្តរឹងមាំទោះបីថមថយបន្តិចបន្តួច (៧,១%) ខណៈដែលវិស័យកសិកម្មនៅបន្តកំណើនទាប (០,២%) ។ សេដ្ឋកិច្ចឆ្នាំ ២០១៦ ត្រូវបានរំពឹងថានៅតែមានសន្ទុះកំណើនខ្ពស់ប្រមាណ ៧% ដែលស្របទៅនឹងការព្យាករទុកនៅដើមឆ្នាំ ២០១៦ ក្នុង ផ.យ.អ.ជ ២០១៤-២០១៨ ។សេដ្ឋកិច្ចដែលបន្តកំណើនរឹងមាំនេះ នៅតែបន្តទ្រទ្រង់ជាសំខាន់ដោយវិស័យកាត់ដេរ ទោះជាកំណើនហាក់ដូចជាថមថយបន្តិចក្តី។ ការរីកចម្រើននៃវិស័យមិនមែនកាត់ដេរ គួបផ្សំនឹងការងើបឡើងវិញនៃវិស័យកសិកម្ម បានជួយប៉ះប៉ូវដល់ការថមថយកំណើនវិស័យសំណង់ និងទេសចរណ៍។[23]

[23] របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០១៦ស្តីពីការអនុវត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ២០១៤-២០១៨,៨

**តារាងទី៧៖ កំណើនផលិតផលក្នុងស្រុកសរុប ពីឆ្នាំ ២០១៣-២០១៨**

| សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ (ប៉ាន់ស្មាន) | ២០១៨ (ព្យាករ) |
|---|---|---|---|---|---|---|---|
| ផ.ស.ស (ថ្លៃបច្ចុប្បន្ន) | ប៊ីលានរៀល | ៦១ ៣២៧ | ៦៧ ៤៣៧ | ៧៣ ៤២៣ | ៨០ ៥៥៩ | ៨៩ ៤៧៨ | ៩៩ ០២៣ |
| ផ.ស.ស (ថ្លៃបច្ចុប្បន្ន) | លានដុល្លារ | ១៥ ២២៩ | ១៦ ៧៩៦ | ១៨ ០៧៨ | ១៩ ៨៦២ | ២២ ១៦៥ | ២៤ ៥២៩ |
| អត្រាកំណើន ផ.ស.ស.ពិត | % | ៧,៤ | ៧,១ | ៧,០ | ៧,០ | ៧,០ | ៧,០ |
| កសិកម្ម | % | ១,៦ | ០,៣ | ០,២ | ១,៨៥ | ១,៩៦ | ១,៩៩ |
| ឧស្សាហកម្ម | % | ១០,៧ | ១០,១ | ១១,៧ | ១០,៥៥ | ១០,៦៩ | ១០,១១ |
| សេវាកម្ម | % | ៨,៧ | ៨,៧ | ៧,១ | ៦,៦៦ | ៦,៥៣ | ៦,៦៦ |
| ផ.ស.ស.ក្នុងប្រជាជនម្នាក់ | ពាន់រៀល | ៤ ១៩៣ | ៤ ៥៩៧ | ៤ ៩៣៥ | ៥ ២៨០ | ៥ ៧៨៩ | ៦ ៣២៤ |
| ផ.ស.ស.ក្នុងប្រជាជនម្នាក់ | ដុល្លារ | ១ ០៤២ | ១ ១៣៨ | ១ ២១៥ | ១ ៣០២ | ១ ៤៣៤ | ១ ៥៦៧ |
| អតិផរណា (អត្រាកំណើនជាមធ្យមប្រចាំឆ្នាំ) | % | ៣,០ | ៣,៩ | ១,២ | ៣,០ | ៣,៨ | ៣,៥ |
| អត្រាប្តូរប្រាក់ (មធ្យមប្រចាំឆ្នាំ) | រៀល/ដុល្លារ | ៤ ០២៧ | ៤ ០៣៨ | ៤ ០៦០ | ៤ ០៥៣ | ៤ ០៣៧ | ៤ ០៣៧ |
| ទុនបម្រុងបរទេសដុល | នាំចូល ខែ | ៣,៨ | ៤,២ | ៤,៤ | ៥,៥ | ៦,៦ | ៦,០ |
| ទុនបម្រុងបរទេសដុល | លានដុល្លារ | ៣ ៦៤៣ | ៤ ៣៩១ | ៥ ០៩៣ | ៦ ៧៣១ | ៨ ៧៥០ | ១១ ១០០ |

ប្រភព÷ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មករា ឆ្នាំ ២០១៧

### ៣.១.១.២ ចំណូលប្រជាជនក្នុងពលរដ្ឋម្នាក់

ផលិតផលក្នុងស្រុកសរុបក្នុងប្រជាជនម្នាក់ ( តម្លៃថេរ ឆ្នាំ២០០០ )បានកើនឡើងជាមធ្យម ៧,៧% ក្នុងរយ:ពេល៣ឆ្នាំចុងក្រោយនេះ។ចំណូលជាមធ្យមក្នុងប្រជាជនម្នាក់ បានកើនឡើងពី១១៣៨ ដុល្លាអាមេរិក ( ២០១៤ ) ទៅ ១៣០២ ដុល្លាអាមេរិក( ២០១៦ ) និង កំពុងនៅលើផ្លូវត្រូវដើម្បីឈានទៅសម្រេចគោលដៅនៃ ផ.ឃ.អ.ជ ដែលកំណត់ ១៥៧៩ ដុល្លារអាមេរិក នៅឆ្នាំ ២០១៨ ។ ការកើនឡើងនេះធ្វើអោយឲ្យមានការបង្កើនកម្រិតជីវភាពរស់នៅរបស់ប្រជាជន។ការកើនឡើងផលិតផលក្នុងស្រុកសរុបក្នុងប្រជាជនម្នាក់ បានធ្វើឲ្យកម្ពុជាវិវត្តខ្លួនទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាបនាឆ្នាំ២០១៥។[24]

### ៣.១.១.២ អត្រាកំណើនតាមវិស័យ

ជានិន្នាការនៃការអភិវឌ្ឍសេដ្ឋកិច្ច បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ស្ទើរតែទាំងអស់មានការវិវត្តបណ្តើរៗចេញពីប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្ម ទៅជាប្រទេសដែលមានសេដ្ឋកិច្ច

[24] របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០១៦ស្តីពីការអនុវត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ២០១៤-២០១៨,១០

ផ្អែកលើវិស័យឧស្សាហកម្ម។ មូលហេតុចំបងដែលធ្វើឲ្យមានការផ្លាស់ប្តូរនេះ គឺដោយសារហេតុផលថាផលិតភាពនៃកម្លាំងពលកម្មនិងចំណូលរបស់ប្រជាជនដែលបំរើការក្នុងវិស័យមិនមែនកសិកម្មដូចជា វិស័យកម្មន្តសាល វិស័យទេសចរណ៍ វិស័យសំណង់ និងវិស័យសេវាកម្មមានកម្រិតខ្ពស់ជាងផលិតភាពនិងចំណូលដែលបានមកពីបម្រើការងារក្នុងវិស័យកសិកម្ម ។ ទោះជាដូចនេះក្តី ការរៀបរាប់ខាងលើនេះមិនមែនដើម្បីគូសបញ្ជាក់ថា វិស័យកសិកម្មមិនគួរត្រូវបានយកចិត្តទុកដាក់នោះទេ។

បន្ទាប់ពីមានការថមថយកំណើនមធ្យមប្រចាំឆ្នាំមកត្រឹម ០,៧% ក្នុងចន្លោះឆ្នាំ ២០១៣-២០១៥វិស័យកសិកម្ម ចាប់ផ្តើមងើបឡើងបន្តិចជាមួយនឹងអត្រាកំណើន៣% ក្នុងឆ្នាំ ២០១៦ ដោយសារភាពអំណោយផលនៃកត្តាអាកាសធាតុ ពោលគឺទឹកភ្លៀងបានធ្លាក់រាយប៉ាយល្អទូទាំងប្រទេស ដែលធ្វើឲ្យទិន្នន័យ និងបរិមាណផល ស្រូវមានការកើនឡើង ស្របពេលដែលបរិមាណផលិតកម្ម និងតម្លៃកៅស៊ូកាន់តែមានសន្ទុះឈានឡើង ទោះបីតម្លៃស្រូវមានការធ្លាក់ចុះបន្តិចក្តី។ យើងសង្កេតឃើញថា អត្រាកំណើនមធ្យមប្រចាំឆ្នាំនៃវិស័យកសិកម្មក្នុងចន្លោះឆ្នាំ ២០១៤-២០១៦ សម្រេចបានត្រឹមតែ ១,២៥% ប៉ុណ្ណោះពោលគឺទាបជាងអត្រាកំណើនជាមធ្យមនាឆ្នាំ ២០០៩-២០១៣ប្រមាណ៣,៧% និងស្ថិតនៅក្រោមគោលដៅកំណត់ក្នុង ផ.យ.អ.ជ. ដែលបានកំណត់កំណើនប្រចាំឆ្នាំ ៥% ក្នុងអំឡុងអាណត្តិរបស់ខ្លួន។ កំណើនយឺតនៃវិស័យកសិកម្ម ត្រូវបានប៉ះប៉ូវមកវិញដោយកំណើនខ្ពស់នៃវិស័យឧស្សាហកម្ម។រវាងឆ្នាំ ២០១៤-២០១៦ វិស័យឧស្សាហកម្មបានកើនឡើង ១០,៩% ក្នុងមួយឆ្នាំ។ ការរក្សាបាននូវកំណើនដ៏រឹងមាំនៃវិស័យឧស្សាហកម្ម ត្រូវបានរួមចំណែកសំខាន់ភាគច្រើនដោយកំណើនខ្ពស់នៃវិស័យកាត់ដេរ និងសំណង់។ ក្រោយពីវិស័យសំណង់បានក្លាយជាវិស័យជំរុញកំណើនទី១ ជាលើកដំបូងក្នុងឆ្នាំ ២០១៤ក្នុងអត្រាកំណើន ២១,៥% វិស័យ នេះបានថមថយជាបន្តបន្ទាប់មកត្រឹម ១៥,៩% នាឆ្នាំ ២០១៦ ដោយសារវដ្តកំណើននៃវិស័យនេះដែលជាធម្មតាតែងមានរយៈពេលមួយខ្លី ។ ដោយឡែក វិស័យកាត់ដេរនឹងនៅតែបន្តដើរតួនាទីជាជន្ទល់ទ្រទ្រង់កំណើនដដែល ព្រមទាំងផ្តល់ការងារជូនប្រជាពលរដ្ឋរាប់សែននាក់ក្នុង១ឆ្នាំ ទោះបីមានការថមថយបន្តិចប៉ុន្តែនៅតែខ្ពស់ជាងឆ្នាំ២០១៥ ក្នុងអត្រា ៨,០% នាឆ្នាំ២០១៦ ដោយសារកំណើនយឺតនៃពាណិជ្ជកម្មជាសកល ការកើនឡើងនៃប្រាក់ដុល្លារអាមេរិក ការដកខ្លួនចេញរបស់ប្រទេសអង់គ្លេសពីសហគមន៍អឺរ៉ុប និងការកើនឡើងជាបន្តបន្ទាប់នៃប្រាក់ឈ្នួលអប្បបរមា។ វិស័យសេវាកម្មក្នុងអំឡុងរយៈពេលដូចគ្នា ( ២០១៤-២០១៦ )បានកើនឡើងដោយអត្រាកំណើនប្រចាំឆ្នាំជាមធ្យម៧,៥% ខ្ពស់ជាងកំណើន

៧,១%នាឆ្នាំ២០១៥ និងគោលដៅផ.យ.អ.ជ. ៧,២%សម្រាប់ឆ្នាំ២០១៨ ទោះបីជាមានការថមថយបន្តិចនាឆ្នាំ ២០១៦។ វិស័យសេវាកម្មឆ្នាំ២០១៦ មានការថមថយបន្តិចមកត្រឹម ៦,៦% ធៀបនឹងឆ្នាំ ២០១៤ និង ២០១៥ ដោយសារការបន្តកំណើនយឺតនៃវិស័យទេសចរណ៍ និង ការថមថយកំណើននៃវិស័យអចលនទ្រព្យ។ អនុវិស័យផ្សេងទៀតនៃវិស័យសេវាកម្មរួមមានពាណិជ្ជកម្មក្នុងស្រុកនៅមានកំណើនខ្ពស់នៅឡើយ ដែលមួយផ្នែកគាំទ្រដោយគោលនយោបាយវិត្តារកម្មរបស់រាជរដ្ឋាភិបាល ដែលជំរុញដល់ការប្រើប្រាស់ក្នុងស្រុកខណៈ ដែលវិស័យគមនាគមន៍មានសន្ទុះកំណើនខ្ពស់ទៅជួយបំពេញដល់ការថមថយនៃវិស័យដឹកជញ្ជូន។

បើទោះបីជា ផ.យ.អ.ជ. ២០១៤-២០១៨ មិនបានកំណត់គោលដៅជាក់លាក់សម្រាប់ចំណែកនៃអនុវិស័យនីមួយៗ ក្នុង ផ.ស.ស ។ ក្នុងអំឡុងពាក់កណ្តាលដំបូងនៃការអនុវត្ត ផ.យ.អ.ជ. ២០១៤-២០១៨ និន្នាការនៃចំណែកតាមវិស័យ ក្នុង ផ.ស.ស មានការផ្លាស់ប្តូរគួរឲ្យកត់សម្គាល់ ។ តាមការប៉ាន់ស្មាន ចំណែកនៃវិស័យកសិកម្មបានថយចុះ ពី២៨,៩% ក្នុងឆ្នាំ២០១៤ ដល់ ២៥,៥% ក្នុងឆ្នាំ២០១៦ ដោយសារការថមថយនៃបរិមាណផលិត និងការធ្លាក់ចុះនៃតម្លៃកសិផលក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ ខណៈវិស័យឧស្សាហកម្មមានកំណើនបញ្ច្រាសវិញពី ២៥,៦% ទៅ២៩,០% ។ នេះឆ្លុះបញ្ចាំងពីការផ្លាស់ប្តូររចនាសម្ព័ន្ធពីសេដ្ឋកិច្ចដែលពឹងផ្អែក វិស័យកសិកម្មមកពឹងផ្អែកលើឧស្សាហកម្មវិញ ដែលទ្រទ្រង់ដោយកំណើនជាបន្តបន្ទាប់នៃវិស័យកាត់ដេរ សំណង់ ម្ហូបអាហារ ភេសជ្ជៈ ព្រមទាំងគ្រឿងបង្គុំអេឡិចត្រូនិក។ វិស័យសេវាកម្មបានរក្សាចំណែករបស់ខ្លួនក្នុង ផ.ស.ស ឲ្យនៅដដែលក្នុងរយៈពេល៣ឆ្នាំចុងក្រោយនេះពោលគឺស្ថិតក្នុងរង្វង់៣៩,៧% ដោយសារកំណើននៃសកម្មភាពអាជីវកម្មក្នុងស្រុក ដែលបានទៅជួយបំពេញការថមថយនៃតម្លៃបន្ថែមក្នុងវិស័យទេសចរណ៍ និងអចលនទ្រព្យ។[25]

[25] របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០១៦ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨,១១

**តារាងទី៨៖ចំណែកនិងកំណើននៃវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្មក្នុង ផ.ស.ស(ភាគរយ)**

| | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ (ប៉ាន់ស្មាន) |
|---|---|---|---|---|
| ចំណែកតាមវិស័យ (ថ្លៃបច្ចុប្បន្ន) | | | | |
| វិស័យកសិកម្ម | ២៨,៩ | ២៦,៦ | ២៥,៥ | ២៤,៤ |
| ដំណាំ | ១៧,២ | ១៥,៨ | ១៥,២ | ១៤,៥ |
| វិស័យឧស្សាហកម្ម | ២៥,៦ | ២៧,៧ | ២៩,០ | ៣០,៣ |
| វាយនភណ្ឌ | ១០,១ | ១០,៦ | ១០,៧ | ១០,៩ |
| សំណង់ | ៨,៥ | ៩,៨ | ១០,៦ | ១១,៣ |
| វិស័យសេវាកម្ម | ៣៩,៧ | ៣៩,៨ | ៣៩,៥ | ៣៩,៣ |
| សណ្ឋាគារ និងភោជនីយដ្ឋាន | ៥,១ | ៤,៩ | ៥,២ | ៥,០ |
| កំណើនតាមវិស័យ (ថ្លៃពិត) | | | | |
| វិស័យកសិកម្ម | ០,៣ | ០,២ | ១,៨៥ | ១,៩៦ |
| ដំណាំ | ០,៥ | ០,៣ | ២,២៥ | ២,១ |
| វិស័យឧស្សាហកម្ម | ១០,១ | ១១,៧ | ១០,៥៥ | ១០,៦៩ |
| វាយនភណ្ឌ | ៦,៦ | ៩,៨ | ៨,០២ | ៨,៤៥ |
| សំណង់ | ២១,៤ | ១៩,២ | ១៥,៩ | ១៤,១ |
| វិស័យសេវាកម្ម | ៨,៧ | ៧,១ | ៦,៦៦ | ៦,៥៣ |
| សណ្ឋាគារ និងភោជនីយដ្ឋាន | ៦,១ | ២,៤ | ២,២៣ | ២,៣៤ |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មករា ឆ្នាំ២០១៧*

## ៣.២ កត្តាជំរុញអោយមានកំណើនសេដ្ឋកិច្ច

### ៣.២.១ ធនធានរូបវ័ន្តដែលធម្មជាតិផ្តល់អោយ

ព្រះរាជាណាចក្រកម្ពុជាស្ថិតក្នុងចំណោមប្រទេសក្រីក្របំផុតមួយនៅក្នុងពិភពលោក ដែលមានប្រជាពលរដ្ឋវ័យក្មេង អាយុក្រោម២០ឆ្នាំ ចំនួន ៤៨% ដែលឈានដល់វ័យធ្វើការ និងកំពុងត្រូវការនូវទីផ្សារការងារ។ ការកើនឡើងនូវសម្ពាធ និងតម្រូវការដី និងធនធានធម្មជាតិដោយតែកំណើនប្រជាជន (ប្រហែល ១,៥៣% ) កំណើននៃភាពគ្មានការងារ ការផ្លាស់ប្តូរទីលំនៅក្នុងប្រទេស និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងវិស័យសេដ្ឋកិច្ចផ្សេងៗ គួបផ្សំជាមួយកង្វះខាតខាងផ្នែកច្បាប់ និងការអនុវត្តនៅមិនទាន់មានប្រសិទ្ធភាពខ្ពស់ផងនោះ បណ្តាលឲ្យព្រៃឈើរបស់

យើងប្រឈមនឹងការធ្វើអាជីវកម្មដោយគ្មាននិរន្តភាព ព្រមទាំងបន្តឲ្យមានទំនាស់ពាក់ទៅនឹងសិទ្ធិកាន់កាប់ និងប្រើប្រាស់ព្រៃឈើ។[26]

**ក.ធនធានព្រៃឈើ**

ព្រះរាជាណាចក្រកម្ពុជា បានទទួលជោគជ័យគួរឲ្យកត់សម្គាល់ក្នុងការថែរក្សាធនធានព្រៃឈើ ដលគ្របដណ្តប់ជាង ៥៩% ស្មើនឹងជាង ១០,៨ លានហិកតានៃផ្ទៃប្រទេស។ ធនធានព្រៃឈើទាំងនេះ មានលក្ខណៈជីវសាស្ត្រពិសេសប្លែក និងជាតំបន់មរតកវប្បធម៌ជាតិ ដែលមានសក្តានុពល និងផ្តល់ទិន្នន័យខ្ពស់។ ជាងនេះទៅទៀតព្រៃឈើរបស់កម្ពុជា មានទំនាក់ទំនងយ៉ាងជិតស្និទ្ធិជាមួយនឹងវិស័យកសិកម្ម និងជលផលដោយជួយរក្សានិរន្តរភាព និងផលិតភាពនៃវិស័យទាំងពីរនេះ។សេវាព្រៃឈើរួមមានទាំងការរក្សានិយ័តភាពប្រភពទឹក ចរន្តទឹក ការទប់ស្កាត់ភាពរាំងស្ងួត និងទឹកជំនន់ ការកាត់បន្ថយការហូរច្រោះដី ការរាក់គោកនៃទន្លេ- ស្ទឹង - អូរ - បឹងបួរ។ល។ ដូច្នេះព្រៃឆោះមានតួនាទីសំខាន់ក្នុងការអភិវឌ្ឍជាតិដោយចីរភាព។ ការប្រើប្រាស់ព្រៃឈើប្រកបដោយនិរន្តផាពអាចផ្តល់ផលប្រយោជន៍ យ៉ាងច្រើនដល់ ប្រទេសជាតិ និងប្រជាជន។ ឱកាសជាច្រើនកំពុងតែកើតឡើងនៅទីផ្សាអន្តរជាតិ ដូចជាការកែច្នៃផលិតផលព្រៃឈើ និងផលិតផលព្រៃឈើកែច្នៃដែលមានតម្លៃខ្ពស់ និងសក្តានុពលនៃការអភិវឌ្ឍទីផ្សារកាបូនព្រៃឈើជាដើម។ ប្រភពហិរញ្ញវត្ថុថ្មីៗ កំពុងត្រូវបានគេបង្កើតឡើងតាមរយៈយន្តការ″ការបង់ថ្លៃសេវាកម្មបរិស្ថាន ″ សម្រាប់ការអភិរក្សធនធានព្រៃឈើ និងជីវចម្រុះ។ ភាគច្រើននៃប្រជាពលរដ្ឋជនបទជាកសិករ ហើយប្រមាណជា ៧៥%នៃគាត់ ក៏ដូចជាគ្រួសារដែលគ្មានដីស្រែ គឺពឹងផ្អែកទៅលើការប្រមូលផលពីធនធានព្រៃឈើសម្រាប់ការចិញ្ចឹមជីវិត ពិសេសនៅពេលជួបគ្រោះធម្មជាតិ។ ព្រៃឈើ ក៏បានផ្តល់អំណោយផលដល់ប្រជាកសិករផងដែរនូវឱកាសក្នុងការដាំដុះដំណាំចម្រុះ ការរកប្រាក់ចំណូលបន្ថែម និងការបង្កើតការងារដោយសហគ្រាសផលិតកម្មអនុផលព្រៃឈើ។

ការថ្លឹងថ្លែងឲ្យមានតុល្យភាពរវាងជំរើសនៃការអភិវឌ្ឍសេដ្ឋកិច្ច ការទាញយកផលប្រយោជន៍កានតើតែច្រើនឡើងពីព្រៃឈើ និងកិច្ចការពារបរិស្ថាន គឺជាបញ្ហាលំបាកមួយ ដោយយើងមិនអាចទុកចោលនូវបញ្ហាណាមួយបានឡើយ។ ការចាត់ចែងគ្រប់គ្រងដ៏ប៉ិនប្រសប់នៃធនធានព្រៃឈើប្រកបដោយសមធម៌ គឺជាមូលដ្ឋានសម្រាប់ផលប្រយោជន៍សេដ្ឋកិច្ចទំនើប

[26] កម្មវិធីព្រៃឈើជាតិ ២០១០-២០២៩,១០

ហើយក៏អាចរក្សា និងពង្រឹកនូវមុខងារ ប្រព័ន្ធអេកូឡូស៊ី ភាពសម្បូរបែបនៃជីវចម្រុះ និងភាពខុសគ្នានៃអេកូឡូស៊ីទៀតផង។[27]

**ខ.ធនធានទឹក**

កម្ពុជាគឺជាប្រទេសមួយ ដែលមានទឹកដ៏សន្ធឹកសន្ធាប់នៅតំបន់។ បណ្ដាស្ទឹង ទន្លេ បឹង ទឹកក្រោមដី និងទឹកសមុទ្រគឺជាប្រភពដ៏សំខាន់ជាអាយុជីវិតសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិនៅក្នុងវិស័យជាច្រើនដូចជា កសិកម្ម ឧស្សាហកម្ម សហគ្រាស វារីអគ្គិសនី នាវាចរណ៍ ទេសចរណ៍ ការការពារបរិស្ថាន និងជីវភាពប្រចាំថ្ងៃ។ ទឹកនៅកម្ពុជាមានពីរប្រភេទគឺៈ ទឹកភ្លៀងប្រចាំឆ្នាំប្រមាណ ៧៥.០០០លានម៣ និងទឹកក្រោមដីប្រមាណ ១៧.៦០០០ លានម៣។ កំពស់ទឹកភ្លៀងប្រចាំឆ្នាំនៅកម្ពុជាស្ថិតក្នុងចន្លោះ១.៤០០មម និង៣.៥០០មម អាស្រ័យទៅតាមតំបន់នានានៃប្រទេស។ ទន្លេសំខាន់ៗចំនួន០២ គឺ ទន្លេមេគង្គ និងទន្លេសាបមានមុខងារយ៉ាងសំខាន់ចំពោះការរក្សាបាននូវវារីអេកូឡូស៊ី និងផ្ដល់មូលដ្ឋានធនធានធម្មជាតិសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គម។ ជាឧទាហរណ៍ កសិកម្ម និងជលផលជាប្រភពចំណូលដ៏សំខាន់ចំពោះជាតិនិងគ្រួសារ។ ទឹកត្រូវបានគេយកទៅប្រើប្រាស់យ៉ាងច្រើនមុខព្រួញ ដូចជា ក្នុងគ្រួសារ កសិកម្ម ឧស្សាហកម្ម វារីអគ្គិសនី នាវាចរណ៍ និងទេសចរណ៍។ល។ សេដ្ឋកិច្ចកម្ពុជាមានការអាស្រ័យយ៉ាងខ្ពស់លើធនធានទឹក។ សារៈប្រយោជន៍នៃធនធានទឹកចំពោះផលិតផលស្បៀងអាហារ និង ជីវភាពពលរដ្ឋតាមជនបទ។[28]

**គ.ធនធានរ៉ែ និង ប្រេងកាត**

ធនធានរ៉ែ គឺជាសម្បត្តិធម្មជាតិមួយក្នុងចំណោមសម្បត្តិធម្មជាតិដ៏មានតម្លៃជាច្រើនទៀតដូចជា សមុទ្រ ព្រៃឈើ រុក្ខជាតិ និងសត្វ( Flora and Fauna ) ជាដើម ប៉ុន្តែលក្ខណៈពិសេសរបស់ធនធានរ៉ែគឺជាសម្បត្តិធម្មជាតិមួយដែលមិនកកើតឡើងវិញឡើយ។ ប្រទេសដែលសម្បូរធនធានរ៉ែគឺជាប្រទេសដែលមានកំណប់មហាសាលដែលធម្មជាតិបានផ្ដល់ឲ្យប្រជាជាតិនោះ។ កម្ពុជាត្រូវបានគេចាត់ទុកថាជាប្រទេសដែលមានធនធានរ៉ែច្រើនប្រភេទ រាជរដ្ឋាភិបាលកំពុងខិតខំជាជំហានៗ ដើម្បីកំណត់ឲ្យបានជាក់លាក់នូវទំហំ និងបរិមាណធនធានរ៉ែទាំងនោះ។ រ៉ែសំណង់បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់វត្ថុធាតុដើមមានថ្មសំណង់ ក្រួស ខ្សាច់ ឡាតេរីត សម្រាប់បម្រើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន វារីអគ្គិសនី ទំនប់ធារា

[27] កម្មវិធីព្រៃឈើជាតិ ២០១០-២០២៩,១០

[28] ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុសំរាប់វិស័យធនធានទឹក(២០១៣-២០១៧),ភ្នំពេញ,២០១២,៩

សាស្ត្រ និងសំណង់នានាទូទាំងប្រទេស។ ចុងឆ្នាំ២០១៧ មានអាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្មប្រមាណ ២៦០ បានផ្តល់ឲ្យអាជីវករធ្វើអាជីវកម្មធនធានរ៉ែសំណង់លើផ្ទៃដីប្រមាណជាង ៦០០០ហិចតា ដោយប្រើកម្លាំងពលកម្មជាង៥០០០នាក់ និងមានទុនវិនិយោគសរុបប្រមាណ ៣៣៥ ០០០ ០០០ដុល្លារអាមេរិក។

ឯផ្នែករ៉ែឧស្សាហកម្មក៏បានរីកចម្រើនគួរឲ្យកត់សម្គាល់ផងដែរ ក្នុងនោះការធ្វើអាជីវកម្មថ្មកំបោរសម្រាប់ផ្គត់ផ្គង់ដល់រោងចក្រផលិតស៊ីម៉ងត៍ក្នុងស្រុកបានកើនឡើងយ៉ាងខ្លាំង។ បច្ចុប្បន្ននេះ មានរោងចក្រផលិតស៊ីម៉ងត៍ចំនួន៥កំពុងដំណើរការដែលអាចមានលទ្ធភាពផ្គត់ផ្គង់ស៊ីម៉ងត៍ប្រមាណ៧០០០ ០០០ តោនក្នុងមួយឆ្នាំ ឆ្លើយតបនឹងតម្រូវការសាងសង់ និងកាត់បន្ថយបានជាអិបរមានូវការនាំចូលផលិតផលស៊ីម៉ងត៍ពីក្រៅប្រទេស។ជាងនេះទៅទៀត អាជីវកម្មថ្មកំបោរនេះក៏ត្រូវបានប្រើប្រាស់ជាវត្ថុធាតុដើមសម្រាប់ផ្គត់ផ្គង់ដល់រោងចក្រអគ្គិសនី និងដល់អាជីវកម្មផលិតចំណីសត្វផងដែរ។

ចំពោះរ៉ែលោហៈវិញមានអាជ្ញាបណ្ណស្វែងរុករកធនធានរ៉ែចំនួន៥៩អាជ្ញាបណ្ណ គិតត្រឹមចុងឆ្នាំ២០១៧ត្រូវបានផ្តល់ដល់វិនិយោគិនទាំងក្នុងស្រុក និងក្រៅស្រុក ដើម្បីធ្វើការសិក្សាស្រាវជ្រាវរ៉ែលោហៈដែលរួមមានរ៉ែដែក មាស ទង់ដែង និងរ៉ែបុកស៊ីត។ ដោយឡែកអាជ្ញាបណ្ណ ឧស្សាហកម្មអាជីវកម្មធនធានរ៉ែចំនួន២៧ ក៏បានផ្តល់ការវិនិយោគិនសម្រាប់អាជីវកម្មរ៉ែដែក មាស ត្បូងថ្ម និងខ្សាច់ស៊ីលីតា ដែលក្នុងនោះឧស្សាហកម្មអាជីវកម្មរ៉ែមាសខ្នាតមធ្យមចំនួន១ កំពុងដំណើរការសាងសង់រោងចក្រដែលគ្រោងនឹងចាប់ផ្តើមអាជីវកម្មរ៉ែមាសនាឆ្នាំ២០១៨នេះ។ ទុនវិនិយោគសរុបសម្រាប់រ៉ែលោហៈនេះមានចំនួនប្រមាណ៧៣៣ ០០០ ០០០ដុល្លារសហរដ្ឋអាមេរិក ដោយប្រើកម្លាំងពលកម្មចំនួនប្រមាណ ១៥០០នាក់។

អាស្រ័យដោយការកែទម្រង់លើវិធានការប្រមូលចំណូលពីវិស័យរ៉ែនានាឆ្នាំ២០១៥ បានធ្វើឲ្យចំណូលពីវិស័យរ៉ែក្នុងឆ្នាំ ២០១៦ មានការកើនឡើងរហូតដល់ជាង ៥២ ០០០ ០០០ ០០០ រៀល (ជាងដប់បីលានដុល្លារសហរដ្ឋអាមេរិក )ធៀបទៅឆ្នាំ២០១៣ ដែលមានតែ ៧ ០០០ ០០០ ០០០រៀល (ជិតពីរលានដុល្លារសហរដ្ឋអាមេរិក)តែប៉ុណ្ណោះ។[29]

### ៣.២.២ ធនធានមនុស្ស

ប្រទេសកម្ពុជា សម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់ខ្លួនមួយចំនួនដូចជាការកាត់បន្ថយអត្រាមរណៈទារក និងមាតា បីភាគបួនកម្រិតប្រាក់ចំណូលបានកើនឡើង ហើយ

[29] គោលនយោបាយជាតិស្តីពីធនធានរ៉ែឆ្នាំ ២០១៨-២០២៨,២០១៨,១

កម្រិតក្រីក្រ បានធ្លាក់ចុះចំណែកឯស្ថិតិ សុខាភិបាល និងវិស័យអប់រំជាច្រើនទៀត បានប្រសើរឡើងខ្លាំង។

**ក្រាបទី៥ ៖ និន្នាការនៃសន្ទស្សន៍អភិវឌ្ឍធនធានមនុស្ស , ឆ្នាំ១៩៩០-២០១៤**




កម្មវិធីអភិវឌ្ឍរបស់អង្គការសហប្រជាជាតិ ស្តីពីការអភិវឌ្ឍមនុស្ស កំណត់ធាតុសំខាន់ៗចំនួនបី។ មនុស្សគួរតែ៖

- មានជីវិតរស់នៅឲ្យបានយូរអង្វែង និងមានសុខភាពល្អ ( អាយុកាលជាមធ្យម )
- ទទួលបានចំណេះដឹង ( បានចូលសាលារៀន )
- ទទួលបានធនធានដែលចាំបាច់ សម្រាប់ការរស់នៅឲ្យបានសមរម្យ ( អំណាចនៃការទិញមានភាពស្មើគ្នា និងប្រាក់ចំណូល )។

ចាប់តាំងពីឆ្នាំ ១៩៨០ ដល់ ២០១៣ ប្រទេសកម្ពុជា បានធ្វើឲ្យប្រសើរឡើងនូវសន្ទស្សន៍មនុស្ស គឺពី ០.២៥១ ទៅដល់០.៥៨៤។ ទោះបីជាយ៉ាងណាក៏ដោយនៅក្នុងឆ្នាំ ២០១៣ ប្រទេសកម្ពុជានៅតែជាប់ចំណាត់ថ្នាក់១៣៦ ក្នុងចំណោមប្រទេសនៅក្នុងប្រភេទនៃការអភិវឌ្ឍមធ្យម។[30]

[30] https://opendevelopmentcambodia.net/km/topics/social-development/ ចូលថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៩

# ជំពូកទី៤

# ការសិក្សាលើលទ្ធផល

## ៤.១ ទំនាក់ទំនងរវាងកំណើនប្រជាជន និងការអភិវឌ្ឍសេដ្ឋកិច្ច

ក្នុងផ្នែកនេះយើងនឹងបង្ហាញពីលទ្ធផលនៃការសិក្សា និងបកស្រាយនូវលទ្ធផលដែលយើងទទួលបាន ទាំងទៅលើចំនួនប្រជាជន និងផលិតផលក្នុងស្រុកសរុប ( GDP ) ក្នុងឆ្នាំ ២០១៣ ដល់ ២០១៨ ។

### ក.គណនា GDP

ក្នុងការគណនាផលិតផលក្នុងស្រុកសរុប (GDP)ប្រចាំឆ្នាំយើងអនុវត្តន៍តាមរូបមន្តដូចខាងក្រោម៖

GDP=C+I+G+ (X-M)

C = Consumption អ្នកប្រើប្រាស់

I = Investment ការវិនិយោគ

G = Government រដ្ឋាភិបាល

X = Export ការនាំចេញ

M = Import ការនាំចូល

### ខ.គណនាGDP per Capital

ដើម្បីគណនាចំនូលប្រជាជនសរុបក្នុងពលរដ្ឋម្នាក់យើងត្រូវអនុវត្តន៍រូបមន្តដូចខាងក្រោម៖

GDP per Capital= GDP/Population

### គ.គណនា អត្រាកំណើនប្រជាជនប្រចាំឆ្នាំ

ដើម្បីគណនាអត្រាកំណើនប្រជាជនប្រចាំឆ្នាំ យើងត្រូវអនុវត្តន៍រូបមន្តដូចខាងក្រោម៖

អត្រាកំណើនប្រជាជនប្រចាំឆ្នាំក្នុងចន្លោះពេលមួយ គឺជាសូចនាករដែលវាស់វែងពីកម្រិតនៃការកើន(អត្រាកំណើនវិជ្ជមាន) ឬការថយចុះនៃចំនួនប្រជាជន ( អត្រាកំណើនអវិជ្ជមាន ) គិតជាភាគរយៈក្នុងមួយឆ្នាំៗនៅចន្លោះពេលនោះ។

រង្វាស់មួយដែលវ៉ាស់វែងពីកំណើនប្រជាជនក្នុងចន្លោះពេលណាមួយ គឺអត្រាកំណើនប្រចាំឆ្នាំ(រូបមន្តខាងក្រោម)។តាមរូបមន្តនេះ អត្រាកំណើនប្រជាជនក្នុងមួយឆ្នាំៗ ចាប់ពីរយៈពេលដើមទី($T_o$) ដល់រយៈពេលចុងទី($T_i$) អាចគណនាបានតាមរូបមន្តកំណើនអ៊ិចស្ប៉ូណង់ស្យែលមួយ ដែលត្រូវបានសម្រួលដូចខាងក្រោម៖

- រូបមន្តទី១ ៖ អត្រាកំណើនប្រចាំឆ្នាំ ស្មើនឹងឡូការីតនៃផលធៀបរវាងចំនួនប្រជាជននៅគ្រាដើមទីនិងចំនួនប្រជាជននៅគ្រាចុងទី រួចចែកនឹងចំនួនឆ្នាំចាប់ពីគ្រាដើមទីដល់គ្រាចុងទីនិងគុណនឹង ១០០
- រូបមន្តទី២ ៖ អត្រាកំណើនប្រចាំឆ្នាំ ស្មើនឹងឡូការីតចំនួនប្រជាជននៅគ្រាដើមទីដកនឹងឡូការីតចំនួនប្រជាជននៅគ្រាចុងទី ចែកនឹងចំនួនឆ្នាំចាប់ពីគ្រាដើមទីដល់គ្រាចុងទី និងគុណនឹង១០០។

$$\text{អត្រាកំណើនប្រចាំឆ្នាំ} = \frac{\ln\left(\frac{\text{ចំនួននៅឆ្នាំ } T_i}{\text{ចំនួននៅឆ្នាំ } T_0}\right)}{(T_i - T_0)} * 100$$

*ឬ អត្រាកំណើនប្រចាំឆ្នាំ* $= [\ln(\text{ចំនួននៅឆ្នាំ } T_i) - \ln(\text{ចំនួននៅឆ្នាំ } T_0)] / (T_i - T_0) * 100$

**តារាងទី៩៖ ចំនួនប្រជាជនសរុប និងផលិតផលក្នុងស្រុកសរុប ឆ្នាំ២០១៣ ដល់ ២០១៨**

| ឆ្នាំ | ប្រជាជនសរុប (គិតជាលាននាក់ ) | ផលិតផលក្នុងស្រុកសរុប (គិតជាលានដុល្លារ) |
|---|---|---|
| 2013 | 14,7 | 15,229 |
| 2014 | 14,9 | 16,796 |
| 2015 | 15,1 | 18,078 |
| 2016 | 15,3 | 19,862 |
| 2017 | 15,5 | 22,165 |
| 2018 | 15,8 | 24,529 |

តាមការសិក្សារបស់យើង យើងរកឃើញថា ចាប់ពីឆ្នាំ២០១៣ ដល់ ឆ្នាំ២០១៨ចំនួនប្រជាជនសរុប និង ផលិតផលក្នុងស្រុកសរុបមានការកើនឡើងគួរដូចគ្នា នេះបញ្ជាក់ថាកំណើនប្រជាជនមានទំនាក់ទំនងជាមួយនឹងផលិតផលក្នុងស្រុកសរុប។ ដូចនេះ កាលណាប្រជាជនកើនឡើង ធ្វើអោយមានកំលាំងពលកម្មកើនឡើង ដែលជាកត្តាជំរុញអោយមានការផលិតមានការកើនឡើង នាំអោយសេដ្ឋកិច្ចមានការអភិវឌ្ឍ ហើយសេដ្ឋកិច្ចកម្ពុជាក្នុងរយៈ៦ឆ្នាំចុងក្រោយនេះមានការកើនឡើងថេរ ដែលធ្វើអោយចំនូលប្រជាជនក្នុងពលរដ្ឋម្នាក់មានការកើនឡើងផងដែរ។

## ៤.២. ការវិភាគលើផលវិជ្ជមាន និងអវិជ្ជមាន

ក្នុងការសិក្សារបស់យើង យើងបានទទួលលទ្ធផលនៃការវិភាគដូចខាងក្រោម៖

**តារាងទី១០៖ លទ្ធផលនៃការសិក្សា**

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| SUMMARY OUTPUT | | | | | | | | |
| | | | | | | | | |
| *Regression Statistics* | | | | | | | | |
| Multiple R | 0.996966 | | | | | | | |
| R Square | 0.993941 | | | | | | | |
| Adjusted R Square | 0.992426 | | | | | | | |
| Standard Error | 301.675 | | | | | | | |
| Observations | 6 | | | | | | | |
| | | | | | | | | |
| ANOVA | | | | | | | | |
| | *df* | *SS* | *MS* | *F* | *Significance F* | | | |
| Regression | 1 | 59715840 | 59715840 | 656.161768 | 1.37953E-05 | | | |
| Residual | 4 | 364031.2 | 91007.8 | | | | | |
| Total | 5 | 60079871 | | | | | | |
| | | | | | | | | |
| | *Coefficients* | *andard Err* | *t Stat* | *P-value* | *Lower 95%* | *Upper 95%* | *Lower 95.0%* | *Upper 95.0%* |
| Intercept | -111345 | 5107.283 | -21.8013 | 2.61914E-05 | -125525.2716 | -97165.0913 | -125525.272 | -97165.09129 |
| Population | 859.5072 | 33.55398 | 25.61565 | 1.37953E-05 | 766.3464276 | 952.6680054 | 766.346428 | 952.6680054 |

ក្នុងការសិក្សា និងវិភាគរបស់យើង យើងឃើញថា គំរូរបស់យើង អាចបកស្រាយបាននូវបាតុភូតនៃប្រជាជនសរុប និងផលិតផលក្នុងស្រុកសរុប បានរហូតដល់ជាង៩៩.៣៩%។ មិនតែប៉ុណ្ណោះ តម្លៃ Significance F មានតម្លៃ តូចជាង១% ( Significance F=1.379)ហើយតម្លៃ F =656.16ដែលបង្ហាញថា គំរូខាងលើអាចទទួលយកបាន។ អថេរ ពន្យល់ Population មានតម្លៃ ៨៥៩.៥០៧២ ជាមួយនឹង តម្លៃ t Start ស្មើ 33.55 ដែលបង្ហាញថា ចំនួនប្រជាជននឹងមានផលវិជ្ជមានដល់កំណើនសេដ្ឋកិច្ច ដែលស្ថិតិក្នុងកំរិតជឿជាក់ ដល់ទៅ៩៥%។ ការបកស្រាយខាងលើបង្ហាញថា ចំនួនប្រជាជន មានឥទ្ធិពលវិជ្ជមានដល់កំណើនសេដ្ឋកិច្ច ដែលរាល់ការកើនឡើងនៃចំនួនប្រជាជននោះ សេដ្ឋកិច្ចនឹងមានការកើនឡើង។ ការបកស្រាយខាងលើ ក៏បានបង្ហាញផងដែរពី ឥទ្ធិពលវិជ្ជមាននៃចំនួនប្រជាជន ដែលមានទៅលើ កំណើនសេដ្ឋកិច្ច ក៏ដូចជាផលិតផលក្នុងស្រុកសរុបផងដែរ។

# សេចក្តីសន្និដ្ឋាន និង អនុសាសន៍

## ១.សេចក្តីសន្និដ្ឋាន

ជារួមមក ក្នុងការសិក្សារបស់យើង យើងបានរកឃើញថា ចំនួនប្រជាជន ពិតជាបានចូលរួមចំណែកវិជ្ជមានក្នុងការបង្កើនកំណើនសេដ្ឋកិច្ចជាតិពិតប្រាកដមែន ដែលចូលរួមរបស់វាមិនត្រឹមតែ ក្នុងសេដ្ឋកិច្ចនោះទេ កំណើនប្រជាជន នាំទៅរកការកើនឡើងកម្លាំងពលកម្ម ដែលត្រូវបានគេយល់ថាជាវិជ្ជមានក្នុងការជម្រុញកំណើនសេដ្ឋកិច្ច។ កម្លាំងពលកម្មកាន់តែច្រើនមានន័យថា អ្នកធ្វើការផលិតកាន់តែច្រើន ហើយចំនួនប្រជាជនសរុបច្រើនបានបង្កើនសក្តានុពលនៃទីផ្សារក្នុងស្រុក។ ទោះបីជាយ៉ាងណាក៏ដោយ មានសំណួរមួយបានលើកឡើងថា ប្រសិនការកើនឡើងយ៉ាងលឿននៃការផ្គត់ផ្គង់កម្លាំងពលកម្ម នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានពលកម្មលើសជាវិជ្ជមាន ឬអវិជ្ជមានទៅលើការអភិវឌ្ឍន៍? ជាក់ស្តែង វាគឺអាស្រ័យទៅលើសមត្ថភាពនៃប្រព័ន្ធសេដ្ឋកិច្ច ក្នុងការប្រើប្រាស់កម្លាំងពលកម្មបន្ថែមនេះ។ សមត្ថភាពនេះ ពាក់ព័ន្ធជាចាំបាច់ទៅនឹងអត្រា និងប្រភេទនៃការកើនឡើងនៃទុន បូករួមនិងកត្តាផ្សេងទៀត ដូចជា ជំនាញនៃការគ្រប់គ្រង និងរដ្ឋបាល។ តែប្រសិនបើចង់បង្កើនកម្រិតជីវភាពរស់នៅ ប្រសិនបើចំនួនប្រជាជនច្រើនពេក ហើយអត្រាកំណើនលឿនខ្លាំង ក៏ជាកត្តាជះឥទ្ធិពលខ្លាំងមកលើសេដ្ឋកិច្ចផងដែរ ព្រោះប្រជាជនច្រើនគឺត្រូវមានតំរូវការច្រើន តែប្រសិនបើប្រជាជនច្រើន តែសេដ្ឋកិច្ចនៅតែដដែលគ្មានកំណើន ឬអាចរួមតូច គឺវាធ្វើអោយប៉ះពាល់ខ្លាំងដល់ជីវភាពរស់នៅរបស់ប្រជាជនក្នុងប្រទេស។ ជាការពិតណាស់ កំណើនប្រជាជន និងមានការកើនឡើងជាយថាហេតុនៅក្នុងកម្លាំងពលកម្ម ត្រូវបានពិចារណាតាមទម្លាប់វិជ្ជមាន មួយក្នុងការធ្វើឲ្យមានកំណើនសេដ្ឋកិច្ច។ កម្លាំងពលកម្មដ៏ធំធេង មានន័យថាកម្មករផលិត គឺមានចំនួនច្រើន ហើយចំនួនប្រជាជនសរុបច្រើននោះកើននូវទំហំជាសក្តានុពលនៃទីផ្សារក្នុងស្រុក។ ម្យ៉ាងវិញទៀត វាជាបញ្ហាថាកំណើនភ្លាមៗនេះ បានផ្តល់កម្លាំងពលកម្មបន្ថែមដើម្បីអភិវឌ្ឍប្រទេសដែលបានជះឥទ្ធិពលវិជ្ជមាន និងអវិជ្ជមានទៅលើការអភិវឌ្ឍសេដ្ឋកិច្ចអោយមានកំណើន។

ជាក់ស្តែងគឺអាស្រ័យទៅលើកប្រព័ន្ធសេដ្ឋកិច្ច ដើម្បីស្រូបទាញយក ហើយនឹងធ្វើការយ៉ាងសកម្មដែលបន្ថែមអោយកម្មករ និងភាពដែលអាចរក្សាបាន ដូចជាចំណេះជំនាញ និងការគ្រប់គ្រងរដ្ឋបាលនៅក្នុងប្រទេសនោះ។ ការផ្តល់អោយមានការយល់ដឹងដំបូងនៃសមាសភាគជាមួយមូលគ្រឹះទាំងពីរ គឺមូលដ្ឋានគ្រឹះនៃបច្ចេកវិទ្យា និងធនធានមនុស្ស ដែលបានផ្តល់ឲ្យមានព្រំដែនលទ្ធភាពផលិតកម្ម បានគូសបង្ហាញនូវចំនួនអតិបរមា បូកបញ្ចូលផលិតផលដែលបាននៃ

ផលរបរ នៅពេលមានធនធានទាំងអស់មានគ្រប់គ្រាន់ ត្រូវបានប្រើប្រាស់អោយមានប្រសិទ្ធភាព និងចំគោលដៅនោះ។

ប្រសិនបើ វាមិនមានការផ្លាស់ប្តូរនៃបច្ចេកវិទ្យាទេ ចំនួននៃធនធានមនុស្សឡើងទ្វេដង ដែលជាលទ្ធផលនៃការវិនិយោគមួយក្នុងកាបង្កើនគុណភាពនៃធនធានមនុស្សដែលមានស្រាប់ ឬការវិនិយោគនៅក្នុងធនធានថ្មីដូចជា ដី មូលធន ក្នុងករណីដែលមានពលកម្មច្រើន និងគ្រួសារខ្នាតធំ។ ការរីកចម្រើននៃបច្ចេកវិទ្យា ក៏ជាមធ្យោបាយក្នុងការដោះស្រាយដែលកើតមានដោយសារ កំណើនប្រជាជន និងការអភិវឌ្ឍសេដ្ឋកិច្ចផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ក៏យើងត្រូវមានវិធីសាស្ត្រក្នុងការទប់ស្កាត់ រកដំណោះស្រាយ និងវិធីបង្ការ កុំអោយមានកំណើនហួសប្រមាណ ឬធំជាងទំហំសេដ្ឋកិច្ចនោះឡើយ។ ព្រោះកំណើនប្រជាជនច្រើនហួសកម្រិតនៃការផ្គត់ផ្គង់ ឬផលិត នឹងបង្កអោយមានបញ្ហាក្នុងការដោះស្រាយ។

សរុបជារួម យើងឃើញថាកំណើនប្រជាជនពិត ជាមានផលវិជ្ជមានដល់ការអភិវឌ្ឍដល់សេដ្ឋកិច្ចជាតិពិតប្រាកដមែន។ ដើម្បីអោយប្រទេសមានការអភិវឌ្ឍ និង មានកំណើនកត្តាមនុស្សជាកត្តាសំខាន់ដែលជាឆ្អឹងខ្នង និងជាជន្ទល់ដើម្បីអភិវឌ្ឍប្រទេស។ មនុស្សជាមូលធនដ៏មានតំលៃ ក្នុងការចូលរួមធ្វើអោយសេដ្ឋកិច្ចជាតិរីកចម្រើន ។ ដូច្នេះជារួមគឺធ្វើយ៉ាងណាអោយកំណើនប្រជាជន មានតុល្យភាពរវាងការអភិវឌ្ឍសេដ្ឋកិច្ច ក៏ដូចជាទំហំសេដ្ឋកិច្ចជាតិផងដែរ។ ម្យ៉ាងទៀតកំណើនប្រជាជន មិនមានភាពប៉ះពាល់ដល់សេដ្ឋកិច្ចនោះទេ គឺវាអាស្រ័យលើប្រព័ន្ធសេដ្ឋកិច្ចដើម្បីស្រូបយក។

## ២.អនុសាសន៍

តាមការសិក្សារបស់យើង យើងឃើញថា ក្នុងការជំរុញអោយមានកំណើនសេដ្ឋកិច្ចជាតិ រដ្ឋាភិបាលអាចធ្វើការជំរុញអោយមានកំណើនសេដ្ឋកិច្ច តាមរយៈ ការលើកកម្ពស់ការវិនិយោគ បង្កើតការងារ ផ្តល់ឱកាសការងារដល់បុគ្គលមានសមត្ថភាព ប្រើប្រាស់តាមថ្លៃទីផ្សារ(ប្រាក់ឈ្នួលសមរម្យ) បណ្តុះបណ្តាលជំនាញ ផ្តល់ឱកាសការងារដល់បុគ្គលមានសមត្ថភាព។

ក្រៅពីនេះ រដ្ឋាភិបាលអាចធ្វើការលើកកម្ពស់អោយសេដ្ឋកិច្ចអោយមានកំណើន តាមរយៈ យុទ្ធសាស្ត្រដទៃទៀត ដូចជា ការជំរុញអោយមានផ្នែកផលិតត្រូវផ្តោតទៅលើ៖

- បង្កើនកំលាំងពលកម្ម ដែលចូលរួមក្នុងការផលិត
- បង្កើននូវមូលធនមនុស្ស ដូចជាចំណេះដឹង និង ចំណេះធ្វើរបស់ពលករ

ក្រៅពីនោះរដ្ឋាភិបាលត្រូវបង្កើន សមត្ថភាពចំណាយ ក្នុងសេដ្ឋកិច្ច ដែលបង្កអោយទីផ្សារ ដំណើរការ ដោយផ្តោតទៅលើ៖

- បង្កើនការចំណាយរបស់គ្រួសារ ដើម្បីអោយសាច់ប្រាក់មានលំហូរ
- បង្កើនការនាំចេញដើម្បីទាញសាច់ប្រាក់ពីក្រៅប្រទេស
- បន្ថយការនាំចូល កាត់បន្ថយការហូរចេញនូវមូលធនក្នុងស្រុកទៅក្រៅប្រទេស

ដើម្បីសម្រេចអោយបានគោលដៅដូចខាងលើ រដ្ឋាភិបាលគួរអនុវត្តនូវសកម្មភាពដូចខាងក្រោម៖

- បង្កើតគោលនយោបាយគាំទ្រអោយមានកំណើនប្រជាជន
- បង្កើតការអប់រំអោយបានទូលំទូលាយ ដល់ទីជនបទ កន្លែងដាច់ស្រយាល ដើម្បីអោយមានការអប់រំមានភាពរីកចម្រើន ក៏ដូចជាផ្តល់ឱកាសដល់កុមារនៅទីជនបទ និងទីដាច់ស្រយាល
- លើកកម្ពស់ និងបង្កើតអោយមានការវិនិយោគខាងបច្ចេកវិទ្យា
- បង្កើនអោយមានការបែងចែកភាគលាភអោយបានសមស្រប
- ធ្វើការកែទម្រង់នៃការអប់រំ ទាំងបរិមាណ និង គុណភាព
- បង្កើនគោលនយោបាយបណ្តុះបណ្តាលធនធានមនុស្ស ប្រកបដោយសមត្ថភាព
- បង្កើនអត្រាមានការងារធ្វើ
- បង្កើតការងារថ្មីៗក្នុងស្រុក
- បង្កើនការវិនិយោគទៅលើ វិស័យសុខាភិបាល និង ការអប់រំអោយមានភាពទូលំទូលាយ
- បង្កើតអោយមានការបង្ហាត់បង្រៀន ពីចំណេះដឹង និង ចំណេះធ្វើទៅដល់ពលរដ្ឋ និងពលករ ប្រកបដោយជំនាញ និងវិជ្ជាជីវៈ
- បង្កើនការជំរុញលើកទឹកចិត្តក្នុងការសន្សំ តាមរយៈការបង្កើនអត្រាការប្រាក់សន្សំ និងសុវត្ថិភាពសន្សំ
- បង្កើនការវិនិយោគ ដោយបន្ថយអត្រាការប្រាក់
- បង្កអោយស្ថានភាពសេដ្ឋកិច្ច សង្គម និង នយោបាយ មានស្ថេរភាពល្អ ដើម្បីផ្តល់ទំនុកចិត្តដល់ការវិនិយោគ(ក្នុងនិងក្រៅប្រទេស)
- ផ្តល់លក្ខណៈងាយស្រួលផ្នែក ផ្លូវច្បាប់ក្នុងការធ្វើអាជីវកម្ម

- ការដាក់ចេញគោលនយោបាយ យុទ្ធសាស្ត្រផ្សេងៗ ដើម្បីអោយអភិវឌ្ឍ សេដ្ឋកិច្ចអោយមានរីកចម្រើន និង មានកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព
- បង្កើនគោលនយោបាយអភិវឌ្ឍជាតិ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន និងកាត់បន្ថយអោយបាននៅភាពក្រីក្រ
- ការពារទីផ្សារក្នុងស្រុក ដើម្បីលើកទឹកចិត្តអោយមានការផលិតបន្ថែមក្នុងស្រុក
- ស្វែងរកទីផ្សារក្រៅប្រទេសបន្ថែម សម្រាប់បង្កើននិងជំរុញការនាំចេញ ក៏ដូចជាតម្រូវការសម្រាប់ផលិតបន្ថែម ដើម្បីបង្កើនចំណូលជាតិ
- បង្កើនលំហូរសាច់ប្រាក់ដោយការធ្វើពាណិជ្ជកម្មក្រៅស្រុក និងការជំរុញអោយមានការវិនិយោគ ជាជាងរក្សាប្រាក់ទុកចោលពីប្រជាជន
- លើកកម្ពស់វិស័យសុខាភិបាលបញ្ចៀសរាល់ជំងឺផ្សេងៗនិងកាត់បន្ថយអត្រាមរណៈ
- ជំរុញអោយមានការចូលរួមច្រើនជាងមុន ក្នុងសេដ្ឋកិច្ចពីសំណាក់កំលាំងពលកម្ម
- បន្ថយការនាំចូល និងបង្កើនការប្រើប្រាស់ផលិតផលក្នុងស្រុក
- លើកកម្ពស់ ការចំណាយ របស់ប្រជាជន ដែលផ្តោតទៅលើការចំណាយទៅលើផលិតផល និងសេវាកម្មក្នុងស្រុក
- បង្កើនការចំណាយរបស់រដ្ឋ ជាពិសេសទៅលើទំនិញ សាធារណៈ និងហេដ្ឋារចនាសម្ពន្ធ័ សង្គម ( ផ្លូវថ្នល់ ថាមពល ធារាសាស្ត្រ ស្ពាន សំណង់អាគារ ...)
- បង្កើនការអន្តរាគមន៍របស់រដ្ឋទៅក្នុងសេដ្ឋកិច្ច ដើម្បីទប់ស្កាត់ការឃុបឃិតតម្លៃក្នុងសេដ្ឋកិច្ច
- ផ្តល់ប្រាក់ខែអោយបានសមរម្យដល់កម្មករ ពលករ តាមទីផ្សារបច្ចុប្បន្ន
- ផ្តល់ឱកាសដល់បុគ្គលមានសមត្ថភាពក្នុងការអភិវឌ្ឍប្រទេសជាតិ
- រួមគ្នាលើកស្ទួយសេដ្ឋកិច្ច ទាំងអ្នកប្រើប្រាស់ រដ្ឋាភិបាល វិស័យឯកជន អង្គការក្រៅរដ្ឋាភិបាលផ្សេងៗ

# ឯកសារយោង


- សាស្ត្រាចារ្យ ម៉ម ចរិយារុធ និង ងួន ហេង , សេដ្ឋកិច្ចនយោបាយ,២០១៦
- N.Gregory Mankiw; David Romer ; David N.Weil ; A Contribution to The Empirics of Economic Growth
- Todaro,M.P.,&Smith,S.C.(2009).Economic Development .New York: Pearson Addison Wesley
- ច្បាប់ស្តីពីស្ថិតិ
- អង្កេតចន្លោះជំរឿននៃប្រជាសាស្ត្រឆ្នាំ ២០១៣ របាយការណ៍លទ្ធផលសរុបបណ្តោះអាសន្ន,២០១៣
- ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥
- គោលនយោបាយប្រជាជន ២០១៦-២០៣០
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- បណ្ឌិត លុជ្យ លីកាណាន់,*មូលហេតុនៃភាពក្រីក្រ&គោលនយោបាយពាក់ពន្ធ័ទីជនបទនៅកម្ពុជា*(វិទ្យាស្ថានសភាកម្ពុជា,២០១៥)
- រស់ បណ្ឌេត និង គឹម សុធន ,*ការធ្វើចំណាកស្រុក ការទប់ស្កាត់ការជួញដូរមនុស្ស&ការធ្វើអាជីវកម្មផ្លូវភេទ*(វិទ្យាស្ថានសភាកម្ពុជា,២០១៧)
- សៀវភៅណែនាំសម្រាប់បណ្តុះបណ្តាលស្តីពីគោលនយោបាយប្រជាជននិងប្រជាសាស្ត្រ ម៉ូឌុល១
- ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥
- គោលនយោបាយជាតិស្តីពីមនុស្សចាស់ ២០១៧
- ធន ប៉ូល និង គឹម កែវធីតា ,*បញ្ហាប្រឈមក្នុងការអប់រំថ្នាក់មូលដ្ឋាននៅខេត្តព្រះវិហារ ឧត្តរមានជ័យ&បន្ទាយមានជ័យ*(វិទ្យាស្ថានសភាកម្ពុជា,២០១៧)
- របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០១៦ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨
- ប៉ូច ប៊ុណ្ណាក់,សៀវភៅណែនាំសំរាប់បណ្តុះបណ្តាលស្តីពីគោលនយោបាយជាតិប្រជាជន&ប្រជាសាស្ត្រម៉ូឌុល១,រាជធានីភ្នំពេញ,២០១៨

- របាយការណ៍វិភាគស៊ីជម្រៅស្តីពីសុខភាពបន្តពូជ&សិទ្ធទទួលបានសេវាសុខភាពយុវវ័យកម្ពុជា,ភ្នំពេញ,២០១៦
- គោលនយោបាយជាតិប្រជាជន ២០១៦-២០១៨
- កម្មវិធីព្រៃឈើជាតិ ២០១០-២០២៩
- ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុសំរាប់វិស័យធនធានទឹក(២០១៣-២០១៧), ភ្នំពេញ,២០១២
- គោលនយោបាយជាតិស្តីពីធនធានរ៉ែឆ្នាំ ២០១៨-២០២៨,២០១៨
- https://opendevelopmentcambodia.net/km/topics/social-development/ ចូលថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៩
- លីម រតនៈ និង នេត ប៊ុនលីម " ឥទ្ធិពលនៃការវិនិយោគទៅលើកំណើនសេដ្ឋកិច្ចកម្ពុជា " ( ឆ្នាំ២០១៦) សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ,សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- សៀវភៅបង្រៀនឆ្នាំសិក្សា ២០១៨-២០១៩ របស់សាស្ត្រចារ្យ សាន់ មន្តិយ៉ា
- បណ្ឌិត ហង់ ជួន ណារ៉ុន,សេដ្ឋកិច្ចកម្ពុជា,២០១៥
- ពេជ្យ សម្បត្តិ និងជួរ ចន្ទារី "ការចូលរួមរបស់សហគ្រាសខ្នាតតូចក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសកម្ពុជា " សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ,សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

# ឧបសម្ព័ន្ធ

រូបភាពទី១ ទ្រឹស្តីរបស់លោក Malthus នៃចំនួនប្រជាជន



## តារាងទី១ ៖ចំនួនប្រជារាស្ត្រនៅកម្ពុជា យោងតាមប្រភពផ្សេងៗ

| ប្រភព | ប្រជារាស្ត្រ | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទាំងពីរភេទ | បុរស | ស្ត្រី | |
| (1) | (2) | (3) | (4) | (5) |
| ជំរឿនឆ្នាំ ១៩៦២ | 5728771 | 2862939 | 2865832 | កាលបរិច្ឆេទជំរឿនថ្ងៃទី១៧-១៩ ខែមេសា ឆ្នាំ១៩៦២ |
| អង្កេតទូទៅនូវប្រជាសាស្ត្រឆ្នាំ ១៩៨០ | 6589954 | 3049450 | 3540504 | កាលបរិច្ឆេទរាប់នៅដំណាច់ឆ្នាំ ១៩៦២ |
| អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ ១៩៩៣-៩៤ | 9870000 | 4714000 | 5156000 | កាលបរិច្ឆេទប៉ាន់ស្មានប្រជាសាស្ត្រខែមេសាឆ្នាំ១៩៩៨ លើមូលដ្ឋានគំរូដែលមានសំណាកគំរូ៥៤៧៩គ្រួសារ |
| អង្កេតប្រជាសាស្ត្រកម្ពុជាឆ្នាំ ១៩៩៦ | 10702329 | 5119587 | 5582742 | កាលបរិច្ឆេទប៉ាន់ស្មានប្រជាសាស្ត្រថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៩៨ លើមូលដ្ឋានគំរូដែលមានសំណាក២០០០០គ្រួសារ |
| ជំរឿនឆ្នាំ ១៩៩៨ | 11437656 | 5119587 | 5926248 | កាលបរិច្ឆេទកំណត់ជំរឿនថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨។ មិនរាប់បញ្ចូលតំបន់មួយចំនួនមានការប្រយុទ្ធនៅពេលធ្វើជំរឿន។តាមការប៉ានស្មានចំនួនប្រជារាស្ត្រនៅតំបន់ មិនរាប់បញ្ចូលនោះមាន៤៥០០០នាក់។ |
| អង្កេតប្រជាសាស្ត្រចន្លោះ ជំរឿនកម្ពុជាឆ្នាំ២០០៨ | 12824000 | 6197000 | 6627000 | ចំនួនប្រជាសាស្ត្រប៉ាន់ស្មានពីគ្រួសារធម្មតានាថ្ងៃទី០៣ ខែមីនាឆ្នាំ២០០៨ ដោយមិនគ្របដណ្តប់ប្រជាសាស្ត្រស្ថាប័នគ្មានផ្ទះសំបែង។ល។ |
| ជំរឿន ឆ្នាំ ២០០៨ | 13395682 | 6516054 | 6879628 | កាលបរិច្ឆេទកំណត់ជំរឿនថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨។ រាប់បញ្ចូលទាំងគ្រួសារខ្លះដែលមិនបានឆ្លើយ។ |
| អង្កេតប្រជារាស្ត្រចន្លោះ ជំរឿនកម្ពុជាឆ្នាំ ២០១៣ | 14676591 | 7121508 | 7555083 | ចំនួនប្រជាសាស្ត្រប៉ាន់ស្មានពីគ្រួសារធម្មតានាថ្ងៃទី០៣ ខែមីនាឆ្នាំ២០១៣ |

រូបភាពីទី២ ៖ អត្រាកំណើនប្រជាជនកម្ពុជាចាប់ពីឆ្នាំ ២០១៣ ដល់ ឆ្នាំ២០១៨




ប្រភព៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ២០១៤-២០១៨

រូបភាពទី៣៖ អាយុកាលសង្ឃឹមរស់របស់ប្រជាពលរដ្ឋកម្ពុជា




ប្រភព៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ២០១៤-២០១៨

**តារាងទី២ ៖ កំណើនប្រជាជន**

| សូចនករសំខាន់ៗ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ប្រជាជន | | | | | | | |
| សរុប: អង្កេតចន្លោះជំរឿន ខែមីនា ឆ្នាំ២០១៣ | លាននាក់ | ១៤,៧ | | | | | |
| ដង់ស៊ីតេប្រជាជន | ក្នុងមួយគម² | ៨២ | ៨៥ | ៨៧ | ៨៨ | ៨៩ | ៩០ |
| បុរសធៀបនឹងស្ត្រី | ស្ត្រី១០០នាក់ | ៩៤,៣ | ៩៦ | ៩៦,២ | ៩៦,៣ | ៩៦,៥ | ៩៦,៧ |
| អាយុ ០-១៤ | %នៃប្រជាជន | ២៩,៤ | ២៩,៦ | ២៩,២ | ២៨,៩ | ២៨,៧ | ២៨,៥ |
| អាយុ ១៥-៦៤ | %នៃប្រជាជន | ៦២,៦ | ៦៥,៩ | ៦៦,២ | ៦៦,៤ | ៦៦,៥ | ៦៦,៥ |
| អាយុ ៦៥ឆ្នាំឡើង | %នៃប្រជាជន | ៥,០ | ៤,៥ | ៤,៦ | ៤,៧ | ៤,៨ | ៥,០ |
| ជនបទ | %នៃប្រជាជន | ៧៨,៦ | ៧៨,៥ | ៧៨,៤ | ៧៨,៣ | ៧៨,២ | ៧៨,១ |
| ទីប្រជុំជន | %នៃប្រជាជន | ២១,៤ | ២១,៥ | ២១,៦ | ២១,៧ | ២១,៨ | ២១,៩ |
| អត្រាកំណើនប្រចាំឆ្នាំ | % | ១,៤៦ | ១,៤៤ | ១,៤២ | ១,៤១ | ១,៣៩ | ១,៣៦ |

ប្រភព៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨

ក្រាហ្វិកទី១ ៖ ការបែងចែកដីតាមតំបន់




| | Plain | | | Tonle Sap | | | Cambodia | | |
|---|---|---|---|---|---|---|---|---|---|
| | Less than 1 ha | 1 ha - 2 ha | 2 ha - 3 ha | Less than 1 ha | 1 ha - 2 ha | 2 ha - 3 ha | Less than 1 ha | 1 ha - 2 ha | 2 ha - 3 ha |
| 2009 | 56.1 | 26.7 | 8.8 | 34.4 | 30.0 | 15.4 | 46.9 | 27.7 | 11.5 |
| 2010 | 57.0 | 25.0 | 10.0 | 41.0 | 28.0 | 15.0 | 49.0 | 28.0 | 12.0 |
| 2011 | 73.4 | 21.8 | 3.3 | 49.8 | 32.5 | 10.1 | 64.4 | 25.8 | 6.1 |
| 2012 | 69.4 | 22.4 | 4.3 | 46.8 | 32.8 | 8.4 | 58.8 | 27.4 | 6.7 |
| 2013 | 66.6 | 24.4 | 4.9 | 41.9 | 35.5 | 11.7 | 56.2 | 29.6 | 7.5 |

**ប្រភព៖** NIS ( CSES 2009-2013 )

ក្រាហ្វិកទី២៖ ភាពក្រីក្រក្នុងប្រជាជនម្នាក់ៗនៅទីក្រុង ជនបទ និងកម្ពុជា




**ប្រភព៖** អ្នកស្រាវជ្រាវរៀបចំក្រាហ្វិកនេះដោយប្រើប្រាស់ទិន្នន័យពីធនាគារពិភពលោក(២០១៥)

ក្រាហ្វិកទី៣៖វដ្តវិលវល់នៃភាពក្រីក្រ (The Vicious Circle of Poverty )




ប្រភព៖ យកតាម Soubbontina, Tatyana P. and Chaterine A. Sheram ( 2000 )

រូបភាពទី៤ ៖ អត្រាមរណភាពមាតា និង ទារក




ប្រភព៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ២០១៤-២០១៨

រូបភាពទី៥ ៖ ការព្យាករណ៍អំពីលទ្ធភាពមានកូនសរុប(១៩៩០ - ២០៣០)




ប្រភព៖ ការព្យាករណ៍ចំនួនប្រជាជនកម្ពុជា៖ របាយការណ៍លេខ១២ នៃជំរឿនទូទៅនូវប្រជារាស្ត្រកម្ពុជាឆ្នាំ២០០៨

តារាងទី៣៖ ស្ថានភាពអាពាហ៍ពិពាហ៍

ភាគរយស្ត្រី បុរសវ័យក្មេង និង យុវជន អាយុ ១៥-២៤ឆ្នាំតាមស្ថានភាពអាពាហ៍ពិពាហ៍បច្ចុប្បន្ន និងឆ្នាំអង្កេតកម្ពុជា DHS ២០០៥-២០១៤

| ចរិតលក្ខណៈអង្កេត | 2000 | | | | 2005 | | | | 2010 | | | | 2014 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ស្ថានភាពអាពាហ៍ពិពាហ៍ | 15-17 | 18-19 | 20-24 | 15-24 | 15-17 | 18-19 | 20-24 | 15-24 | 15-17 | 18-19 | 20-24 | 15-24 | 15-17 | 18-19 | 20-24 | 15-24 |
| **ស្ត្រី** | | | | | | | | | | | | | | | | |
| មិនដែលរៀបការ | 94.1 | 75.4 | 44.5 | 72.0 | 95.9 | 77.3 | 40.8 | 67.0 | 95.5 | 77.8 | 43.1 | 68.0 | 93.5 | 67.6 | 35.8 | 59.1 |
| បច្ចុប្បន្នរៀបការរួច | 5.8 | 22.6 | 50.9 | 25.8 | 4.0 | 20.8 | 54.9 | 30.6 | 4.1 | 21.0 | 53.2 | 29.9 | 6.1 | 30.6 | 60.8 | 38.7 |
| រៀបការពីមុន | 0.1 | 2.0 | 4.6 | 2.2 | 0.1 | 1.9 | 4.3 | 2.4 | 0.4 | 1.2 | 3.7 | 2.1 | 0.4 | 1.8 | 3.4 | 2.2 |
| **បុរស** | | | | | | | | | | | | | | | | |
| មិនដែលរៀបការ | | | | | 99.7 | 94.4 | 60.5 | 82.1 | 99.4 | 95.5 | 66.8 | 84.6 | 98.8 | 93.5 | 59.4 | 79.1 |
| បច្ចុប្បន្នរៀបការរួច | | | | | 0.3 | 4.2 | 36.7 | 16.5 | 0.6 | 3.4 | 30.2 | 13.9 | 1.1 | 6.2 | 36.9 | 19.0 |
| រៀបការពីមុន | | | | | 0.0 | 1.4 | 2.8 | 1.4 | 0.0 | 1.1 | 3.0 | 1.5 | 0.1 | 0.4 | 3.7 | 1.9 |

**តារាងទី៤៖ អត្រាអក្ខរជននៅឆ្នាំ ២០១៣ ដល់ ២០១៨**

| សូចនាករសំខាន់ៗ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|---|
| ចំនួនវិទ្យាល័យបច្ចេកទេស | ចំនួន | ៤ | ៤ | ៥ | ៥ | ៦ | ៧ |
| ចំនួនសិស្សនៅមធ្យមសិក្សាបច្ចេកទេស | ចំនួន | ៧៣០ | ៩៨៤ | ១ ២៣៨ | ១ ៤៩២ | ១ ៧៤៦ | ២ ០០០ |
| អត្រាអក្ខរជន(១៥-២៤ ឆ្នាំ) | % | ៩១,៥ | ៩២,៥ | ៩៣,៥ | ៩៤,៥ | ៩៥,៥ | ៩៦,៥ |
| អត្រាអក្ខរជន(១៥-៤៥ឆ្នាំ) | % | | ៨៧,៧ | ៨៨,៤ | ៨៩,១ | ៨៩,៨ | ៩០,៥ |

ប្រភព៖ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨

**តារាងទី៥៖ សូចនាករទាក់ទងនឹងការអប់រំបឋមសិក្សា(ថ្នាក់ជាតិ)**

| សូចនាករ | ២០០០-២០០១ | ២០១២-២០១៣ | ២០១៣-២០១៤ | ២០១៤-២០១៥ | ២០១៥-២០១៦ | ២០១៦-២០១៧ |
|---|---|---|---|---|---|---|
| អត្រាពិតចូលរៀនថ្មី | ៧៦,៤០ | ៩៤,៣០ | ៩៨,១០ | ៩៤,៥០ | ៩៥,៩០ | ៩៥,១០ |
| អត្រាពិតនៃការសិក្សា | ៨៣,៨០ | ៩៧,០០ | ៩៨,២០ | ៩៧,៩០ | ៩៨,៤០ | ៩៧,៧០ |
| អត្រាបោះបង់ការសិក្សា | - | ១០,៥០ | ៨,៣០ | ៦,២០ | ៤,៦០ | - |
| អត្រាបញ្ចប់ការសិក្សា | ៤៦,៨០ (២០០៤-២០០៥) | ៨៧,៣៥ | ៨៨,៩៤ | ៨៤,១០ | ៨០,៦០ | ៧៩,៩០ |
| អត្រាត្រួតថ្នាក់ | ៤២,៩០ (២០០៥-២០០៦) | ៤,៨០ | ៥,១០ | ៦,៧០ | ៦,៦០ | - |
| អត្រាឆ្លងភូមិសិក្សា | ៨២,៦០ | ៧៦,៨០ | ៧៦,៨០ | ៧៨,៧០ | ៨២,១០ | ៨៥,៥០ |

ប្រភព៖ ស្ថិតិ និងសូចនាករអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា

## តារាងទី៦ ៖ សូចនាករទាក់ទងនឹងមធ្យមសិក្សាបឋមភូមិ(ថ្នាក់ជាតិ)

| សូចនាករ | ២០០០-២០០១ | ២០១២-២០១៣ | ២០១៣-២០១៤ | ២០១៤-២០១៥ | ២០១៥-២០១៦ |
|---|---|---|---|---|---|
| អត្រារួមនៃការសិក្សា | - | - | - | ៥៥,១០ | ៦៥,៥០ |
| អត្រាឡើងថ្នាក់ | - | ៧៧,៤០ | ៧៧,២០ | ៧៨,៦០ | ៨០,៦០ |
| អត្រាត្រួតថ្នាក់ | - | ១,៤០ | ១,៨០ | ២,២០ | ២,៥០ |
| អត្រាបោះបង់ការសិក្សា | - | ២១,២០ | ២១,០០ | ១៩,២០ | ១៧,០០ |
| អត្រាឆ្លងភូមិសិក្សា | ៦៣,០០ | ៦៩,១០ | ៧១,១០ | ៧២,៩០ | ៧៦,៦០ |

ប្រភព៖ ស្ថិតិ និងសូចនាករអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា

## ក្រាហ្វិកទី៤៖ បម្រែបម្រួលកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ច៖ កម្ពុជា


បម្រែបម្រួលកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ចៈ ប្រទេសអភិវឌ្ឍន៍
2018
2017
2016
2015
2014
2013
2012
2011
2010
2009
2008
2007
2006
2005
2004
2003
2002
2001
2000
1999
1998
1997
1996
1995
1994
1993
1992
1991
0%
10%
20%
30%
40%
50%
60%
70%
80%
90%
100%
កសិកម្ម
ឧស្សាហកម្ម
សេវាកម្ម

## តារាងទី៧៖ កំណើនផលិតផលក្នុងស្រុកសរុប ពីឆ្នាំ ២០១៣-២០១៨

| សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ (ប៉ាន់ស្មាន) | ២០១៨ (ព្យាករ) |
|---|---|---|---|---|---|---|---|
| ផ.ស.ស (ថ្លៃបច្ចុប្បន្ន) | ប៊ីលានរៀល | ៦១ ៣២៧ | ៦៧ ៤៣៧ | ៧៣ ៤២៣ | ៨០ ៥៥៩ | ៨៩ ៤៧៨ | ៩៩ ០២៣ |
| ផ.ស.ស (ថ្លៃបច្ចុប្បន្ន) | លានដុល្លារ | ១៥ ២២៩ | ១៦ ៧៩៦ | ១៨ ០៧៨ | ១៩ ៨៦២ | ២២ ១៦៥ | ២៤ ៥២៩ |
| អត្រាកំណើន ផ.ស.ស.ពិត | % | ៧,៤ | ៧,១ | ៧,០ | ៧,០ | ៧,០ | ៧,០ |
| កសិកម្ម | % | ១,៦ | ០,៣ | ០,២ | ១,៨៥ | ១,៩៦ | ១,៩៩ |
| ឧស្សាហកម្ម | % | ១០,៧ | ១០,១ | ១១,៧ | ១០,៥៥ | ១០,៦៩ | ១០,១១ |
| សេវាកម្ម | % | ៨,៧ | ៨,៧ | ៧,១ | ៦,៦៦ | ៦,៥៣ | ៦,៦៦ |
| ផ.ស.ស.ក្នុងប្រជាជនម្នាក់ | ពាន់រៀល | ៤ ១៩៣ | ៤ ៥៩៧ | ៤ ៩៣៥ | ៥ ២៨០ | ៥ ៧៨៩ | ៦ ៣២៤ |
| ផ.ស.ស.ក្នុងប្រជាជនម្នាក់ | ដុល្លារ | ១ ០៤២ | ១ ១៣៨ | ១ ២១៥ | ១ ៣០២ | ១ ៤៣៤ | ១ ៥៦៧ |
| អតិផរណា (អត្រាកំណើនជាមធ្យមប្រចាំឆ្នាំ) | % | ៣,០ | ៣,៩ | ១,២ | ៣,០ | ៣,៨ | ៣,៥ |
| អត្រាប្តូរប្រាក់ (មធ្យមប្រចាំឆ្នាំ) | រៀល/ដុល្លារ | ៤ ០២៧ | ៤ ០៣៨ | ៤ ០៦០ | ៤ ០៥៣ | ៤ ០៣៧ | ៤ ០៣៧ |
| ទុនបម្រុងបរទេសដុល | នាំចូល ខែ | ៣,៨ | ៤,២ | ៤,៤ | ៥,៥ | ៦,៦ | ៦,០ |
| ទុនបម្រុងបរទេសដុល | លានដុល្លារ | ៣ ៦៤៣ | ៤ ៣៩១ | ៥ ០៩៣ | ៦ ៧៣១ | ៨ ៧៥០ | ១១ ១០០ |

ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មករា ឆ្នាំ ២០១៧

## តារាងទី៨៖ចំណែកនិងកំណើននៃវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្មក្នុង ផ.ស.ស(ភាគរយ)

| | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ (ប៉ាន់ស្មាន) |
|---|---|---|---|---|
| **ចំណែកតាមវិស័យ (ថ្លៃបច្ចុប្បន្ន)** | | | | |
| វិស័យកសិកម្ម | ២៨,៩ | ២៦,៦ | ២៥,៥ | ២៤,៤ |
| ដំណាំ | ១៧,២ | ១៥,៨ | ១៥,២ | ១៤,៥ |
| វិស័យឧស្សាហកម្ម | ២៥,៦ | ២៧,៧ | ២៩,០ | ៣០,៣ |
| វាយនភណ្ឌ | ១០,១ | ១០,៦ | ១០,៧ | ១០,៩ |
| សំណង់ | ៨,៥ | ៩,៨ | ១០,៦ | ១១,៣ |
| វិស័យសេវាកម្ម | ៣៩,៧ | ៣៩,៨ | ៣៩,៥ | ៣៩,៣ |
| សណ្ឋាគារ និងភោជនីយដ្ឋាន | ៥,១ | ៤,៩ | ៥,២ | ៥,០ |
| **កំណើនតាមវិស័យ (ថ្លៃពិត)** | | | | |
| វិស័យកសិកម្ម | ០,៣ | ០,២ | ១,៨៥ | ១,៩៦ |
| ដំណាំ | ០,៥ | ០,៣ | ២,២៥ | ២,១ |
| វិស័យឧស្សាហកម្ម | ១០,១ | ១១,៧ | ១០,៥៥ | ១០,៦៩ |
| វាយនភណ្ឌ | ៦,៦ | ៩,៨ | ៨,០២ | ៨,៤៥ |
| សំណង់ | ២១,៤ | ១៩,២ | ១៥,៩ | ១៤,១ |
| វិស័យសេវាកម្ម | ៨,៧ | ៧,១ | ៦,៦៦ | ៦,៥៣ |
| សណ្ឋាគារ និងភោជនីយដ្ឋាន | ៦,១ | ២,៤ | ២,២៣ | ២,៣៤ |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មករា ឆ្នាំ២០១៧*

**ក្រាបទី៥ ៖ និន្នាការនៃសន្ទស្សន៍អភិវឌ្ឍធនធានមនុស្ស , ឆ្នាំ១៩៩០-២០១៤**




**តារាងទី៩៖ ចំនួនប្រជាជនសរុប និងផលិតផលក្នុងស្រុកសរុប ឆ្នាំ២០១៣ ដល់ ២០១៨**

| ឆ្នាំ | ប្រជាជនសរុប (គិតជាលាននាក់ ) | ផលិតផលក្នុងស្រុកសរុប (គិតជាលានដុល្លារ) |
|---|---|---|
| 2013 | 14,7 | 15,229 |
| 2014 | 14,9 | 16,796 |
| 2015 | 15,1 | 18,078 |
| 2016 | 15,3 | 19,862 |
| 2017 | 15,5 | 22,165 |
| 2018 | 15,8 | 24,529 |

## តារាងទី១០៖ លទ្ធផលនៃការសិក្សា

| SUMMARY OUTPUT | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |
| *Regression Statistics* | | | | | | | | |
| Multiple R | 0.996966 | | | | | | | |
| R Square | 0.993941 | | | | | | | |
| Adjusted R Square | 0.992426 | | | | | | | |
| Standard Error | 301.675 | | | | | | | |
| Observations | 6 | | | | | | | |
| | | | | | | | | |
| ANOVA | | | | | | | | |
| | *df* | *SS* | *MS* | *F* | *Significance F* | | | |
| Regression | 1 | 59715840 | 59715840 | 656.161768 | 1.37953E-05 | | | |
| Residual | 4 | 364031.2 | 91007.8 | | | | | |
| Total | 5 | 60079871 | | | | | | |
| | | | | | | | | |
| | *Coefficients* | *andard Err* | *t Stat* | *P-value* | *Lower 95%* | *Upper 95%* | *Lower 95.0%* | *Upper 95.0%* |
| Intercept | -111345 | 5107.283 | -21.8013 | 2.61914E-05 | -125525.2716 | -97165.0913 | -125525.272 | -97165.09129 |
| Population | 859.5072 | 33.55398 | 25.61565 | 1.37953E-05 | 766.3464276 | 952.6680054 | 766.346428 | 952.6680054 |